# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី៣៤ លេខ ២ ខែ កុម្ភៈ

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ
ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ

- អំពីអវិជ្ជា លោក -ដេងជ្រីវ រៀបរៀង . . . . . . . . ១២១
- លោកុត្តរាភិសម័យ (តចប់) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រីរៀបរៀង . . . . . ១៤១
- ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត)ៈលោកប៊ូ-ប៊ុំ ប្រែរៀបរៀង . . . . . . ១៤៨
- មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះញាណកោសលញ-ឈឹនពិនិត្យ ១៥៨
- មហោសថជាតក(ត)លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-ត្លូរ ពិនិត្យ ១៦៦
- រឿងនារទកស្សប កាព្យពាក្យ ៧ លោក យូ-អ៊ុន និពន្ធ . . . . . . . . ១៧១

ផ្នែកអក្សរសាស្ត្រ

- ការអានពាក្យវប្បធម៌ លោក គួច-គីឡេង រៀបរៀង . . . . . . . ១៩៦
- ពាក្យខ្មែរប្រែចេញពីបរទេស (ត) ដោយគណៈកម្មការវប្បធម៌ . . . . . . ២០៣
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . . ២០៤
- រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ២០៥
- រឿងព្រេងចិន (ត) លោក ភិយ ប៊ុក ប្រែរៀបរៀង. . . . . . . . ២០៨
- ភូមិសាស្ត្រសេដ្ឋកិច្ចអាហ្វ្រិកខាងត្បូង (តចប់) លោក ញ៉ែម-ទឹម ប្រែ . . . . . ២១១
- រឿងព្រេងប្រាប់ពីសុភាសិតដែលថា ឃ្លានទំអត់,ខ្សត់ទំរក,គេឲ្យច្រើនកុំយក,ខ្លាចឲ្យឬលដិត ២១៦

ផ្នែកកំណត់នឹងប្រវត្តិការណ៍

- មហាសន្និបាតនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ លោក ភិយ-ប៊ុក រៀបរៀង . . . . . ២២២
- គិលានដ្ឋាន បំរើនសុខភាព . . . . . . . . . . . . . . ២៣៧

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា ២៣០រ០០

34è Année — N° 2 — Février 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

**Partie religieuse** page

—L'Ignorance par M. PHENG-CHRIV . . . . . . . . . 121
—Lokkottarabhisamaya par l'Oknha TEA-SAN (suite et fin) 141
—Prah Abhidhamma pitaka (Kampi prah Yamaka)
(suite) par M. BOU-PO. . . . . . . . . . . . . 148
—Madhurasavahini (suite) traduit par Samdech Prah
Dhammalikhita LOUIS-EM, revu et corrigé
par Vén. NHEAN-CHHOEUN. . . . . . . . . . . 158
—Mahosotha Jataka (suite) relevé du manuscrit sur
feuilles de latanier par M. IM-PHON, revu et
corrigé par Vén. KEM-TO . . . . . . . . . . 166
—Histoire de Naradakassapa en vers par M. YOU-OUN . . 171

**Partie littéraire**

—Manière de lire des mots culturels par M. KUOCH-KY-LENG 196
—Activités de la Commission culturelle (suite) . . . . . 203
—Dictionnaire Sanscrit-Khmèr (suite)
par Vén. PANG-KHAT . . . . . . . . . . . . . 204
—Histoire de Sam-Kok (suite) traduite par l'Oknha
NOU-KAN . . . . . . . . . . . . . . . . . 205
—Contes et Légendes populaires de la Chine par M. RAY-BUC 208
—Géographie économique de l'Afrique du Sud (suite et fin)
traduite par M. NHEM-KHEM . . . . . . . . . 211
—Commentaires des proverbes cambodgiens par la
Commission des Mœurs et Coutumes . . . . . . 216

**Notes et Chroniques**

—La réunion de l'Association des Amis du Lycée
Bouddique par M. RAY-BUC. . . . . . . . . 222
—Infirmerie de Chamrœun SOKHA-PHEAP. . . . . . . 237

---

Abonnement annuel (comprenant 12 numéros) : 230 f 00

## ផ្នែកសាសនា

### អំពីអវិជ្ជា

លោក ដេង-ជ្រីវ រៀបរៀង

---

មុននឹងពោលថា អវិជ្ជា មានន័យដូចម្តេច ? ជាកត្តានាំឲ្យកើតអ្វី ? សូមពណ៌នាទូវភពសិន ។

ភពគឺអ្វី ?

ភព គឺជាទីសំណាក់របស់សត្វ ក្នុងដំណើរត្រាច់រង្គាត់ក្នុងវដ្ដសង្សារ ។ ភពមាន ៣ គឺ កាមភព ១ រូបភព ១ អរូបភព ១ ។

ហេតុដូចម្តេច បានជាហៅថា កាមភព ?

បានជាហៅដូច្នេះព្រោះភពនេះ ពោរពេញដោយកាម ( សេចក្តីតម្រេក ចំណង់ ) ឬដោយកាមគុណទាំង ៥ គឺ រូប សំឡេង ក្លិន រសសម្ផស្ស ។ សត្វក្នុងកាមភពរមែងក្រេបជញ្ជក់ ទោះបីតិច ឬច្រើនទូវកាមគុណទាំង ៥ នេះ មិនដែលអាក់ខានមួយវេលាណាឡើយ ។

ឯកាមភពមាន ១១ ភូមិ ដោយរាប់ស្ថានមនុស្សបញ្ចូលជាមួយផង ។

ហេតុម្តេចបានជាហៅថា រូបភព ?

បានជាហៅដូច្នេះព្រោះភពនេះ ប្រាសចាកកាមគុណទាំង ៥ គឺ

ថា បើសត្វណាមានបំណងនឹងទៅកើតទីនោះ ត្រូវឲ្យប្រាសចាកកាម-គុណទាំង ៥ ពីខន្ធសន្តាន បើពុំដូច្នោះទេ ខ្លួននឹងពុំអាចទៅអាស្រ័យនៅក្នុងភពនោះបានឡើយ ។

សូមបញ្ជាក់ថា ក្នុងរូបភព សត្វនៅត្រូវការប្រើប្រាស់រូបជាប្រយោជន៍ចិត្ត តែមិនមានការប្រកាន់មាំ នឹងការត្រេកក្នុងរូបដូចជាសត្វក្នុងកាមភពឡើយ ។

ហេតុម្តេចបានជាហៅ អរូបភព ?

បានជាហៅដូច្នេះព្រោះភពនេះ មិនត្រឹមតែប្រាសចាកកាមគុណទាំង ៥ ប៉ុណ្ណោះទេ គឺថែមទាំងមិនត្រូវការប្រើរូបទៀតផង ។ យ៉ាងនេះ បានជាមានសត្វខ្លះដោយយល់គាន់ស្មានថា ភពនេះជាព្រះនិព្វាន ។ ភពទាំងបីនេះរួមគ្នា ហៅថាសង្សារវដ្ត ឬ សង្សារចក្រ ។

តើមនោគតិនៃសត្វក្នុងត្រៃភព មានសភាពដូចម្តេច ?

សត្វក្នុងត្រៃភពតែងមានមនោគតិរបស់ខ្លួនមិននឹងនឡើយ មនោ-គតិនេះ លោតឆ្លងទៅឆ្លងមករវាងភពទាំងបី តាមទំហំនឹងកំឡាំងផលកម្មរបស់ខ្លួន ។ វិញ្ញាណសត្វប្រៀបដូចស្វាដែលមានខ្សែជាប់ក ហើយដែលគេចងទុកក្នុងរោងមួយមានបោះបង្គោលបី ប្រកបដោយឈើខ្វែងខាងចុង សម្រាប់ឲ្យសត្វនេះអាចលោតផ្លោះទៅមកបាន ។ ស្វាមិនអាចលោតផុតពីបង្គោលបីបានយ៉ាងណា វិញ្ញាណសត្វក៏មិនអាចនឹងស្ទុះ

ផុតចេញពីកពប័បានយ៉ាងនោះ បៀវលែងតែវិញ្ញាណនៃព្រះវិណាស្រេចចេញ ។

មានបញ្ហាចោទទៀងថា ចុះសុគតិស្ថាននោះដូចម្ដេច? ទុគ្គតិស្ថាននោះដូចម្ដេច?

សុគតិស្ថានប្រែថា ស្ថានមានដំណើរស្រួល ទុគ្គតិស្ថានប្រែថា ស្ថានមានដំណើរតឹងពីបាក ដោយអំណាចការផ្សេងគ្នានៃផលកម្ម តែទោះជាយ៉ាងណា ក៏សត្វមិនអាចស្ទុះរួចពីកពប័បានឡើយ ប្រៀបដូចជាខ្លែងដែលបុគ្គលបង្ហើរឡើងអាកាស ខ្លែងនោះទីងត្រូវតែធ្លាក់មកលើផែនដីវិញជាប្រាកដ កាលណាអស់មានខ្យល់ទ្រ ហើយត្រូវតែហោះឡើងទៅទៀត កាលណាត្រឡប់មានខ្យល់មកវិញ ។

ព្រះពុទ្ធទេសនាថា តែមានជាតិ ត្រូវមានជរា ១ ត្រូវមានព្យាធិ ១ ត្រូវមានមរណៈ ១ តែទាំងបួននេះ មានជាធម្មតាក្នុងកពប័ ។

គេឧបមាទុកភពទាំងបី ដូចជាផ្ទះបីខ្នង មានសភាពផ្សេងពីគ្នាគឺផ្ទះទី ១ ធ្វើអំពីស្លឹក ផ្ទះទី ២ ធ្វើអំពីឈើប្រក់ក្បឿង ផ្ទះទី ៣ ធ្វើអំពីថ្ម ឬបេតុងអារម៉េ ហើយក្នុងផ្ទះនីមួយ ៗ សឹងមានមនុស្សម្នាក់អាស្រ័យនៅ ៗ

គេសួរថា តើមនុស្សទាំងបីនាក់ខាងលើនេះ មានការថ្លៃថ្នូរពិសេសជាងគ្នាបែបណាខ្លះ? បើម្នាក់ ១ សុទ្ធតែមានជាវយ៉ាងមុតព្យុះនៅទីងផញ្ចាំង រង់ចាំឲ្យតែដល់ពេលទីងគាត់កម្ចាស់ផ្ទះរៀងខ្លួន ៗ ត្រង់ចំណុច

នេះ ព្រះពុទ្ធទ្រង់ត្រាស់ថា មានដំណើរស្រួលនឹងដំណើរពិបាកប្លែកគ្នាខ្លះក៏ពិតមែន តែពោះបរិយុទ្ធបានសុខស្រួលមួយគ្រា ក៏គង់គ្រាក្រោយខ្លួននឹងត្រូវទៅជួបនឹងទុក្ខវិញជាមិនខាន ព្រោះវិញ្ញាណសត្វមិនមែនតាំងនៅជាស្ថាពរគង់គតនៅមួយ ៗ ឡើយ គឺជាសត្វដែលទៅសំចតនៅអរូបភពក្តី រូបភព ឬ កាមភពក្តី តែងតែត្រូវមរណសង្គ្រាមមកផ្តាច់ជីវិតន្ទ្រិយដូច ៗ គ្នាជាធម្មតា ។

ដូច្នេះ សម្រេចសេចក្តីថា ភពទាំងបី ឬ សង្សារវដ្តជាកន្លែងទុក្ខ ព្រោះមានធម៌បីគឺ អនិច្ចំ ទុក្ខំ អនត្តា ស្ថិតនៅជានិច្ច ។

មានបញ្ហាទៀតថា បើភពបីជាកន្លែងទុក្ខ ហេតុអ្វីក៏មានសត្វពេញចិត្តមកកើតច្រើនម៉្លេះ ? ហើយមុននឹងបញ្ចូលខ្លួនមកក្នុងត្រៃភព តើវិញ្ញាណជីវសត្វទាំងនោះ សំចត ឬ អាស្រ័យនៅស្ថានណា? ភពណា ឬភូមិណា ? សូមទុកដោះស្រាយចំណុចនេះដែលជាចំណុចធំទៅខាងមុខៗ

សួរថា វិញ្ញាណសត្វកាលបើមានហើយ នឹងអាចសាបសូន្យទៅវិញខ្លះ ដោយស្វ័យប្រវត្តិ ឬទេ ?

វិញ្ញាណនេះកែមានហើយ មិនងាយនឹងសាបសូន្យទៅវិញដោយឯកឯងទេឡើយ សូម្បីវិញ្ញាណសត្វយ៉ាងតូចឆ្មារ ដូចជាស្រមោចក៏ដោយ ៗ បើគេយករូបសត្វទៅសនប់ក្នុងត្បាល់កក់ ក្នុងរន្ធដីជ្រៅប៉ុន្មានក្តី ក្នុងធុងដែកផ្សារយ៉ាងជិតស្លួចប្រអប់គ្រែខក្តី រួចគេដុតក្លុងសម្លាប់វិញ្ញាណសត្វនឹង

វិនាសសាបសូន្យជាមួយឬទេ? ។ ឆ្លើយថា វិនាសតែរូប ចំណែកវិញ្ញាណមិនវិនាសសោះ ។ បើមិនវិនាសតើអាស្រ័យនៅទីណា ស្ទុះចេញទៅតាមណា ហេតុអ្វីក៏មិនឃើញ? ។ ឆ្លើយថា កាលបើរូបវិនាសហើយ វិញ្ញាណត្រូវស្ទុះទៅរករូបថ្មីទៀតជាធម្មតា តាមសមគួរដល់កំឡាំងផលកម្ម ដោយឥតមាននរណាអាចដឹងឮបានឡើយ ព្រោះវិញ្ញាណជាអរូបធម៌ ។

ចុះបើយ៉ាងដូច្នេះ គឺថាបើវិញ្ញាណមានហើយ ៗ នៅតែត្រាច់ផ្គាត់ក្នុងវដ្ដសង្សារ ដូចជាសត្វស្វាដែលបុគ្គលចងទុកក្នុងរោងមានបង្គោលបី ហេតុម្ដេចវិញ្ញាណថ្មីនោះ ដែលមិនទាន់ចូលមក ក៏ពេញចិត្តនាំគ្នាតាំងសែនតាំងកោដិម្ដងៗ មកចូលឲ្យជាប់ក្នុងលោកដូចជាត្រីជាប់ដុចធ្វើអ្វី? តាមធម្មតា តែកន្លែងណាមានទុក្ខ មានគ្រោះថ្នាក់ មានសោករោគភ័យ ឧបមាថា នៅស្រុកណាមានកើតអាសន្នរោគជាអាទិ៍ គេតែងតែជៀសវាងមិនទៅស្រុកនោះជាដាច់ខាត ព្រោះគេត្រូវការតែសេចក្ដីសុខ ។ ដំណើរហេតុយ៉ាងណា បានជាវិញ្ញាណថ្មីនេះតែងនាំគ្នាសម្រុកចូលមក តើមុននឹងចូលមកពុំបានដឹងថា ត្រៃភពជាកន្លែងទុក្ខឬទេ? ជាកន្លែងដែលសត្វចូលហើយ ត្រឡប់ថយចេញបានដោយលំបាកឬទេ? ។

មនុស្សទៅរុតត្រី ១ ខំស្ទុះត្រដររស្ទើរបាក់អង្រ្គុត ដើម្បីជៀសឲ្យផុតពីការវិនាស ដែលជាការណ៍ផ្ទុយនឹងពាក្យបចតាមអាកមតិបួកណាដែលថាត្រីសុខចិត្តជាទាខ្លួននឹងចំណីមនុស្ស ព្រោះពងកូនម្ដងមួយម៉ឺន ៗ កុំថា

ឡើយដល់ទៅត្រី សូម្បីតែមូស ឬសង្កើច ជាសត្វតូចល្អិត ក៏ភ័យនឹងសេចក្ដីស្លាប់ណាស់ដែរ ចូរយើងក្រឡេកមើល ! វាខំហើរនឹងខំរត់កាលណាវាឃើញមនុស្សដេញទះ ឬដេញញៀចវា ។ ចុះសត្វមមាចដែលនាំគ្នាចាំងរយចាំងពាន់ មកពុមភ្លើងចង្កៀង ហើយបានទទួលនូវសេចក្ដីអន្តរាយ តើបាណកសត្វនេះ ដឹងថាភ្លើងជាសត្រូវនឹងអាត្មាឬទេ? ត្រីស៊ីនុយដែលអ្នកនេសាទចងទៅនឹងសន្ទូច ហើយធ្លាក់ខ្លួនដល់សេចក្ដីស្លាប់ តើវាដឹងថា មានសន្ទូចពួននៅខាងក្នុងនុយឬទេ? ទារកបរិភោគលាមកខ្លួនឯងតើវាដឹងថា លាមកជាវត្ថុស្មោកគ្រោកឬទេ?

ឧទាហរណ៍ប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថា សេចក្ដីអន្តរាយឬសេចក្ដីទុក្ខវេទនាដូចពោលមកខាងលើ បណ្ដាលមកតែពីការមិនដឹងជាហេតុ ។ សារុបសេចក្ដីទៅឃើញថា សេចក្ដីទុក្ខទាំងពួងកើតមានឡើងដោយមានការមិនដឹងជាមេ ។

បើដូច្នេះ វិញ្ញាណចិត្តនៃសត្វ ដែលបោលសម្រុកមកក្នុងភពថ្មី ក៏មានការមិនដឹងជាហេតុដែរឬ ? នេះគឺជាការណ៍ពិតឥតកម្រែក ។ អ្វីជាការមិនដឹងដែលទុកជាមេក្លាងធំ ដែលជម្រុលវិញ្ញាណចិត្តនៃសត្វឲ្យមកចូលក្នុងដុំចតិត្រៃភព ? ការមិនដឹងនេះហៅថា អវិជ្ជា ។

ហេតុម្ដេច បានជាហៅទាត់ទុក អវិជ្ជា ជាមេបង្កវិញ្ញាណចិត្តនៃសត្វក្នុងត្រៃភព តើមានអ្វីនឹងបញ្ជាក់ទុកជាភស្តុតាង ?

ដើម្បីងាយស្រួលយល់នេះ សូមលើកយកបដិច្ចសមុប្បាទធម៌មក ថ្លែងបញ្ជាក់ជាកស្តុតាងដូចតទៅ តែសូមថ្លែងបដិច្ចសមុប្បាទធម៌បដិលោម ជាមុន ៖

"ការអស់សង្ឃឹម ការតូចចិត្ត ការខ្សឹកខ្សួល ការកន្ទក់កន្ទេញ សេចក្តីសោយសោក សេចក្តីស្លាប់ ការចាស់ជរា ការមានជម្ងឺដំកាត់ ទាំងនេះមកតែពីមានជាតិ គឺការកើត, បានជាមានជាតិ មកពីមានភព, បានជាមានភព មកពីមានឧបាទានគឺសេចក្តីប្រកាន់ជាប់ចិត្ត, បានជា មានឧបាទាន មកពីមានតណ្ហាគឺសេចក្តីត្រូវការ, បានជាមានតណ្ហា មកពី មានវេទនាគឺសេចក្តីដឹងអារម្មណ៍, បានជាមានវេទនា មកពីមានផស្សៈគឺ ការប៉ះពាល់, បានជាមានផស្សៈ មកពីមានអាយតនៈ គឺកន្លែងកើតអា-រម្មណ៍, បានជាមានអាយតនៈ មកពីមាននាមរូប, បានជាមាននាមរូប មកពីមានវិញ្ញាណ, បានជាមានវិញ្ញាណ មកពីមានសង្ខារ គឺការផ្សំផ្គុំធាតុ ជាការចាំបាច់ ដើម្បីឲ្យកើតបានជាសរីរៈ, បានជាមានសង្ខារ មកពីមាន អវិជ្ជា គឺជាការមិនដឹង" ។

បើថ្លែងបដិច្ចសមុប្បាទធម៌ ដោយអនុលោមវិញ គឺត្រូវកប់យក អវិជ្ជាជាដើមអាទិ៍ ដោយសន្ទើបដូចតទៅ :

"អវិជ្ជាជាបច្ច័យឲ្យមានសង្ខារ ១ ជាបច្ច័យឲ្យមានវិញ្ញាណ ១ ជា

បច្ច័យឲ្យមាននាមរូប ។ ល ។ ភពជាបច្ច័យឲ្យមានជាតិ ។ ជាបច្ច័យឲ្យមានជរា ព្យាធិ មរណៈ" ។

បើគេសួរថា តពីអវិជ្ជាទៅ ឬ ខាងដើមអវិជ្ជាមានអ្វីទៀត ?

ត្រង់ចំណុចនេះ អ្នកណាក៏មិនអាចឆ្លើយប្រាប់បានឡើយ ។ ចំពោះការដោះស្រាយបញ្ហាវិញ្ញាណសត្វគង់តែគត់ ព្រះសក្យមុនីគោតមបានទ្រង់លើកយកមកពិចារណា ជាអនុលោមនិងបដិលោម លើរតនបល្លង្កក្រោមដើមពោធិព្រឹក្ស នូវបដិច្ចសមុប្បាទធម៌ គឺធម៌ប្រស្រ័យទាក់ទងគ្នាដូចប្រវាក់ ដើម្បីស្រាវជ្រាវឲ្យឃើញពិតថា អ្វីជាបច្ច័យបណ្តាលមកពីហេតុអ្វី រួចទ្រង់ពិចារណាបណ្តោយទៅវិញថា អ្វីជាហេតុនាំឲ្យមានអ្វី ។ ជាអវសានទ្រង់សម្រេចព្រះទ័យថា ធម៌ដែលប្រស្រ័យគ្នា ដូចប្រវាក់នេះ គឺមានអវិជ្ជាជាមេគឺចប់ត្រឹមអវិជ្ជានេះឯង គ្មានអ្វីតទៅទៀត ពោះព្រះអង្គទ្រង់ពិចារណាឈ្វេចឈ្វៀងណា ក៏ទ្រង់ឃើញច្បាស់ថា អស់តែត្រឹមអវិជ្ជា គឺអវិជ្ជានេះហើយដែលជាមេដើមភាពបង្អស់ ។ ចំណែកវិញ្ញាណមុននឹងចូលមកកាន់លោក ស្ថិតនៅជាធាតុ ។

ដើម្បីឲ្យងាយយល់ថា ធម៌ប្រវាក់នេះ មានការប្រទាក់គ្នាបែបណា ហើយពាល់អស់ត្រឹមអវិជ្ជានោះដូចម្តេច សូមលើកឧទាហរណ៍ជាសេចក្តីឧបមាជូនដាដំណើរដូចតទៅ :

ដំណាលថា មានមួយថ្ងៃ សត្វកុកស្ទុះទៅជាន់កូនក្រួចស្លាប់ ៗ មេក្រួចក្ដៅក្រហាយមិនសុខចិត្ត ក៏ទៅប្ដឹងគ័ង្គក់ឲ្យជំនុំជំរះរឿងស្លាប់កូនខ្លួន ៗ ក្នុងសម័យនោះ មិនដឹងជាសត្វណា តាំងគ័ង្គក់ឲ្យធ្វើជាចៅក្រមទេ ស្រាប់តែសត្វគម្រាតនេះមានអំណាចកោះហៅឲ្យកុកចូលមក ហើយសួរថា :

- ហេតុម្ដេចបានជាកុកឯង ស្ទុះទៅជាន់កូនក្រួចស្លាប់ ?

កុកឆ្លើយថា :

- បានជាខ្ញុំបាទស្ទុះទៅជាន់ ព្រោះភ័យនឹងអាអ្ហូតស្រែករគ្ហូក ៗ

គ័ង្គក់ឲ្យកោះហៅអាអ្ហូតមកសួរទៀតថា :

- អាអ្ហូតឯង ហេតុអ្វីក៏ស្រែករគ្ហូក ពាល់តែកុកភ័យស្ទុះទៅជាន់កូនក្រួចស្លាប់ ?

- បានជាខ្ញុំបាទស្រែករគ្ហូក ព្រោះឮមាន់ទឹកស្រែករគ្រេក ៗ

គ័ង្គក់ឲ្យកោះហៅមាន់ទឹកមកសួរទៀតថា :

- មាន់ទឹកឯង ហេតុអ្វីក៏ស្រែករគ្រេក នាំឲ្យអាអ្ហូតស្រែករគ្ហូក ?

- បានជាខ្ញុំបាទស្រែករគ្រេក ព្រោះឃើញក្រសារហូតដារ ៗ

- ក្រសារឯង ហេតុអ្វីក៏ហូតដារ នាំឲ្យមាន់ទឹកភ័យស្រែករគ្រេក ?

- បានជាខ្ញុំបាទហូតដារ ព្រោះឃើញទុំងលយសំពៅ ៗ

– ទុនឯង ហេតុអ្វីក៏លយសំពៅ នាំឲ្យក្រសារហូតដាវ ?

– បានជាខ្ញុំបាទលយសំពៅ ព្រោះឃើញត្រដក់ស្ពាយយាម ។

– ត្រដក់ឯង ហេតុអ្វីក៏ពៅស្ពាយយាម នាំឲ្យទុងលយសំពៅ ?

លុះពុគ័ន្តក់សួរអំពីង ត្រដក់នៅស្ងៀម ធ្វើក្បាលងើងើ ។ មិនដឹងឆ្លើយដូចម្ដេច ព្រោះយាមនេះ វាស្ពាយជាកេរ្តិ៍តពីដូនតាមក គ្មានមកពីហេតុអ្វី ដែលនាំឲ្យវាស្ពាយឡើយ ។ កាលបើសួរម្ដងជាពីរដងជាបីដង ត្រដក់នៅតែស្ងៀម ទើបគ័ន្តក់ប្រកាសកាត់ទោសចំពោះត្រដក់ ថាជាមេដើមចមនៃការស្លាប់កូនក្រួច រួចគ័ន្តក់លោតថង់ក្បាលត្រដក់ជ្រុះពេមអស់គ្មានសល់ បានជាក្បាលត្រដក់ទំពែករហូតមកដល់សព្វថ្ងៃ ។

ឧទាហរណ៍គួរអស់សំណើច ដែលខ្ញុំទាញមកថ្លែងជាសេចក្ដីឧបមានេះ បង្ហាញឲ្យយល់ថា វិញ្ញាណចិត្តរបស់សត្វមានអវិជ្ជាជាមេ មិនមានអ្វីជាហេតុតពៅទៀតទេ ដូចជាសេចក្ដីស្លាប់នៃកូនក្រួច មានត្រដក់ជាហេតុដំបូងដូច្នោះ ។ ចំណែកការពិចារណាបដិច្ចសមុប្បាទធម៌ នៃព្រះសម្ពុទ្ធក៏យ៉ាងនោះដែរ ព្រះអង្គទ្រង់ដញ្ញឹងដោយព្រះបញ្ញាញាណដ៏ក្លៀវក្លាងពៅ ទ្រង់យល់ច្បាស់ថាគ្មានអ្វីជាហេតុតពីអវិជ្ជាពៅទៀតទេ ទើបព្រះបរមគ្រូទ្រង់សម្រេចព្រះទ័យថា ធម៌ប្រទាក់គ្នាដូចច្រវាក់នេះ មានអវិជ្ជា ជាមេដើមចម គឺថាការមិនដឹងនេះឯងហើយ ដែលជាហេតុបណ្ដាលឲ្យកើតវិញ្ញាណសត្វក្នុងត្រៃភពជាកន្លែងទុក្ខ ។

សារុបសេចក្តីទៅ ឃើញថា អវិជ្ជា មានន័យថាមិនដឹង អវិជ្ជា ជាកត្តាបង្កវិញ្ញាណថ្មីនៃសត្វកើតតៗ តែមានសត្វហើយត្រូវតែមានទុក្ខ ព្រោះសត្វជាទុក្ខ ។ ជាសត្វ ហើយកន្លែងដែលសម្រាប់សត្វសំចតក៏ជាទុក្ខទៀត ដូចបានពណ៌នាមកពីខាងលើរួចមកហើយ ។

ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់ថា តើសត្វពិតជាទុក្ខមែនឬ ? សូមលើកយកសច្ចៈទាំងបួនមកអធិប្បាយ ជាគ្រឿងនិទស្សន៍ដូចតទៅ :

សច្ចៈ ប្រែថា សេចក្តីពិតដែលមានក្នុងលោក ហើយដែលមិនប្រែក្លាយទៅជាប្រការដទៃ ។ សច្ចៈនេះ ព្រះសម្ពុទ្ធទ្រង់ជ្រាបច្បាស់មុនគេបង្អស់ ។ ឯសច្ចៈទាំងបួនគឺ ១- ទុក្ខសច្ចៈ ប្រែថា ទុក្ខជាសេចក្តីពិត, ២- សមុទយសច្ចៈ ប្រែថា ហេតុបណ្តាលឲ្យកើតទុក្ខ (តណ្ហា) ជាសេចក្តីពិត, ៣- និរោធសច្ចៈ ប្រែថា ស្ថានរលត់ទុក្ខ (ព្រះនិព្វាន) ជាសេចក្តីពិត, ៤- មគ្គសច្ចៈ ប្រែថា ផ្លូវប្រតិបត្តិ ដើម្បីរំលត់ទុក្ខជាសេចក្តីពិត ។

ទុក្ខជាសេចក្តីពិតក្នុងលោកនោះដូចម្តេច ?

តាំងពីថ្ងៃដែលសត្វមកចាប់បដិសន្ធិ រហូតដល់ថ្ងៃប្រសូត សត្វទទួលទុក្ខវេទនាជាដរាប ។ សូមពិចារណាមើល! ការអាស្រ័យនៅក្នុងទីដ៏ចង្អៀតយ៉ាងក្រៃលែងគឺផ្ទៃមាតានេះ ជាសុខស្រួល ឬជាការលំបាក ? បើគេលុងឈើ ឬធ្វើលូឲ្យល្មមចុះតែមនុស្សម្នាក់ ហើយគេបញ្ជ្រូក

មនុស្សទៅក្នុងនោះ គេអាចស្មានបានថា មិនមានការសុខស្រួលឡើយ ឯសត្វនៅក្នុងផ្ទៃម្តាយក៏មានសភាពដូច្នោះដែរ ។

គេអាចពោលបានថា ការអាស្រ័យនៅនៃសត្វក្នុងផ្ទៃម្តាយ ជាការធម្មតា ៗ ចម្លើយនេះ ជាការសមរម្យម្យ៉ាងដែរ ព្រោះបើមិនមែនជាការធម្មតា ធ្វើដូចម្តេចនឹងមានសត្វរស់ពេញលោក ។ តែដែលយល់ថាជាការធម្មតានេះ កើតមានចំពោះតែសត្វដែលប្រាសចាកបញ្ញាទេ ចំណែកព្រះអរិយបុគ្គលវិញ លោកភ័យខ្លាចនឹងខ្ពើមរអើម រកអ្វីឧបមាគ្មាន ៗ រឿងនេះ មិនខុសគ្នាពីដង្កូវនៅក្នុងបង្គន់ទេ ត្រង់ដង្កូវខ្លួនឯងចូលចិត្តនឹងពេញចិត្តថា ការអាស្រ័យនៅក្នុងបង្គន់ ហើយបរិភោគលាមកកល់ថ្ងៃជាអាហារ ជាការគាប់ប្រសើរនៃអាត្មា តែបើឲ្យមនុស្សបញ្ចេញយោបល់ចំពោះបញ្ហានេះវិញ គេអាចទាយទុកមុនជាស្រេចថា ១០០/១០០ ពិតជាថាមិនស្រួល មិនប្រពៃ ជាការស្មោកគ្រោករកអ្វីផ្ទឹមពុំបាន ត្រូវតែដកខ្លួនថយចេញឲ្យឆ្ងាយយ៉ាងដាច់រហ័សជាទីបំផុត ។

ចាប់ពីថ្ងៃសម្រាលចេញពីផ្ទៃម្តាយ សត្វតែងរងទុក្ខវេទនារហូតដល់ម៉ោងស្លាប់ ។ តើរងទុក្ខរបៀបណា ? ។ គេអាចដំពាស់បានថា បើថាសត្វទទួលតែទុក្ខយ៉ាងនេះ ស មក្នុងលោកគ្មានសត្វឡើយ នេះជាការផ្ទុយទៅវិញ គេឃើញសត្វមានចំនួនកាន់តែច្រើនឡើង ។ ហើយសើច

ញញឹមនឹងសប្បាយរីករាយចំពោះការរស់នៅក្នុងលោក ។ ចំណែកទីសំណាក់អាស្រ័យក៏ប្រែទម្រង់ស្ទើររាល់ថ្ងៃ គឺប្រែពីអាក្រក់ទៅល្អ ពីមិនស្រួលទៅជាស្រួល ពីមិនសមរម្យទៅសមរម្យ ពីតូចទៅធំ ពីទាបទៅខ្ពស់ ពីចង្អៀតទៅទូលាយ ពីក្រខ្វក់ទៅស្អាត ។ល។ មធ្យោបាយដឹកនាំទៀតក៏ប្រសើរប្លែក ដែលពីដើមយើងធ្លាប់ឮតែក្នុងរឿងព្រេង ទាំងអាហារសម្រាប់បរិភោគព្រមទាំងសំលៀកបំពាក់ នឹងគ្រឿងសំអាងកាយមិនឃ្លាតឆ្ងាយពីទេពនិម្មិតឡើយ បើយ៉ាងនេះ តើត្រង់កន្លែងណាដែលនឹងនិទស្សន៍ឲ្យឃើញច្បាស់ថា សត្វទៅជារងទុក្ខវេទនាជានិច្ចនោះ ? ។

ត្រង់ចំណុចនេះ ឃើញថាហាក់ដូចជាអឺចឹងមែន ប៉ុន្តែការមែននេះកើតមានដល់តែពួកសមញ្ញបុថុជ្ជន ដែលប្រាសចាកការពិចារណាឲ្យជិតដល់ទេ ។ ហេតុអ្វីក៏ថាដូច្នេះ ? ថារឿងខាងលើនេះជាការចំរើនត្រដរនៃសត្វទេតើ ព្រោះថាទុក្ខពេក ជាការមិនបណ្ដោយ ជាការមិនអស់សង្ឃឹម ដ្បិតទុក្ខសច្ចៈពុំដែលកើតជាក់ច្បាស់ដល់ទឹកចិត្តនៃសត្វសាមញ្ញទេ មានកើតខ្លះដែរ តែដោយពេលដោយខណៈ ដូចជាផ្លេកបន្ទោរប៉ុណ្ណោះ ហើយសត្វក៏នឹកស្មានថា មិនមែនជាទុក្ខសច្ចៈផង ម្ល៉ោះហើយសេចក្ដីត្រូវការរកសុខ រុញច្រានដោយជម្រុលទឹកចិត្តសត្វកុំឲ្យនៅស្ងៀម កុំឲ្យខ្ជិល កុំឲ្យធ្វើព្រងើយ ដ្បិតការទាំងនេះ តាមលោកភាសិតថា ត្រឡប់ជាឲ្យទុក្ខដល់អាត្មាវិញ ហើយបើមិនពិចារណាឲ្យជ្រៅ ក៏ហាក់

ដូចជាការពិតអីចឹងមែនដែរ ព្រោះចលនានៃកងកាយនឹងចិត្ត នាំឲ្យភ្លេចគិតដល់សេចក្ដីទុក្ខមែន ដោយចិត្តអាល័យតែជាប់ជំពាក់កងការងារ តែបើពិចារណាបន្តិចទៅទៀត ឃើញថា ចលនានៃកងកាយនឹងចិត្តនេះ ក៏ជាទុក្ខ ព្រោះដូចពាក្យចាស់ទៀមថា «មួយដំបងនឹងបួន» ទេ ។ ទុក្ខខាងក្រៅមិនមកប៉ះពាល់មែន តែការធ្វើបែកញើស ការអង្គុយគិតកប់មោង ការនិយាយស្ដីអស់រយៈពេលដ៏យូរ ការរំព្រើងអត់ងងុយ ។ល។ តើទុកជាអ្វីទៅវិញ? ។

ម្យ៉ាងទៀត ចំពោះបញ្ហាខាងលើនេះ មានអ្នកប្រាជ្ញភាគច្រើនក្នុងលោក ទោះជាខាងពុទ្ធសាសនាក្ដី ខាងវិទ្យាសាស្ត្រក្ដី ខាងប្រាកដនិយមក្ដី តែងជួយដោះស្រាយបញ្ហាទុក្ខឲ្យសត្វ ដោយប្រើមធ្យោបាយខាងការពោលលួងលោមនឹងកម្ទេចចិត្តជាការថ្ងូរ ការត្អូញត្អែរ ការកន្ទក់កន្ទេញ ការយំសោកសង្រេងសង្រែ ការអស់សង្ឃឹម ការព្រួយចិត្ត ការអាឡោះអាល័យ ទាំងនេះជាអំពើឥតប្រយោជន៍ ជាអំពើកំសាក ដែលជាហេតុគ្រាន់តែធ្វើឲ្យអាក់ដំណើរអាត្មាប៉ុណ្ណោះ រកលទ្ធផលល្អគ្មាន ប្រៀបបាននឹងអ្នកដំណើរ ដែលកំពុងគ្រាច់ចរកណ្ដាលកន្តារៈ ឬ អុំទូកកណ្ដាលសមុទ្ទ ហើយពោលត្អូញត្អែរអំពីការស្រេកឃ្លាន ការក្ដៅក្រហាយ ការភ័យស្រពាន់ ការអស់កំឡាំង នឹងការនឿយហត់ ឯការពោលដូច្នេះ តើ

ទឹងជូនលទ្ធផលគាប់ប្រសើរដល់អាត្មាឬទេ? បើខ្ញុំមានការចាំបាច់ត្រូវតែបន្តដំណើរទៅទៀតដដែល ៗ ហើយចំពោះសមិទ្ធិនៃសត្វទាំងនេះ តើអ្នកណាអាចកំណត់បានថា ទឹងក្ដទៅពេលណាមួយឬទេ? មែនពិត បើយកក្ដីដោយសន្មត នោះទឹងអាចមានបានខ្លះ តែបើយកក្ដីតាមការពិត ឃើញថាឥតអង្គីមានឡើយ ព្រោះធម៌អនិច្ចំ ឥតប្រែក្លាយទៅជាប្រការដទៃទេ ។

ក្នុងលោក ជីវិតជាទុក្ខតែម្ដង ៗ ព្រះពុទ្ធសំដែងថា: "កិច្ឆំ មច្ចាន ជីវិតំ ប្រែថា ការរស់នៅនៃសត្វទាំងឡាយជាការលំបាក" ។ ភាសិតអ្នកប្រាជ្ញខាងលោកនិយម ក៏មានន័យស្របគ្នាទឹងពុទ្ធភាសិតដែរ : គេពោលថា: (La vie est une lutte) ប្រែថា ជីវិតជាការប្រយុទ្ធ ។ ក្នុងពាក្យ "ប្រយុទ្ធ" គឺមានការតស៊ូ មានបរាជ័យ ទឹង អបរាជ័យជាធម្មតា ។ ចុះបើយ៉ាងនេះ តើទឹងអាចកំណត់ទុកជីវិត ជាការសប្បាយជាការស្រួលឬជាទុក្ខ? ចម្បាំងធម្មតា តែងមានពេលក្ដ តែងមានពេលចប់ ចំណែកចម្បាំងគឺជីវិតសត្វ ជាចម្បាំងដ៏ធំក្រៃលែងលើសចម្បាំងនានាជាចម្បាំងមិនមានពេលសម្រាកទឹងរកឲ្យបំផុតគ្មាន ។

លោកប៊ែរណាដាំងដឺសាំងព្យែរ (Bernadain de Saint Pierre) អ្នកនិពន្ធជាតិបារាំងនៃសៀវភៅប្រលោមលោកៈឈ្មោះ "ប៉ូលអេវីហ្ស៊ីនី" (Paul et Virginie) ពោលថា: "សេចក្ដីស្លាប់ជាការរំដោះទុក្ខ" សំដី

នេះបញ្ជាក់បន្ថែមលើយោបល់ខាងលើដែលថា ជីវិតជាសេចក្តីទុក្ខ ព្រោះបើមរណៈជាការរំដោះទុក្ខ ជីវិតពិតជាទុក្ខពិតប្រាកដដោយស្វ័យប្រវត្តិ ។

តើជីវិតជាទុក្ខបែបណា ?

ព្រះពុទ្ធទេសនាថា: " ជិឃច្ឆា បរមា រោគា ប្រែថា ការស្រេកឃ្លានជារោគដ៏ធំក្រៃលែងជាងរោគទាំងឡាយ " ។

តាំងពីប្រសូតចេញមក សត្វត្រូវទទួលទានដរាបអវសានជីវិត ។-តាមសភាពប្រក្រតី អាហារជាគ្រឿងឧបត្ថម្ភខានពុំបានដល់ជីវិត អ្វីដទៃទុក្ខជាគ្រឿងបន្ទាប់បន្សំពីអាហារទាំងអស់ ។ ដូច្នេះហើយ ទើបគេតែងឮបន្តិចពីទីនេះ បន្តិចពីទីនោះ ក្នុងសាកលលោក នូវការធ្វើឃាតកម្ម កូដកម្ម វាយប្រហារ ចម្បាំង ទាំងនេះមិនមែនមានហេតុអ្វីក្រៅពីដណ្តើមគ្នារស់ឲ្យបានស្រួល បន្តិចតែប៉ុណ្ណោះ ព្រោះមានជនពួកខ្លះ ដោយអាងមានឫទ្ធិអំណាចជាងគេដណ្តើមយករស់តែម្នាក់ឯង ។ ឯអ្នកខ្លះទៀតពុំបានធ្វើអ្វីនឹងគេ មកពីខ្វះមធ្យោបាយ ឬមកពីពាលគំនិត ហើយក៏បណ្តោយដំណើរជីវិតឲ្យប្រព្រឹត្តទៅតាមយថាកម្ម ។

ចំណែក ជរា ព្យាធិ ព្រមទាំងការណ៍អ្វីផ្សេង គឺជាសេចក្តីទុក្ខបន្ទាប់ពីជីវិត ។

សេចក្ដីដូចពោលរៀបរាប់មកនេះ បញ្ជាក់ឲ្យឃើញច្បាស់ នូវទុក្ខសច្ចៈ ថាពិតជាមានប្រាកដក្នុងលោក ហើយមិនមានក្នុងទីណាក្រៅពីក្នុងលោកឡើយ ។

សមុទយសច្ចៈ សេចក្ដីពិតចំពោះហេតុដែលបណ្ដាលឲ្យមានទុក្ខនោះដូចម្ដេច?

ត្រង់នេះ គឺសំដៅយក តណ្ហា ជា សមុទយសច្ចៈ ។ អ្វីហៅតណ្ហា មានន័យដូចម្ដេច?

តណ្ហា ប្រែថា សេចក្ដីត្រូវការ ។ គឺសេចក្ដីត្រូវការចង់រស់នេះ ហើយដែលបណ្ដាលឲ្យមានទុក្ខ ។

សួរថា ចុះបើគេមិនត្រូវការ គេមានគ្រប់គ្រាន់អស់ហើយ តើនឹងមានអ្វីនាំឲ្យគេមានទុក្ខ?

បើពោលដូច្នេះ សមុទយសច្ចៈហាក់ដូចជាមិនមានក្នុងលោក បើសច្ចៈទី២ នេះគ្មានហើយ សច្ចៈទីមួយ ត្រូវតែស្ថិតនៅជាអហោសិកម្មចំពោះអ្នកនោះ ។

សូមពិនិត្យមើលសិន តើមនុស្សណា ឬសត្វណាដែលមិនត្រូវការចង់រស់ ដែលពោលថា អាត្មាអញគ្រប់គ្រាន់ហើយ?

តាមការសង្កេតយ៉ាងហ្មត់ចត់ ឃើញថាគ្មានសត្វណាមួយដែលមិន

ចង់រស់ ដែលផ្អែកឯង ព្រោះតាប់បើកភ្នែកឡើងនៅគ្រប់ផ្ទះ ឃើញតែផ្សែងហុយទ្រលោម បើមានផ្ទះខ្លះឥតហុយផ្សែង នោះអ្នកម្ចាស់គង់តែរត់ទៅរកផ្ទះដែលមានផ្សែងហុយជាពុំខាន ដែលថានឹងស៊ូដេកត្រាំអត់គឺពិតជាមិនមាន កុំថាឡើយអ្នកជាត្រឹមត្រូវ សូម្បីអ្នកវិកលវិការ ក៏គង់តែស្ទុះស្ទាទៅរករស់នឹងគេដែរ ដោយមធ្យោបាយផ្សេងៗ មានការដើរសុំទានជាដើម ។ បើការចង់រស់មានហើយ សេចក្តីត្រូវការផ្សេងដទៃរមែងរត់មកកើមពីខ្លួនឯង ៗ ជាធម្មតា ដូចជាលោហជាតិ រត់ទៅតាមកើមមេដែកដូច្នោះ ។

គេអាចដណ្តឹងសួរថា: មានមនុស្សខ្លះសម្លាប់ខ្លួនឯង ដោយមធ្យោ-បាយប្លែកៗ មានការចងកជាដើម តើនឹងចាត់ទុកមនុស្សនោះជាអ្នកចង់រស់ដែរឬឬ ?

ចំពោះចំណោទនេះ គួរឲ្យពិចារណាដែរ បើគ្រប់សត្វតែងមានតណ្ហាគឺសេចក្តីត្រូវការ មានការចង់រស់ជាអាទិ៍ តើដោយប្រការម្តេចអ្នកនោះត្រឡប់ជាសម្លាប់អាត្មាទៅវិញ ហាក់ដូចជាផ្ទុយស្រឡះនឹងគោលសច្ចៈ ។

ចំពោះរឿងដែលចោទមកនេះគឺងាយសោះ ៗ អ្នកធ្វើអត្តវិនិបាតកម្មមានតណ្ហាយ៉ាងខ្លាំងក្លា គឺត្រូវការចង់រស់ជាងអ្នកដទៃដ៏លើសលុបតែដោយ

ការចង់រស់នោះមិនបានសម្រេចដូចចិត្តប៉ុនប៉ង ក៏គិតកាន់មហិមាថា ការទៅរស់ក្នុងអនាគតជាតិប្រហែលប្រសើរជាងជីវិតបច្ចុប្បន្នរបស់ខ្លួន ម៉្លោះហើយក៏ដាច់ចិត្តធ្វើអត្តវិនិបាតកម្ម ដោយមកពីត្រូវការចង់រស់ឲ្យបានធូរស្រាលទេតើ ព្រោះការរស់ក្នុងជាតិនេះជាការតឹងពេក ៗ រឿងនេះមិនខុសគ្នាប៉ុន្មានពីមនុស្សដែលដាច់ចិត្តដកខ្លួនថយចេញពីស្រុកកំណើតមាតុជាប្រទេសដែលអ្នកណាក៏តែងតែចង់នៅរួមសុខទុក្ខជាមួយមាតាបិតា និងញាតិសាច់សាលោហិត នរណាក៏តែងរលឹកនឹងស្រឡាញ់រកអ្វីប្រៀបគ្មាន តែដែលបានជាដាច់ចិត្តដើរចោល មកពីមានការគានតឹងទ្រាំពុំបានហើយ សង្ឃឹមថា សេចក្ដីត្រូវការរបស់ខ្លួន នឹងបានសម្រេចដូចបំណង បើកាលណាអាត្មាដកខ្លួនទៅទីដទៃ ៗ

ដូច្នេះតណ្ហាគឺសេចក្ដីត្រូវការ តែងមានក្នុងសន្ដានសត្វគ្រប់គ្នា ហើយសេចក្ដីទុក្ខធ្ងន់ស្រាលដែលកើតមានដល់សត្វ ក៏អាស្រ័យតែពីតណ្ហាធំឬតូចប៉ុណ្ណោះឯង ៗ បើសត្វណាមានតណ្ហាធំ ទុក្ខក៏ធ្ងន់ បើសត្វណាមានតណ្ហាតូច ទុក្ខក៏ស្រាល តែថាឲ្យប្រាសចាកផុតពីតណ្ហាគឺឥតមានឡើយ ហើយតណ្ហានេះ អាចពង្រីកទៅរកត្រាំដែនគ្មាន បើបណ្ដោយឲ្យវាប្រព្រឹត្តទៅតាមអំពើចិត្ត ៗ

សុភាសិតថែងថា : " តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ប្រែថា ការសោកសង្រេងសង្រៃ កើតមកតែពីសេចក្តីត្រូវការ ការភ័យខ្លាច ក៏កើតមកតែពីសេចក្តីត្រូវការ បើសេចក្តីត្រូវការសូន្យហើយ ការសោកក្តី ការភ័យខ្លាចក្តី នឹងមានមកពីណា " ។

ពុទ្ធភាសិតនេះចង្អុលឲ្យឃើញថា តណ្ហានឹងទុក្ខ ពិតជាមានក្នុងលោកនឹងពិតជាមាននៅក្នុងសន្តានសត្វគ្រប់ប្រាណ តែសត្វនោះឥតបានយល់ បានស្គាល់ដ៏ជាក់ច្បាស់ទេ មានតែពួកព្រះអរិយៈទើបលោកជ្រាបច្បាស់ដោយបញ្ញាចក្ខុរបស់លោក ឯសត្វវិញដឹងតែពីចង់រស់ ថ្ងូរត្អូញ ត្អូរ ស្រែកយំ . . . . ប៉ុណ្ណោះ ។

ជាអវសាន សូមសាទៅបញ្ជាក់នូវសច្ចៈទាំងពីរម្តងទៀត ។ ឯសច្ចៈទី ៣ គឺនិរោធសច្ចៈ នឹងសច្ចៈទី ៤ គឺមគ្គសច្ចៈ ពុំបានលើកយកមកអធិប្បាយក្នុងទីនេះទេ ព្រោះមិនមានការសំខាន់ដល់អត្ថបទនេះ ។

ដោយទុក្ខសច្ចៈនឹងសមុទយសច្ចៈ ជាសេចក្តីពិតដែលមានក្នុងលោក ទើបត្រូវទុកលោកឬភពជាកន្លែងទុក្ខ ។ ឯការមិនដឹងគឺ អវិជ្ជា ពិតជាមេដើមចមនៃសេចក្តីទុក្ខរបស់សត្វ ព្រោះ អវិជ្ជា មេបង្កវិញ្ញាណចាំនៃសត្វ បញ្ចូលមកក្នុងត្រៃភព ដូចដែលបានពណ៌នាមកហើយនោះ ។

លោកុត្តរាភិសម័យ

ភាគទី ៥

អ្នកឧកញ៉ា ឆា-សាង អតីតរដ្ឋមន្ត្រីរៀបរៀង

(តចប់)

## ត្រៃលោក និង ត្រៃភព

តើត្រៃលោក ដែលព្រះអរហន្តលោកឆ្លងចេញរួចផុតស្រឡះនោះ ជាឋានដទៃផ្សេងពីត្រៃភព គឺភព ៣ ដែលព្រះអរហន្តអង្គនោះ លែងត្រឡប់មក វិលកើតវិលស្លាប់ទៀតឬដូចម្ដេច ?

ចំពោះសំនួរនេះ ខ្ញុំសូមជំរាបថា ឯឋានទាំងឡាយដែលបណ្ឌិតលោកសន្មតហៅថា ត្រៃលោកក្ដី ឬហៅថាត្រៃភពក្ដី គឺជាឋានដដែល មិនមែនជាឋានផ្សេងដាច់ដោយឡែកពីគ្នាឡើយ ដោយបណ្ឌិតលោកគ្រាន់តែរួមឋាននរកស្ថិតនៅខាងក្រោមមនុស្សលោក និងឋានសួគ៌ក្នុងទេវលោក ហើយសន្មតហៅថា កាមភព និងបែងចែកព្រហ្មលោកធ្វើជាភព ២ ទៀត គឺយកឋានព្រហ្មដែលមានរូបធ្វើជារូបភព ហើយយកឋានព្រហ្មដែលគ្មានរូប ធ្វើជាអរូបភពតែប៉ុណ្ណោះទេ ។

រីឯឋានទាំងឡាយនោះបានជាម្ដងហៅថាត្រៃលោក, ហើយម្ដងត្រូវហៅថា ត្រៃភពវិញនោះ ពីព្រោះកាលបើលោកពោលថា ត្រៃលោក

គឺគ្រាន់តែសំគាល់ឋានទាំងឡាយនោះ ថាជាលោកគឺជាទីអាស្រ័យនៅនៃសត្វលោក ដូចជាមនុស្សលោក គឺជាទីសំណាក់អាស្រ័យនៅនៃមនុស្ស ៗលៗ ហើយកាលបើលោកពោលថា ត្រៃគតិវិញ គឺគ្រាន់តែសំគាល់ឋានទាំងឡាយនោះថាជាគតិ គឺជាទីសម្រាប់ឲ្យសត្វអន្ទោលវិលកើតវិលស្លាប់ តាមយថាកម្មរបស់ខ្លួនតែប៉ុណ្ណោះទេ ។

បើគតិមានតែ ៣ ហៅថាត្រៃគតិ តើទុគ្គតិគតិនិងសុគតិគតិនោះជាគតិដោយឡែកផ្សេងពីត្រៃគតិនោះទៀត ឬដូចម្ដេច ?

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា ទុគ្គតិគតិនិងសុគតិគតិនោះគឺ កាម.គតិនោះឯង មិនមែនជាគតិដទៃផ្សេងពីកាមគតិនោះឡើយ ពីព្រោះទុគ្គតិ-គតិគឺសំដៅអបាយភូមិ ៤ មាននរកជាដើម ហើយសុគតិគតិគឺសំដៅឋានសួគ៌ ៦ ជាន់នោះ ។

មួយវិញទៀត. បើលោកមានតែ ៣ ហៅថា ត្រៃលោកនោះ តើបរលោកនោះជាលោកផ្សេងពីត្រៃលោកទៀត ឬដូចម្ដេច ?

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា បរលោកនោះមិនមែនលោកឯណាក្រៅផ្សេងពីត្រៃលោកនោះទេ, ពីព្រោះបរលោកដែលប្រែថា លោកខាងមុខ ជាគូនឹងឥធលោកដែលប្រែថា លោកនេះ តែប៉ុណ្ណោះឯង ។

ឯបរលោកគឺលោកខាងមុខនោះ គឺសំដៅទុគ្គតិគតិ ដែលតាំងនៅខាងក្រោមមនុស្សលោក និងសុគតិគតិ ដែលតាំងនៅលើទេវលោកនោះ

ឯង ពីព្រោះសត្វដែលស្លាប់ពីឋានកណ្តាល រមែងទៅចាប់បដិសន្ធិកើតក្នុងសុគតិភព ឬទុគ្គតិភពតាមកម្លាំងបុណ្យឬបាបដែលសត្វនោះបានធ្វើដោយកាយវាចាចិត្តនោះ ។

រីឯទុគ្គតិភព និងសុគតិភពដូចបានអធិប្បាយខាងលើនេះមានស្ថានភាពដូចម្តេចខ្លះនោះ ខ្ញុំនឹងបរិយាយរៀបរាប់តាមដែលខ្ញុំបានដឹងខ្លះដូចតទៅនេះ :

## ១- អំពីទុគ្គតិភព

ឯទុគ្គតិភព គឺភពដែលជាទីកើតនៃសត្វដែលមានគតិអាក្រក់ គឺសត្វដែលបានធ្វើនូវអំពើបាបផ្សេង ៗ ។

ឯទុគ្គតិភពនេះ គឺសំដៅអបាយភូមិ ៤ គឺនរក, ប្រេត, អសុរកាយ និងតិរច្ឆាន ។ ឯនរកជាឋាន ១ ស្ថិតនៅឯបាតាល គឺលោកខាងក្រោម មានរណ្តៅជាទីលំនៅនៃសត្វនរក នៅទទួលរងទុក្ខទោសតាមផលបាបកម្មធ្ងន់ ឬស្រាលដែលខ្លួនបានធ្វើ ដោយហេតុនេះ ទើបរណ្តៅនរកមាន ៨ គឺ: ១- សញ្ជីវៈ ២- កាលសុត្តៈ ៣- សង្ឃាដៈ ៤- រោរុវៈ ៥- មហារោរុវៈ ៦- តាបៈ ៧- មហាតាបៈ ៨- អវីចិ ។

ឯឋាននរកនោះមានទិដ្ឋានខ្លះថា មាននាយនិរយបាលចាំធ្វើទណ្ឌកម្មផ្សេង ៗ មានតាប់ភ្លើងជាដើម ដើម្បីឲ្យសត្វនរកបានសេចក្តីលំបាកវេទនាក្តៅក្រហាយខ្លោចផ្សា ស្លាប់កើត ៗ ស្លាប់ក្នុងរណ្តៅនរកនោះឯង ។

រីឯភូមិនៃប្រេត, អសុរកាយ នឹងតិរច្ឆានវិញនោះ ឃើញមានទៅលាយឡំតែជាមួយនឹងមនុស្សក្នុងឋានកណ្ដាល ។

ឯប្រេតនោះ គឺសំដៅខ្មោចដែលពីដើមធ្លាប់កើតជាមនុស្សបានធ្វើអំពើបាបដែលវិបាកមិនគម្រប់ឲ្យធ្លាក់ទៅសោយទុក្ខក្នុងនរកនោះ ។ ឯប្រេតនោះមាននិទានថា មានរូបកាយអាក្រក់, មានជីវភាពរហេមរហាមយ៉ាងក្រៃលែង, តែមិនបេះលងមនុស្សដូចខ្មោចឯទៀត ។

រីឯពួកអសុរកាយ, មានព្រាយអាកាស, នឹងខ្មោចអារក្សជាដើម ក៏មានជីវភាពរហេមរហាម ហើយមានខ្មោចព្រាយខ្លះដើរក្នុងពេលយប់ស្វែងរកអសុចិវត្ថុ មានគំរង់ជាដើម លិទ្ធជញ្ជក់យករសជាតិគំរង់ជាអាហារ ។

ចំណែកឯសត្វតិរច្ឆាន ទោះបីកើតជាសត្វអ្វីក៏ដោយ សុទ្ធតែត្រូវទទួលទុក្ខវេទនាទាំងអស់, ខ្ញុំមិនចាំបាច់ពណ៌នាទៀតឡើយ ។

ឯអបាយភូមិទាំង ៤ ដូចបានរៀបរាប់ដោយសង្ខេបខាងលើនេះ ឃើញសុទ្ធតែជាទីប្រាសចាកសេចក្ដីសុខ នឹងសេចក្ដីចំរើនពិតណាស់ ។

ឯសត្វដែលនឹងធ្លាក់ខ្លួនទៅកើតក្នុងអបាយភូមិណាមួយ ៗ ក៏មកតែពីផលបាបកម្មដែលសត្វនោះបានធ្វើតាក់តែងឲ្យទៅកើត ដើម្បីនឹងទទួលទណ្ឌកម្មនឹងទុក្ខវេទនាតាមកម្លាំងបាបកម្មដែលខ្លួនបានធ្វើនោះ ។

រីឯបាបកម្ម គឺអំពើអាក្រក់ដែលធ្វើដោយកាយ, វាចា ចិត្ត, មាន ១០

ហៅថា អកុសលកម្មបថ ១០ ចែកចេញជាកាយទុច្ចរិត ៣, វចីទុច្ចរិត ៤ និងមនោទុច្ចរិត ៣ ។

## ២_ អំពីសុគតិភព

ឯសុគតិភព គឺភពដែលជាទីកើតនៃសត្វដែលមានគតិល្អ គឺសំដៅយកសត្វដែលបានធ្វើនូវអំពើបុណ្យនោះឯង ។

### ឯសុគតិភពគឺសំដៅឋានសួគ៌ ៦ ជាន់គឺ :

ជាន់ទី ១ ហៅថា ចាតុម្មហារាជិកា, ជាន់ទី ២ ហៅថា តាវត្តិង្ស, ជាន់ទី ៣ ហៅថា យាមា, ជាន់ទី ៤ ហៅថា តុសិតា, ជាន់ទី ៥ ហៅថា និម្មានរតី, ជាន់ទី ៦ ហៅថា បរនិម្មិតវសវត្តី ។

ឯឋានសួគ៌ ៦ ជាន់នេះជាទេវលោក គឺជាឋាននៃពពួកទេវតា និងស្រីទេពអប្សរមានព្រះឥន្ទ្រាធិរាជជាស្តេចគ្រប់គ្រង ។

ឯជីវភាពនៃពពួកទេវតា និងស្រីទេពអប្សរមានដំណើរខ្ពង់ខ្ពស់ប្រសើរដូចម្តេចនោះ ខ្ញុំពុំបានដឹងឲ្យច្បាស់សព្វគ្រប់ទេ តែខ្ញុំបានដឹងត្រង់ថាទេវតាក្តី ស្រីទេពអប្សរក្តី រមែងបានជួបប្រទះនូវសុភមង្គលគ្រប់បែបយ៉ាងពីព្រោះនៅលើឋានសួគ៌នោះមានវិមានទិព្វ, មានសម្បត្តិទិព្វ និងមានអាហារទិព្វឥតមានការព្រួយលំបាកនឹងអ្វីឡើយ ។

មួយវិញទៀតដោយហេតុថា កំណើតទេវតាក្តី កំណើតស្រីទេពអប្សរក្តី មិនមែនជាឧបបាតិកកំណើតទេនោះ ខ្ញុំអាចសន្និដ្ឋានបានថា ទេវតានឹងស្រីទេពអប្សរតង់ទីងនៅរួមសង្វាសជាមួយគ្នាជាស្វាមីភរិយា ទើបសត្វដែលត្រូវទៅចាប់កំណើតឯឋានសួគ៌នោះ អាចទៅចាប់បដិសន្ធិកើតឡើងបានដែរ ។

កាលបើឋានសួគ៌មាន ៦ ជាន់ តើទេវតាក្នុងឋាននីមួយៗ បានបំពេញបុញ្ញកម្មផ្សេងពីគ្នាដូចម្តេច ទើបបានមកចាប់កំណើតលើឋានសួគ៌ផ្សេង ៗ ដូច្នេះ ?

ចំពោះបញ្ហានេះឃើញថាពិបាកនឹងឆ្លើយដោះស្រាយ ឲ្យសមហេតុផលណាស់ ពីព្រោះការកសាងសន្សំកុសល នឹងបុណ្យរមែងមានលក្ខណៈនឹងដំណើរផ្សេង ៗ ខុសពីគ្នាជាច្រើនអនេកប្បការ ៗ ត្រង់នេះឃើញមានតែបុញ្ញាភិសង្ខារនោះទេ ដែលអាចនឹងនាំតែងកំណើតល្អក្នុងឋានសួគ៌នីមួយ ៗ ឲ្យទៅតាមកម្លាំងបុញ្ញកម្មនោះ ៗ បាន ៗ

រីឯបុញ្ញកម្ម ដែលជាមូលហេតុនៃកំណើតល្អក្នុងឋានសួគ៌នោះ គឺសំដៅកុសលកម្មបថ ១០ នឹងបុញ្ញកិរិយាវត្ថុ ១០ នោះឯង ៗ

ឯកុសលកម្មបថ១០ គឺអំពើជាកុសល ដែលកើតឡើងដោយចេតនាវៀរមិនធ្វើនូវអំពើជាអកុសល ១០ គឺកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ ៗ

បើដូច្នេះ ឃើញថាកុសលកម្មបថ ១០ នេះគ្រាន់តែជាកុសលកម្មអាច ញុំាងសត្វឲ្យដោះខ្លួនរួចពីអបាយភូមិ ៤ តែប៉ុណ្ណោះ ។ លុះណាតែសត្វនោះបានបំពេញបុញ្ញកិរិយាវត្ថុ ១០ មានទានសីលភាវនាជាដើមថែមទៀត ទើបបុញ្ញកម្មនេះគាត់តែងបដិសន្ធិឲ្យទៅកើតក្នុងសុគតិភពបាន ។

សរុបសេចក្តីទៅឃើញថា ទុគ្គតិភព នឹងសុគតិភពជាទីសម្រាប់ឲ្យសត្វលោកអន្ទោលវិលកើតវិលស្លាប់តាមយថាកម្មរបស់ខ្លួន រកទីបំផុតគ្មានឡើយ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតដែលបានដឹងច្បាស់នូវវដ្តសង្សារ គឺដំណើរវិលកើតវិលស្លាប់ក្នុងត្រៃភពដូច្នេះ រមែងមានចិត្តនឿយណាយ ហើយស្វែងរកឧបាយសម្រាប់ដោះខ្លួនឲ្យរួចចាកវដ្តភ័យ គឺភ័យក្នុងការអន្ទោលវិលកើតវិលស្លាប់ក្នុងភពតូចភពធំនោះឯង ។

រីឯឧបាយនោះ បណ្ឌិតតែងដឹងច្បាស់ថា គ្មានឧបាយណាក្រៅពីការត្រាស់ដឹងមគ្គ ៤ ផល ៤ នឹងនិព្វាននោះទេ, ពីព្រោះមគ្គផលនិព្វាននោះ ពិតជាលោកុត្តរធម៌ គឺធម៌អាចចម្លងសត្វឲ្យឆ្លងចេញរួចផុតពីត្រៃលោកបានពិតមែន ។

លោកុត្តរកថាសង្ខេបចប់ដោយសង្ខេបតែប៉ុណ្ណេះ ឯរ

# ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

លោក ប៊ិ · ប៉ិ ប្រែរៀបរៀង

(តមក)

ព្រះយោគាវចរកុលបុត្រដែលប្រកបដោយវីរិយភាព កាលបើបាន
ពិចារណាឃើញខន្ធទាំង ៥ ដោយសង្ខេប ឬដោយពិស្តារដូច្នេះហើយ
ក៏ពិចារណាឃើញនូវអជ្ឈត្តិករូប គឺរូបខាងក្នុងជាដើមដោយអសុភារម្មណ៍
គឺនិយមថា រូបនេះមិនល្អ ទើងជាទីនាំមកនូវសេចក្តីខ្ពើមរអើម ៗ លំដាប់
អំពីនោះ ទើងកំណត់ដឹងនូវកវឡិង្ការាហារ គឺភោជនាហារដែលខ្លួនធ្វើឲ្យ
ជាពំនូក វិបល្លាសំ បជហាតិ ទើងលះបង់នូវវិបល្លាស គឺអារម្មណ៍មិន
ល្អ សំគាល់ថាល្អ លុះយល់ឃើញដូច្នោះហើយ ក៏ទើងឆ្លងកាមោឃៈ
ទើងបញ្ចកាមគុណបាន មិនប្រកបដោយសំយោជនៈ មានកាមសំយោជន៍
ជាដើម ទើងញុំាងខ្លួនឲ្យជាបុគ្គលប្រសើរ គឺជាព្រះខីណាស្រពក្នុងព្រះ
បវរពុទ្ធសាសនា ទើងទំលាយបំផ្លាញនូវអភិជ្ឈាអស់លោក មិនជាប់ជំពាក់
ដោយឧបាទានទាំង ៤ ទើងឃើញវេទនាថាជាទីនាំមកនូវទុក្ខ ហើយ
កំណត់ដឹងនូវផស្សៈ លះបង់នូវការយល់ឃើញថាជាសុខក្នុងធម៌ទាំងពួង
ដែលនាំមកនូវទុក្ខ ទើងឆ្លងតាកភវោឃៈបាន ទើងជាព្រះខីណាស្រពក្នុង

ពុទ្ធសាសនា គ្មានព្យាបាទ ។ សូម្បីពិចារណាឃើញសញ្ញា, សង្ខារ និងវិញ្ញាណដោយព្រះអនត្តា ក៏កំណត់ពិចារណានូវមនោសញ្ចេតនាហារ លះបង់នូវវិបល្លាស គឺយល់ឃើញថា ខ្លួនជារបស់ខ្លួនក្នុងបញ្ចក្ខន្ធ ដ៏មិនមែនជារបស់ខ្លួន និងធ្វើនូវខយៈគឺមិច្ឆាទិដ្ឋិបាន និងមិនប្រកាន់មាំក្នុងអត្តវាទុបាទាន ។ កាលពិចារណាឃើញនូវវិញ្ញាណដោយអនិច្ច-លក្ខណៈ ក៏នឹងកំណត់ដឹងនូវវិញ្ញាណាហារ និងលះបង់នូវវិបល្លាសនៃចិត្ត គឺថាទៀងក្នុងធម៌ដែលមិនទៀង និងធ្វើនូវខយៈ គឺអវិជ្ជាបាន និងបានជាព្រះអរិយបុគ្គលដ៏ប្រសើរគ្មានអាសវៈ ។

ព្រះយោគាវចរ ឃើញនូវអានិសង្សក្នុងការពិចារណាឃើញបញ្ចក្ខន្ធ គឺ រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ ប្រកបដោយអានិសង្សជា-ច្រើនដូច្នេះហើយ គប្បីពិចារណាដោយសង្ខេបឬដោយពិស្តារដូចពោលមកហើយនោះ ក៏នឹងបានសម្រេចមគ្គញ្ញាណ ផលញ្ញាណ សូម្បីអភិនីហារនៅមិនទាន់ចាស់ក្លា ក៏ជាបច្ច័យទៅក្នុងអនាគត លុះដល់គ្រប់កំណត់កាលហើយ ក៏នឹងកន្លងរំលងផុតចាកបញ្ចក្ខន្ធចូលកាន់ព្រះមហា-និព្វាន ។

ខន្ធយមកៈចប់ ។

X

X X

# អាយតនយមក:

ឥទានិ ខន្ធយមកស្ស បវត្តោ អាយតនយមក-និទ្ទេសោ អនុប្បត្តោ ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្វាយតនំ មនាយតនំ ធម្មាយតនន្តិ ។

លំដាប់អំពីខន្ធយមក: ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ទេសនា អាយ-តនយមក: តទៅទៀត មានសេចក្តីតាមព្រះអដ្ឋកថាថា៖

អាយតនយមកនិទ្ទេសោ ការសំដែងនូវអាយតនយមក: មកដល់ហើយ ក្នុងលំដាប់នៃខន្ធយមក:នេះ ខ្ញុំនឹងសំដែងដោយអំណាចអនុលោមតាមព្រះពុទ្ធដីកាថា ភគវា សម្តេចព្រះមានព្រះភាគមានព្រះពុទ្ធដីកាត្រាស់បុច្ឆាជាគូ ៗ ត្រាស់វិសជ្ជនាជាគូ ៗ គ្នា ដូចសំដែងក្នុងខន្ធ-យមក: ផ្សេងគ្នាតែខន្ធយមក:នោះ ត្រាស់បុច្ឆានឹងត្រាស់វិសជ្ជនាក្នុងខន្ធទាំង ៥ ក្នុងអាយតនយមក:នេះ ត្រាស់បុច្ឆានឹងវិសជ្ជនាក្នុងអាយតនៈ ។ ទ្វាទសាយតនានិ អាយតនៈនោះមាន ១២ ប្រការគឺ ចក្ខាយតនៈ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធា-យតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្វាយ-តនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ គ្រប់ជាអាយតនៈ ១២ ប្រការ ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាក្នុងចក្ខាយតនៈនោះ ទ្រង់ត្រាស់បុច្ឆា ជាគូៗ ហើយត្រាស់វិសជ្ជនាជាគូៗថា ចក្ខាយតនំ ឈាម ចក្ខុ នោះឬ ឈ្មោះថាចក្ខាយតនៈ ចក្ខាយតនៈនោះឬ ឈ្មោះចក្ខុ ? ឬចក្ខុ មិនមែនចក្ខាយតនៈទេ ? ចក្ខាយតនៈមិនមែនចក្ខុទេ ? ។

ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាថា អាមន្តា គឺ/ ចក្ខុនោះឯងហើយឈ្មោះថា ចក្ខាយតនៈ ។ នោះឯងហើយឈ្មោះថាចក្ខុ ។ ត្រាស់ដូច្នេះហើយ ទើបត្រាស់បុច្ឆាតទៅទៀតថា រូបនោះឬឈ្មោះថា រូបាយតនៈ ? រូបាយតនៈនោះឬឈ្មោះថារូប ? ។

ការដែលព្រះពុទ្ធអង្គទ្រង់ត្រាស់បុច្ឆា និងវិសជ្ជនានូវរូបក្នុងអាយ-តនយមកៈនេះ មិនប្លែកគ្នាពីបុច្ឆា និងវិសជ្ជនាក្នុងខន្ធយមកៈទេ ប្លែកតែ ខន្ធយមកៈថា ដោយរូបខន្ធក្នុងអាយតនៈ យមកៈនេះហៅថារូបាយតនៈ តែការដែលសំដែងសេចក្តីនោះដូចគ្នា ។

ប្រការមួយទៀត ក្នុងខន្ធវិភង្គនោះត្រាស់ទេសនាដោយរូបក្ខន្ធថា ដោយខន្ធទាំង ៥ ។ អ្នកប្រាជ្ញគប្បីជ្រាបថា ក្នុងសោតាយតនៈជា ដើមដរាបដល់ធម្មាយតនៈ ក៏ត្រាស់បុច្ឆានិងវិសជ្ជនាដូចជាក្នុងចក្ខាយត-នៈ រូបាយតនៈដែរ ។

ចក្ខាយតនៈនោះ បានដល់ចក្ខុ ។ ដែលហៅថា ចក្ខុនោះ ដោយ អត្ថថា ឃើញនូវរូប ។

ដែលហៅថា អាយតនៈនោះ ហេតុតែឃើញជាអណ្ដូងនៃចក្ខុ ។ ឯអាយតនសព្ទនេះប្រែថា អណ្ដូង, ទីកើត, មិនចង្អៀត, ទីនៅ, ទីអាស្រ័យ ក៏បាន ។

ដែលហៅថា អាយតនៈគឺចក្ខុនោះ បានដល់ការអាស្រ័យចក្ខុវិញ្ញាណ ។ បើមានតែចក្ខុទទេ ខ្វះវិញ្ញាណ ចក្ខុនោះមិនអាចឃើញនូវរូបទាំងពួងបានឡើយ ទាល់តែមានចក្ខុវិញ្ញាណ ទើបអាចឃើញរូបសម្រេចសេចក្ដីប្រាថ្នាបាន ។ ឯចក្ខាយតនៈនោះ រមែងមានរូបាយតនៈជាអារម្មណ៍ អធិប្បាយថា ចក្ខុមានរូបជាអារម្មណ៍ រូបជាទីគោងថ្តក់នៃចក្ខុ ។

សោតាយតនៈនោះ ក៏មានសម្លេងជាអារម្មណ៍ ឃានាយតនៈក៏មានក្លិនជាអារម្មណ៍ ជិវ្ហាយតនៈ ក៏មានរសជាអារម្មណ៍ កាយាយតនៈ ក៏មានផោដ្ឋព្វៈជាអារម្មណ៍ មនាយតនៈ ក៏មានធម៌ជាអារម្មណ៍ ។ អធិប្បាយថា សម្លេងជាអារម្មណ៍នៃសោត (ត្រចៀក) ក្លិនជាអារម្មណ៍នៃច្រមុះ រសជាអារម្មណ៍នៃអណ្ដាត គ្រឿងផោដ្ឋព្វៈ គឺពួកកន្ទេលសំពត់ស្លៀកសំពត់ដណ្ដប់ ទីងសេនាសនៈទាំងពួងជាដើមជាអារម្មណ៍នៃកាយ រឿងរ៉ាវទាំងឡាយ ដែលត្រូវគិតត្រូវដឹងដោយចិត្តជាអារម្មណ៍នៃចិត្ត ។

ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ អាយតនៈខាងក្នុងប្រាំមួយប្រការនេះ ជាទី

កើតនៃកុសលនឹងអកុសល ៗ

ចក្ខុជា បសដ្ឋេន្ទា កាលបុគ្គលបានឃើញរូបព្រះពុទ្ធបដិមាករ នឹងរូបព្រះចេតិយ ឃើញដើមព្រះស្រីមហាពោធិព្រឹក្ស ហើយមានចិត្តត្រេកអរកែកយជ្រះថ្លា មានសទ្ធា ធ្វើសក្ការបូជាដោយគ្រឿងសក្ការៈបូជាផ្សេង ៗ តាមសតិកម្លាំង ៗ

ប្រការមួយទៀត បានឃើញផ្កាក៏ហើយមានចិត្តសទ្ធា គិតថាផ្កាឈើនេះ បើអាត្មាអញយកទៅធ្វើសក្ការបូជា ក៏នឹងមានផលានិសង្សគ្រប់ទានមុខ ៗ

ម្យ៉ាងទៀត ឃើញរបស់ទាំងពួងមានដើមថា អង្ករ ស្រូវសាលី នឹងម្ហូបចំណីអាហារក្តី ឃើញវត្ថុអ្វីៗក្តី ហើយកំណត់ទុកក្នុងចិត្តថានឹងធ្វើការកុសលមានឲ្យទានជាដើម ក៏ឈ្មោះថាបានធ្វើការកុសលបង្កើតដល់ចក្ខុមានរូបជាអារម្មណ៍ទាំងអស់ ៗ កុសលកើតដល់ចក្ខុមានរូបជាអារម្មណ៍នោះ គឺបុគ្គលបានឃើញរូបអ្វីៗ ហើយគិតប្រុងនឹងធ្វើការកុសល ក៏ហៅថាកុសលបង្កើតអំពីចក្ខុទ្វារមានរូបជាអារម្មណ៍ទាំងអស់ ៗ

ឯកុសលបង្កើតអំពីចក្ខុទ្វារមានរូបជាអារម្មណ៍នោះ ដូចជាសាធុជនបានឃើញបុប្ផជាតិនឹងផលាផលឬវត្ថុអ្វី ៗ ក៏បេះវែតគិតក្នុងចិត្តថា នឹងបូជាព្រះរតនត្រ័យ ដោយហោចទៅ សូម្បីឃើញភិក្ខុនិមន្តតាមមាគ៌ានឹងឃើញគេដង្ហែព្រះពុទ្ធរូបមកហើយ លើកហត្ថទមស្សការក្តី យ៉ាងនេះ

ក៏ឈ្មោះថាកុសលបង្កើតអំពីចក្ខុទ្វារមានរូបជាអារម្មណ៍បាន ។

ការកុសលដែលបង្កើតអំពីសោតទ្វារ មានសម្លេងជាអារម្មណ៍នោះ គឺបុគ្គលបានឮសម្លេងជនទាំងឡាយ និយាយបបួលគ្នាធ្វើការកុសល ហើយមានចិត្តត្រេកអរកើតសទ្ធាជ្រះថ្លាយ៉ាងនេះ ក៏ឈ្មោះថាកុសលបង្កើតអំពីសោតទ្វារមានសម្លេងជាអារម្មណ៍ សូម្បីគ្រាន់តែបានឮសម្លេងអ្វី ៗ ហើយនិយមបង្អោនចូលទៅខាងការកុសល ក៏រាប់ថាជាកុសលបង្កើតអំពីសោតទ្វារមានសម្លេងជាអារម្មណ៍ទាំងអស់ ។

ការដែលបានឃើញព្រះពុទ្ធរូបហើយកើតសទ្ធាជ្រះថ្លាក្តី ក៏ឈ្មោះថាកុសលបង្កើតអំពីចក្ខុទ្វារដូចគ្នា ។ សម្តេចព្រះពុទ្ធអង្គជាម្ចាស់នៃយើង កាលនៅជាព្រះពោធិសត្វទ្រង់ព្រះនាមបញ្ញត្តិឈ្មោះថា សុរុចិព្រាហ្មណ៍ បានឃើញព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធ ដែលប្រកបដោយព្រះរស្មីជាអស្ចារ្យ គិតទីងនិមន្តព្រះសុមង្គលសម្មាសម្ពុទ្ធនោះ មកថ្វាយចតុប្បច្ច័យទាន ។ អញ្ញេសំ សរីរប្បភា ព្រះរស្មីនៃសម្តេចព្រះពុទ្ធអង្គទាំងឡាយដទៃ ១ នោះផ្សាយទៅបានចម្ងាយ ៨០ ហត្ថជាប្រក្រតី ។ ឯព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធនោះ មិនដូច្នោះទេ និច្ចកាលំ ផរិត្វា ព្រះរស្មីនៃព្រះសុមង្គលសម្មាសម្ពុទ្ធនោះផ្សាយទៅពេញទាំងមួយម៉ឺនលោកធាតុជានិច្ចកាល ព្រោះហេតុព្រះសុកមង្គលសម្មាសម្ពុទ្ធជាម្ចាស់ បានបំពេញបុក្កទានហើយបានតាំងសេចក្តីប្រាថ្នាទុក

ទីងបានបូជា ព្រះពុទ្ធមួយព្រះអង្គដោយគ្រឿងបូជាដ៏ប្រសើរលើសគ្រឿងបូជានៃលោកទាំងឡាយ គឺធ្វើរូបកាយរបស់ខ្លួនឲ្យជាប្រទីបថ្វាយដល់ព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុរបស់ព្រះពុទ្ធមួយព្រះអង្គ ក្នុងកាលនៅជាព្រះបរមពោធិសត្វ មិនទាន់បានត្រាស់ជាព្រះពុទ្ធនៅឡើយ ដូចមានសេចក្តីនិទានតទៅនេះ ៖

សោ ភារ ពោធិសត្តកាលេ បានឮរឿង ។ មកថា ព្រះសុមង្គលសម្មាសម្ពុទ្ធជាម្ចាស់នោះ ក្នុងកាលព្រះអង្គនៅសោយព្រះជាតិជាព្រះបរមពោធិសត្វនៅឡើយ បានកើតក្នុងព្រះបវរពុទ្ធសាសនា ប៉ុន្តែសម្តេចព្រះពុទ្ធអង្គនោះ ស្តេចរំលត់ខន្ធចូលកាន់ព្រះនិព្វានទៅហើយ ទុកតែព្រះធាតុចេតិយ ក្នុងព្រះពុទ្ធសាសនា ។ មិនអស់ មិនបាត់សាបសូន្យឡើយ ។

ជនទាំងឡាយកសាងព្រះចេតិយបញ្ចុះព្រះបរមសារីរិកធាតុ ទុកជាទីនមស្សការ ។ បុត្រនៃត្រកូល (កុលបុត្រ) គឺព្រះបរមពោធិសត្វនោះបានឃើញជនទាំងឡាយនាំគ្នាមកថ្វាយបង្គំព្រះចេតិយ បូជាដោយគ្រឿងសក្ការផ្សេង ។ តាមសទ្ធា ព្រះបរមពោធិសត្វគិតថា ជីវិតំ បរិច្ចជិតំ គួរអាត្មាអញបរិច្ចាគជីវិតបូជាដល់ព្រះធាតុចេតិយ ទើបនឹងបានឈ្មោះថាបូជាសម្តេចព្រះជិនស្រីសម្មាសម្ពុទ្ធ សកលសរីរំ វេដ្ឋាបេត្វា ទើបញុំាងជនទាំងឡាយឲ្យរុំកាយដោយសំពត់ ដែលជ្រលក់ប្រេងក្រអូប

ដោក មានអាការដូចជាប្រទីប ធ្វើឲ្យមានប្រឆេះជាច្រើន ហើយអុជភ្លើង ឲ្យភ្លឺព្រោងព្រាតឆេះពេញទាំងសរីរកាយថ្វាយព្រះបរមសារីរិកធាតុ ដើរ ប្រទក្សិណ តាមលំដាប់ដោយចិត្តសទ្ធាជ្រះថ្លា ទ្រាំទ្រនៅអស់រាត្រីមួយ រហូតដល់ព្រះអាទិត្យរះឡើង

លោមក្កុបំបិ សូម្បីតែរណ្តៅនៃពោមមួយវិនាសអន្តរាយទៅក៏ ឥតអគ្គីមានឡើយ សរីរាវយវៈនៃព្រះបរមពោធិសត្វមិនបានក្តៅក្រហាយ សោះ ត្រជាក់ជាប្រក្រតី អគ្គីមិនបានដុតពេលឲ្យឆេះ បរិដ្ឋា វិយ ហាក់ដូចជាព្រះបរមពោធិសត្វចូលទៅនៅក្នុងត្របកនៃផ្កាឈូក ៗ ធម្មោ ហិ នាម មែនពិត សុចរិតធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្ត ៗ អ្នកណា ប្រព្រឹត្តធម៌ ៗ ក៏រក្សាអ្នកនោះ ៗ

តេនាហ ភគវា ហេតុនោះ សម្តេចព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ប្រទានព្រះធម្មទេសនាទុកថា ធម្មោ ហវេ រក្ខតិ ធម្មចារឹ សុចរិតធម៌រមែងរក្សានូវបុគ្គលប្រព្រឹត្តល្អប្រពៃដោយពិត ធម្មោ សុចិណ្ណោ សុចរិតធម៌នោះ បុគ្គលណាបានសន្សំទុកហើយ ក៏កំណត់ យ៉ាងជាក់ច្បាស់ថា នឹងនាំមកនូវសេចក្តីសុខឲ្យដល់បុគ្គលអ្នកសន្សំនោះ ន ទុគ្គតឹ គច្ឆតិ ធម្មចារី បុគ្គលមានប្រក្រតីប្រព្រឹត្តនូវសុចរិតធម៌ នោះ រមែងមិនទៅកាន់ទុគ្គតិ មានព្រះពុទ្ធដីកាប្រទានព្រះធម្មទេសនា ទុកដូច្នេះ ៗ បណ្ឌិតទាំងឡាយគប្បីធ្វើមនសិការកំណត់ទុកក្នុងចិត្តថា

អំពើណាជាទុច្ចរិតចូរលះបង់ចោលឲ្យស្រឡះកុំធ្វើអំពើនោះឡើយ អំពើណាជាសុចរិត ចូរខំធ្វើអំពើនោះចុះ ។

ឥមស្មឹ ការណេ ស្សុ ល្លោ ហេតុតែផលនៃកុសលកម្មដែលព្រះសុមង្គល បានធ្វើព្រះអង្គឲ្យជាប្រទីបបូជាដល់ព្រះបរមសារីរិកធាតុចេតិយនេះឯង លុះបានត្រាស់ជាព្រះពុទ្ធហើយទើបមានព្រះរស្មីទូទៅទាំងមួយម៉ឺនលោកធាតុជានិច្ចកាល ។

សុរុចិព្រាហ្មណ៍នោះ បានឃើញព្រះពុទ្ធរស្មីដ៏អស្ចារ្យដូច្នោះហើយទើបគិតថា អញនឹងទៅអារាធនានិមន្តព្រះពុទ្ធអង្គមកកាន់គេហស្ថាន គិតស្រេចក៏យាត្រាទៅកាន់ទីគាល់នៃព្រះសុមង្គលសម្មាសម្ពុទ្ធ ហើយក្រាបទូលអារាធនានិមន្តព្រះពុទ្ធអង្គព្រមទាំងព្រះភិក្ខុសង្ឃជាបរិវារ ដើម្បីនឹងឲ្យមកទទួលអាហារបិណ្ឌបាតទានក្នុងវេលាព្រឹកស្អែក ។ សម្តេចព្រះសុមង្គលសម្មាសម្ពុទ្ធក៏ទទួលនិមន្តដោយតុណ្ហីភាព ។ សុរុចិព្រាហ្មណ៍ដឹងច្បាស់ថា ព្រះពុទ្ធអង្គទ្រង់ទទួលនិមន្តហើយ ក៏ក្រាបថ្វាយបង្គំលាវិលមកលំនៅវិញ កាលកំពុងដើរតាមមាគ៌ាគិតថា អាត្មាអញនឹងថ្វាយបិណ្ឌបាតដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធអង្គជាប្រធានប្រមាណប៉ុណ្ណោះ នឹងឲ្យព្រះភិក្ខុសង្ឃទាំងនោះគង់ក្នុងទីកន្លែងណា បើអាសនៈរបស់អាត្មាអញមានមិនគ្រប់គ្រាន់យ៉ាងនេះ ។

(នៅមានត)

មធុរសភាសិត

# សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈិន ពិនិត្យ

(តមក)

---

កាលនោះ សោមទត្តព្រាហ្មណ៍ដែលមានជីវិតរស់នៅ លុះបានដឹងថា សោមព្រាហ្មណ៍ជាសម្លាញ់ស្លាប់ហើយ ក៏ពោលពាក្យសោកស្តាយថា ឱសោមព្រាហ្មណ៍អើយ ! សំឡាញ់បានដោះលៃងជីវិតរបស់ខ្ញុំ ឲ្យរួចអំពីសេចក្តីស្លាប់ ហើយស៊ូស្លាប់ដោយខ្លួនឯង មុខគួរឲ្យខ្ញុំស្តាយណាស់ ។ លុះព្រាហ្មណ៍ពោលយ៉ាងនេះហើយ ក៏ចំណាយទ្រព្យសម្បត្តិធ្វើទានដ៏ធំ បូជាសពនៃសោមព្រាហ្មណ៍នោះស្រេចហើយ ឧទ្ទិសចំណែកបុណ្យចំពោះសោមព្រាហ្មណ៍ ជាសំឡាញ់ដែលទទួលមរណភាពនោះឯង ។

ចំណែកខាងសោមទេវបុត្តបានដឹងច្បាស់ថា សោមទត្តព្រាហ្មណ៍ជាសំឡាញ់ បានធ្វើបុណ្យ ហើយឧទ្ទិសចំណែកបុណ្យជូនមកឲ្យខ្លួនដូច្នោះហើយ ក៏រមិលមើលទិព្យសម្បត្តិរបស់ខ្លួនដ៏មានសិរីសួស្តី តាំងបានឃើញនូវផលានិសង្សនៃសេចក្តីកតញ្ញូកតវេទី ដែលខ្លួនបានលះបង់ជីវិតដើម្បីសោមទត្តព្រាហ្មណ៍ជាសំឡាញ់នោះ លុះបានឃើញច្បាស់ហើយ

ក៏ហោះផ្តេកផ្តោះចុះមកកាន់ស្ថានមនុស្សលោក ហើយលះបង់អត្តភាពទិព្វ និម្មិតអាត្មាជាមាណព ដើរចូលទៅកាន់សំណាក់សោមទត្តព្រាហ្មណ៍ បានធ្វើបដិសណ្ឋារៈស្រុះស្រួលហើយ ក៏ប្រកាសប្រាប់អំពីបុញ្ញភាពរបស់ខ្លួន ដែលបានឡើងទៅកើតនាស្ថានទេវលោកនាយ ហើយនាំយកសោមទត្ត-ព្រាហ្មណ៍ជាសំឡាញ់ហោះឡើងទៅកាន់ស្ថានសួគ៌ទេវលោក ដោយអា-នុភាពបុញ្ញរិទ្ធិរបស់ខ្លួន ទើបនិយាយថា: សំឡាញ់អើយ! អ្នកចូរសោយទិព្វសម្បត្តិសំគួរតាមសេចក្តីប្រាថ្នាអ្នកចុះ លុះនិយាយហើយ ក៏បានប្រ-គល់នូវគ្រឿងឥស្សរិយយសនៃទេវតា ឲ្យសោយអស់រយៈ ៧ ថ្ងៃ រួចនាំត្រឡប់ចុះមកកាន់មនុស្សលោកវិញ បានឲ្យស្ថិតនៅក្នុងផ្ទះរបស់ខ្លួនដដែល ហើយហោះឡើងទៅកាន់ស្ថានទេវលោកវិញ ។ សេចក្តីពិតថា បុគ្គលអ្នកបានទទួលចំណែកបុណ្យក្តី អ្នកចែកចំណែកបុណ្យឲ្យគេក្តី រមែងបានសោយនូវសម្បត្តិទិព្វ និងសម្បត្តិមនុស្សដោយចំណែកមួយមែនពិត ។

ចាប់ដើមអំពីកាលនោះមក សោមទត្តព្រាហ្មណ៍ កាលបើនឹករលឹករឿយ ៗ នូវទិព្វសម្បត្តិដែលវិនាសហើយនោះ ក៏កើតទុក្ខរងស្គមមានសម្បុរអាក្រក់កើតជាពេគរលឿងអស់ទាំងខ្លួនប្រាកដក្នុងកាលនោះឯង ។

អថេកទិវសំ ថ្ងៃមួយជាខាងក្រោយ សោមទេវបុត្តបានរមិលមើលសោមទត្តជាសំឡាញ់នោះ ក៏បានដឹងថា សោមទត្តព្រាហ្មណ៍ដល់នូវសេចក្តីទុក្ខព្រួយមានពេគជូនដូច្នោះហើយ ក៏គិតពិចារណាថា: ធម្មតា

មនុស្សជាតិទាំងអស់ មិនអាចនឹងសោយសម្បត្តិទិព្វបានឡើយ ហើយក៏ហោះចុះមកកាន់សំណាក់សោមទត្តព្រាហ្មណ៍ បានឲ្យកែវចិន្តាមណីមួយជាកែវអាចឲ្យសម្រេចសម្បត្តិទាំងពួងតាមសេចក្តីប្រាថ្នា ហើយធ្វើកែវនោះឲ្យក្លាយទៅជាកេវស្ត្រីមនុស្សដ៏មានរូបល្អ មានបរិវារច្រើន មានពន្លឺរស្មីដ៏ត្រចះត្រចង់ កន្លងរូបស្ត្រីមនុស្សទាំងឡាយដោយអានុភាពឫទ្ធិរបស់ខ្លួន ទើបធ្វើស្ត្រីកេវនោះ ឲ្យជាភរិយានៃសោមទត្តព្រាហ្មណ៍ជាសំឡាញ់ ហើយហោះឡើងទៅកាន់ស្ថានសួគ៌ទេវលោកនាយវិញហោង ។

ឯសោមទត្តព្រាហ្មណ៍ព្រមទាំងភរិយាបុត្ត , ដែលបានសម្បត្តិទិព្វឃើញជាក់ច្បាស់ដោយភ្នែកខ្លួនហើយ ក៏កើតមានសទ្ធាជឿកម្មជឿផលឥតកម្រើក បានឲ្យទានរក្សាសីលដរាបដល់អស់ជីវិត បានឡើងទៅកើតក្នុងសំណាក់សោមទេវបុត្តជាសំឡាញ់នោះឯង , សឹងប្រកបដោយសម្បត្តិទិព្វទាំង ១០ ប្រការជាសុខក្សេមក្សាន្តក្នុងស្ថានសួគ៌ទេវលោក ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយ សម្តែងជាបទព្រះគាថាដូច្នេះថា :

មិត្តេភិជជ្ជិតមជា ឧបការកោច
ទានម្បិ ទេន្តិ សុជនា ឥតិ ចិន្តយិត្វា,
មា មិត្តទុព្ភិ សតតំ ភវេថុបការំ
ក្យុស្សោបការំ ការកញ្ញុ ភាគៈវឌ្ឍតិ ។

សេចក្ដីថា: បណ្ឌិតជាតិទាំងឡាយ បើបានពិចារណាដឹងនូវឧប-
ការដូច្នេះថា : ជនជាសប្បុរសទាំងឡាយតែងមានចិត្តត្រេកអរកែកយកួង
មិត្តដែលមានគុណចំពោះខ្លួន ហើយអាចលះបង់ជីវិតនៃខ្លួនតបឧបការ-
គុណរបស់មិត្តនោះវិញ, មួយទៀត ត្រូវតែកុំទ្រុះមិត្រដែលមានឧបការ:
ឲ្យសោះ ត្រូវតែធ្វើតបគុណវិញឲ្យមាំមួនផង ត្រូវមានចិត្តប្រកបដោយ
កតញ្ញូកតវេទិតាធម៌ផង ឲ្យប្រាកដក្រៃលែងដោយពិត ។

សម្ដែងរឿងនិទានព្រាហ្មណ៍លះបង់ជីវិតខ្លួនដល់សំឡាញ់ ជាគំរប់
១០ ក្នុងវគ្គទីពីរចប់ដោយសង្ខេបប៉ុណ្ណោះឯង ។

X
X X

## មង្គលសកលិមាណធម្មទីប
## យក្ខវិញ្ញតវគ្គទី៣ មានរឿងនិទាន១០

### ១- យក្ខវិញ្ញតវត្ថុកថា

សម្ដែងរឿងនិទានបុរសបញ្ឆោតយក្សជាបឋម ដោយពាក្យបាលីថា:
កតវេទិ បរិជិត្វាតម្ហា ដូច្នេះជាដើម អធិប្បាយថា កាលព្រះមានព្រះ
ភាគជាម្ចាស់ ទ្រង់ចូលបរិនិព្វានទៅហើយ, បានឮថា មានស្រុកមួយ
ឈ្មោះគុណ្ឌកគ្រាម (ស្រុកនៃជាងដេរ) នៅក្នុងជនបទរបស់ព្រះបាទកោ
សលកដ ។

ឯក្នុងគុណ្ឌកគ្រាមនោះ មានមនុស្សម្នាក់ឈ្មោះពុទ្ធទាស ជាអ្នកបានដល់នូវព្រះពុទ្ធជាទីពឹងស្មើដោយជីវិត ដោយបទបាលីដូច្នេះថា: យាវ-ជីវំ ពុទ្ធំ សរណំ គច្ឆាមិ ពុទ្ធោ មេ សរណំ តាណំ បរាយនំ ។ ប្រែថា "ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកដរាបដល់អស់ជីវិត, ខ្ញុំព្រះករុណា មានតែព្រះពុទ្ធជាទីពឹងនូវជ្រកកោនប្រព្រឹត្តទៅខាងមុខ" ។ បុរសនោះ តែងចំរើនពុទ្ធគុណយ៉ាងនេះពុំដែលដាច់ឡើយ ហើយអាស្រ័យនៅក្នុងផ្ទះខ្លួននោះឯង ។

សម័យមួយ មានមនុស្សម្នាក់អ្នកនៅក្នុងជនបទដទៃ បានត្រេចដើរទៅក្នុងស្រុកនោះ ។ ហើយបានដល់គុណ្ឌកគ្រាម ក៏បានសុំនៅសំណាក់អាស្រ័យក្នុងផ្ទះពុទ្ធទាសឧបាសកនោះឯង ។

វេលានោះ មានយក្សមួយ វាចូលទៅជ្រែកអាស្រ័យនៅក្នុងសរីរៈនៃបុរសអ្នកជនបទនោះ វាប្រាថ្នាដើម្បីនឹងបៀតបៀនសំឡាប់យកជាចំណីអាហារ ។

កាលបុរសអ្នកជនបទនោះ បានចូលទៅខាងក្នុងគុណ្ឌកគ្រាមហើយ, ដោយតេជៈគុណនៃពុទ្ធទាសឧបាសកអ្នកដល់នូវព្រះពុទ្ធជាទីពឹងជាប់មិនដាច់ ទើបយក្សនោះវាពុំអាចនឹងចូលទៅកាន់ផ្ទះរបស់ឧបាសកនោះបានឡើយ ហើយលះបង់លែងតាមបុរសអ្នកជនបទនោះចេញ

កនៅនឹងចាំខាងក្រៅស្រុក អស់រយៈកំណត់ ៧ ថ្ងៃ មើលផ្លូវបុរសនោះត្រឡប់ចេញមកអំពីផ្ទះនៃឧបាសកនោះវិញ ក៏នឹងចាប់បរិភោគជាអាហាររបស់កហោង ។

ឯបុរសអ្នកជនបទនោះ លុះបានទៅសំណាក់អាស្រ័យក្នុងផ្ទះឧបាសកនោះ អស់រយៈកំណត់បាន ៧ ថ្ងៃហើយ ក៏មានសេចក្តីប្រាថ្នានឹងត្រឡប់ទៅកាន់ដែនរបស់ខ្លួនវិញ ក៏បានលាឧបាសកនោះចេញទៅអំពីស្រុកក្នុងកាលនោះឯង ។

កាលបើបុរសនោះ ដើរចេញមកអំពីស្រុកដូច្នោះហើយ យក្សនោះក៏ស្ទុះទៅចាប់បុរសនោះ បានក្នុងពាក់កណ្តាលផ្លូវនោះឯង ។

ចំណែកឯបុរសអ្នកជនបទនោះសួរយក្សថា អ្នកឯងទៅណាអស់កាលយូរប៉ុណ្ណោះ អ្នកមកចាប់ខ្ញុំធ្វើអ្វី ។

ឯយក្សតបវិញថា យើងបានមកនៅនឹងចាំក្នុងទីនេះ អស់កាល ៧ ថ្ងៃហើយ ។

បុរសអ្នកជនបទនោះសួរទៀតថា ចុះអ្នកឯងត្រូវការអ្វីដោយខ្ញុំ ។ ត្រូវឲ្យវត្ថុអ្វីដល់អ្នកឯង ។

យក្សបានស្តាប់ហើយឆ្លើយតបថា: ម្នាលបុរសដ៏ចំរើន! ខ្ញុំមានសេចក្តីត្រូវការដោយអាហារនឹងបរិភោគ ដ្បិតខ្ញុំឃ្លានពេកណាស់ ។

បុរសនោះបានស្ដាប់ហើយក៏ពោលថា កាលបើអ្នកឯងស្រែកឃ្លានខ្លាំងយ៉ាងនេះហើយ ហេតុអ្វីក៏អ្នកឯងមិនចូលទៅចាប់យើងបរិភោគខាងក្នុងស្រុកនោះ ។ ឯយក្សឆ្លើយថា : ម្នាលបុរសដ៏ចំរើន! ក្នុងផ្ទះនោះមានឧបាសកម្នាក់ដល់នូវព្រះពុទ្ធជាទីពឹងជាប់ជានិច្ច ដោយតេជះនៃឧបាសកនោះឯង បានជាខ្ញុំពុំអាចនឹងចូលទៅក្នុងផ្ទះនោះបានឡើយ ។

ចំណែកឯបុរសអ្នកជនបទ ក៏ពុំបានដឹងសេចក្ដីថា ពុទ្ធៈ នោះជាដូចម្ដេចឡើយ , តែថាជាមនុស្សមានប្រាជ្ញាចេះនិយាយបញ្ឆោតយក្សនោះឲ្យជឿបាន ក៏ពោលថា ម្នាលយក្ស! បុរសដែលនៅក្នុងស្រុកនោះបានដល់នូវព្រះពុទ្ធជាទីពឹងយ៉ាងណា ខ្ញុំក៏បានដល់នូវព្រះពុទ្ធជាទីពឹងយ៉ាងនោះដែរ ។ លុះនិយាយហើយ ក៏សូត្របាលីថា : ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកដូចឧបាសកនោះពិត ។ កាលបើបុរសអ្នកជនបទនោះបានសូត្រយ៉ាងនេះហើយ យក្សក៏ស្ងាំងកាំងកាំងស្មារតីមិនដឹងជានឹងថាអ្វីកើត ក៏ស្រែកសម្រែកលាន់ឮខ្លាំងភិតភ័យញ័រទន្ទក់រត់បាត់ទៅក្នុងខណៈនោះឯង ។

បពិត្រសប្បុរសទាំងឡាយ! កិច្ចដែលបានដល់នូវព្រះសម្មាសម្ពុទ្ធជាទីពឹងយ៉ាងនេះ នឹងមានផលានិសង្សជាអនន្តគុណ អាចការពារនូវភ័យអន្តរាយក្នុងលោកនេះបាន , ការពារមិនឲ្យសត្វធ្លាក់ចុះទៅក្នុងអបាយភូមិ

បាន ទាំងអាចដឹកនាំសត្វទាំងឡាយៈទៅកាន់ស្ថានសួគ៌ ដរាបដល់ព្រះនិព្វានក៏បាន ។ ហេតុដូច្នោះ បានជាព្រះអរហន្តទាំងឡាយ ពោលនូវបទព្រះគាថាដូច្នេះថា:

តុច្ឆាតិ វចនំ ឯតំ អមនុស្សានំ ភយាវហំ

តុទ្ទកត្តិកាជន្តូនំ សត្តនា មុខមារវហំ ។

សេចក្តីថា: ពាក្យដែលពោលថា តុច្ឆា ដូច្នេះនេះ ជាពាក្យនាំមកនូវភ័យធំដល់ខ្មោចទាំងឡាយ ជាពាក្យនាំមកនូវសេចក្តីរីករាយចិត្តដល់ជនទាំងឡាយដែលជាពុទ្ធបរិស័ទដោយពិត ។

សព្វោបទ្ទវណាសាយ បច្ចត្ថំ ទិព្វមោសថំ

ទិព្វមន្តំ មហាតេជំ មហាយន្តំ មហាព្ភុតំ ។

ពាក្យដែលពោលថា តុច្ឆា ដូច្នេះនេះ ហៅថា ឱសថទិព្វ ហៅថា មន្តទិព្វ មានតេជៈច្រើន ជាយន្តដ៏ប្រសើរ ជាអស្ចារ្យដ៏ធំ អាចញ៉ាំងឧបទ្រពទាំងពួង ឲ្យវិនាសបាត់បង់ទៅបានដោយពិត ។

(នៅមានត)

## មហោសថជាតក

លោក អ៊ឹម-គង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស ឈឹម-ឡូរ ពិនិត្យ

(តមក)

សេនកោ វែអាចារ្យសេនកៈស្រដីថា ហៃអាចារ្យទាំង៣ អើយ! អាថ៌កំបាំងអញនេះ ប្រសិនបើជ្រួតជ្រាបទៅដល់ព្រះកាណ៌ព្រះមហាក្សត្រ ហើយ អ្នកអើយ! វែទោសអញនឹងដល់ស្លាប់ ហេតុអ្វីអញថា ទោសអញដល់ស្លាប់នោះ, ដ្បិតកាលនោះ ព្រះបាទកុសរាជ ជាព្រះវរបិតាព្រះមហាក្សត្រនេះឯង ស្តេចទៅប្រពាតកំសាន្តនាឧទ្យាន អញក៏បានហែស្តេចទៅកូវ បានឃើញស្រីផ្កាមាសមួយ មានរូបឆោមលោមពណ៌នោះល្អ អញពុំអាចទប់ចិត្តបានឡើយ ហើយអញបាននាំស្រីផ្កាមាសនោះចូលទៅក្នុងព្រៃស្ងាត់ សេពសម្ភពដោយនូវចំណង់បញ្ចកាមគុណ ហើយមានចិត្តលោភលន់ពន់ប្រមាណ សម្លាប់ស្រីផ្កាមាសនោះ យកគ្រឿងប្រដាប់ ដែលព្រះមហាក្សត្រព្រះរាជទានឱ្យ អញយកមកវេចរួចទុកនៅចន្លាស់ទឹក ជាទ្រព្យប្រពៃនៃអញ, ហេតុនេះឯង បានជាអញមិនប្រាប់អ្នកដទៃ ពោះបើក្រែងនឹងក្លើសំឡាញ់អញនោះហោង ។ អើបុក្កុសៈ ឯងតើយល់ដូចម្តេច អាថ៌កំបាំងនេះ? ចូរថ្លែងប្រាប់មកហោង ។ ទើបអាចារ្យបុក្កុសៈសំដែងប្រាប់នូវអាថ៌កំបាំងខ្លួនថា ខ្ញុំ

សោតមានយួនដំបៅ . . រួចដួចជាប់នៅដើមភ្លៅ   មានទឹករងៃនោះហូរ
ចេញពេញសំពត់ដិតមន្ទិល ឲ្យជាភិកាលអំលុងយូរហើយ ឥតអ្នកឯណា
ទឹងដឹងឡើយ មានតែប្អូនស្រីខ្ញុំដឹង, កាលណាបើព្រឹកព្រហាមអរុណោ-
ទ័យហើយ ប្អូនស្រីខ្ញុំយកទឹកមកលាងជ្រះដំរះខ្ទុះអសោចិ៍រួចហើយ យក
ថ្នាំបំពាក យកសំឡីមករុំច្រើនជាន់ ហើយយកកំណាត់សំពត់មក
រុំថែមទៀត ទើបយកខ្សែចងពុំឲ្យមានហ្នងដល់តិចឡើយ ទើបស្លៀក
សំពត់លើ ហើយខ្ញុំដើរទៅគាល់ព្រះមហាក្សត្រ, ដូចថ្ងៃមួយ ស្តេច
កំសាន្តព្រះហឫទ័យ ហើយលើលាមកគង់លើភ្លៅខ្ញុំ យកព្រះហស្តមក
អង្អែលសរសើរថា ភ្លៅបុក្កុសៈនេះទន់ មានកាលសរសើរតែអម្បាលនោះ,
មានកាលក៏ស្តេចយកព្រះកេសមកផ្ទុំលើភ្លៅខ្ញុំបន្តិចទៅក្បូ ទឹករងៃនោះ
ជ្រាបជាបដល់ចុងព្រះកេសាព្រះមហាក្សត្រ, នៃអ្នកអាចារ្យសេនកៈអើយ!
អំពើកំបាំងខ្ញុំនេះឯងដូច្នេះ, ប្រសិនបើស្តេចជ្រាបសុភាពថា ខ្ញុំមានយួន
ដំបៅដូច្នោះហើយ ម្លេះសមស្តេចឲ្យអាមាត្យសម្លាប់ខ្ញុំបង់ពុំលែងឡើយ,
ហេតុនេះឯង ខ្ញុំពុំសំដែងប្រាប់អ្នកដទៃ ទោះបីក្រទឹងប្អូនស្រីខ្ញុំនោះ
ឡើយ ។ អាចារ្យសេនកៈថាទឹងអាចារ្យបុក្កុសៈដូច្នោះហើយ ទើបដណ្តឹង
ទៅអាចារ្យកាមិន្ទទៀតថា អាចារ្យកាមិន្ទតើដូចម្តេច? ។ ទើបអាចារ្យកាមិន្ទ
ក៏ថ្លែងនូវអាថ៌កំបាំងរបស់ខ្លួនថា ឯខ្លួនខ្ញុំនេះ កាលណាបើថ្ងៃ ១ បោសថ
ដាច់ខែនោះ មានខ្មោចយក្ស ១ ឈ្មោះ ឆរៈឆរៈ តែងមកចូលជាន់

នៃខ្ញុំ ហើយខ្ញុំស្រែកដូចផ្គរ ស័ព្ទនោះខ្លាំងក្រៃ ៗ រីកូនខ្ញុំ ក៏ដឹងនូវដំណើរដូច្នោះហើយ ក៏រត់ចូលមកចាប់ខ្ញុំនាំទៅក្នុងផ្ទះ ហើយបានយកខ្សែមកចងខ្ញុំខ្ទាប់ផ្តេក ទុកនៅល្វែងខាងក្នុងហើយចងទ្វារខ្ទប់ ទើបកូនខ្ញុំចេញមកក្រៅ ហៅអស់បរិវារយកគ្រឿងមហោស្រពមកលេង ឲ្យប្រឡំស័ព្ទគ្រឿងនូវស័ព្ទខ្ញុំស្រែក ពុំឲ្យអ្នកដទៃក្រៅលែងខ្លួនកូនខ្ញុំឮឡើយ, រីអាចិកំប៉ាំងនេះ បើស្តេចជ្រាបសភាពជាខ្ញុំផ្គរហើយ រីជីវិតនៃខ្ញុំឥតអង្គឹមានឡើយ, ហេតុនោះខ្ញុំថា គួរគប្បីប្រាប់កូននោះក៏ប្រសើរក្រៃ ៗ អាចារ្យសេនកៈស្តាប់ហើយឆ្លើយថា អើ! អាចិកំប៉ាំងអាចារ្យកាមិន្ទថាដូច្នោះហើយ , ឯអាចារ្យទេវិន្ទឯងគេដូចម្តេចសោត? ៗ ទើបអាចារ្យទេវិន្ទថ្លែងសំដែងប្រាប់ថា ហៃអាចារ្យអើយ! ឯសេចក្តីកំប៉ាំងខ្ញុំនោះ , កាលនោះ ព្រះបាទកុសរាជជាសម្តេចព្រះវររាជបិតាព្រះមហាក្សត្រយើងនេះ ព្រះឥន្ទ្រាធិរាជឲ្យកែវមណីរ័ត្នមកស្តេច ប្រយោជន៍នឹងឲ្យរុងរឿងចម្រើនជាមង្គលប្រសើរ លុះដល់ស្តេចទ្រង់ព្រះអាពាធជាទុរន់នោះ ខ្ញុំឡើងទៅចាំមើលព្រះរោគ ខ្ញុំយល់កែវនោះហើយខ្ញុំលួចយកបាន ហើយខ្ញុំឲ្យទៅម្តាយខ្ញុំរក្សា ហើយខ្ញុំមានសិរីសួស្តី, រីម្តាយខ្ញុំពុំឲ្យអ្នកដទៃដឹងដល់គិចឡើយ បើខ្ញុំនឹងឡើងទៅគាល់ព្រះមហាក្សត្រកាលណា ម្តាយខ្ញុំឲ្យកែវមណីរ័ត្ននោះមកខ្ញុំ ៗ បញ្ចូលនូវស្រមោលសិរីសួស្តីហើយ ទើបខ្ញុំឡើងទៅកាន់មន្ទីរស្តេច រីស្តេចមិនមានបន្ទូលនឹងអម្ចាស់ទាំងឡាយឡើយ

ស្តេចមានព្រះបន្ទូលតែនឹងខ្ញុំថា ហៃកាតាវ្យទេវិន្ទអើយ ! ចូរមកឯកាយ ខ្ញុំចូលទៅទៀបព្រះមហាក្សត្រហើយ ព្រះអង្គព្រះរាជទានមាស ៨ ដំឡឹងម្តង, ១៦ ដំឡឹងម្តង, ៣២ ដំឡឹងម្តង, ៦៤ ដំឡឹងម្តង, សព្វថ្ងៃ ខ្ញុំអាស្រ័យដោយតែមណីកែវនោះឯង បើស្តេចជ្រាបនូវអាថ៌កំបាំងទាំងអម្បាលនោះហើយ ឲ្យអ្នកអាតាវ្យសេនកៈអើយ ! ជីវិតនៃខ្ញុំឥតអង្គមានឡើយ, តែក្តីកំបាំងនេះ ខ្ញុំមិនប្រាប់អ្នកដទៃក្រៃលែងម្តាយខ្ញុំឡើយ ។

នឹងថ្លែងពីព្រះបរមពោធិសត្វមិញ ព្រះអង្គគង់នៅក្រោមអានបាយនោះ បានស្តាប់នូវសំដីអាតាវ្យទាំង ៤ សំដែងថ្លែងនូវអាថ៌កំបាំងទាំងអម្បាលនោះហើយ អ្នកកត់សំគាល់ទុកក្នុងព្រះរាជហឫទ័យសព្វគ្រប់ឥតមន្ទិលពិគាល់ឡើយ ។ គេ ( ចត្តារោ បណ្ឌិតា ) . . . អ្នកបណ្ឌិតទាំង ៤ និយាយគ្នា ដូចគេទំលាយថ្លៃនៃអាត្មាឯងស្រេចហើយដោះឡើងទៅ ហើយស្រដីថា អ្នកទាំងឡាយកុំប្រហែស ចូរមកអំពីព្រឹកហោង , យើងនឹងសម្ងាប់កូនគហ្បតីឲ្យបានដូចក្តីបំណងយើងហោង ។ អាតាវ្យទាំង ៤ ស្រដីដូច្នោះហើយ កំហួសទៅផ្ទះរៀង ៗ ហោង ។

បពិត្រអើយ ! បរិវារពោធិសត្វដែលចាំឃ្លាំមើល យល់អាតាវ្យទាំង ៤ ទៅដូច្នោះហើយ កំចូលទៅបើកអានបាយឡើងឲ្យពោធិសត្វចេញមកហើយ អ្នកលីលាយាត្រាទៅដល់លំនៅ ហើយអ្នកស្រង់នូវទឹកអប់ក្រឡាប់នូវគន្ធពីដោះប្រពៃស្រេចហើយនៃ អ្នកសោយនូវភោជនាហារមាន

ខុជារសេនោះត្រកាលផ្សេងៗ ហើយទ្រង់ព្រះចិន្តាថា យប់នេះនាងខុជ្ជុត្តរទេវី ជាអយិអគ្គមហេសីព្រះមហាក្សត្រ អ្នកនឹងឲ្យពតិមានមកប្រាប់អញពុំលែងឡើយ, ពោធិសត្វគិតដូច្នោះហើយ អ្នកប្រើបុរសបរិចារពីរនាក់ឲ្យចាំនៅទ្វារ ហើយផ្តាំថា បើមានបរើអំពីនាងខុជ្ជុត្តរវរលក្ខណ៍ ជាអយិអគ្គ-មហេសីនៃស្តេចឲ្យមករកអញ ក៏ចូរអ្នកទាំងឡាយប្រាប់ថា អញនៅទេ ឲ្យចូលមកកាន់អញឆាប់កុំបីយូរឡើយ ។ ពោធិសត្វអ្នកផ្តាំនូវប្រការអម្បាលនោះហើយ អ្នកចូលទៅផ្ទុំលើគម្រាលដ៏ប្រសើរ ជាសុខសប្បាយទៅហោង ។

តស្មិំ ខណេ រាជា សិរិសយនបិដ្ឋេ និបន្នោ បណ្ឌិតស្ស គុណេ សរិត្វា មហោសធបណ្ឌិតោ សត្តវស្សិកកាលតោ បដ្ឋាយ ..... ក្នុងកាលនោះ រីព្រះបាទវិទេហរាជ ស្តេចចូលទៅគង់លើគ្រែក្រឡាព្រះបន្ទំ ព្រះអង្គពុំស្រណុកព្រះរាជហឫទ័យសោះ ស្តេចបានរំលឹកគុណព្រះពោធិសត្វថា មហោសថអ្នកប្រាជ្ញ អាចមកគាល់ហៅទៅបំរើធ្វើប្រយោជន៍ឲ្យអញតាំងពីអាយុ ៧ ឆ្នាំ រហូតមកដល់ពេលនេះ អ្នកពុំដែលធ្វើនូវកំហុសណាមួយចំពោះរូបអញនោះឥតអង្គីមានឡើយ, កាលៈទេវតាដណ្តឹងប្រស្នាអញក៏ មហោសថអ្នកប្រាជ្ញឆ្លើយដោះសាអាចប្រស្នាតាំងអញ, ឥឡូវនេះ បើអញឥតពីមហោសថអ្នកប្រាជ្ញហើយ រីជីវិតនៃអញឥតអង្គីមានឡើយ ។

(នៅមានត)

រឿងដាវធភាសប្រប

កាព្យពាក្យ ៩

# ឃុនសុវត្ថិវិទូ ឃូរ-អ៊ុន និពន្ធ

បានទទួល

## រង្វាន់លើកទឹកចិត្ត

ផ្នែកកវីនិពន្ធ ក្នុងការប្រឡងអក្សរសាស្ត្រ
របស់សមាគមអ្នកនិពន្ធខ្មែរ នៅឆ្នាំ១៩៦១

---

## នមក្ការកថា

ខ្ញុំសូមលើក ហត្ថក្រពុំ បង្គំផ្ទង់
ចំពោះគ្រង់ អង្គត្រៃរ័ត្ន ក្នុងលោកា
គឺព្រះពុទ្ធ នឹងព្រះធម៌ ជាសរណា
ចាំងព្រះសង្ឃ ជាកេត្រា នៃពួកសត្វ ។
ព្រះសម្ពុទ្ធ ព្រះសទ្ធម្ម នឹងព្រះសង្ឃ
ចាំង ៣ អង្គ ដែលឈ្មោះថា ព្រះត្រៃរ័ត្ន
ព្រោះជាកែវ មានពន្លឺ ភ្លឺឆ្វៀលឆ្វាត់
អាចបំបាត់ កាត់ងងឹត ក្នុងសន្តាន ។
កែវដទៃ(១) ទោះបីថ្លៃ ច្រើនអនេក

---

១ កែវមណី, កែវពៃទូរ្យ. កែវបភិឡ, ពេជ្រ, មាស, ប្រាក់ ជាដើម ។

ស្មើបែក ដុះតាប់ក្អែក អ្នកឃើញបាន
ក៏មិនអាច កំចាត់ល្ងង់ ក្នុងអង្គប្រាណ
មិនអាចប្រាន កងកិលេស ឲ្យឃ្លាតឆ្ងាយ ៗ
ឯគ្រែវត្ត ប្រាកដជា កែវថ្លៃថ្លា
ញុំាងប្រាជ្ញា មនុស្សទេព្តា ឲ្យបែកសាយ
ឲ្យលះកាត់ គ្រឿងសៅហ្មង ផងចាំងឆ្ងាយ
ឲ្យផ្តាត្រាយ ផ្តាច់ចង្វាយ ខ្សែតណ្ហា ៗ
កែវចាំងបី គុណពិសី គួរគោរព
ចាំងជាម្លប់ ដ៏ត្រជាក់ អ្នកសាសនា
ហេតុនេះខ្ញុំ សូមលើកផ្គុំ ម្រាមហត្ថា
ឱនកាយា លុតជង្គង់ បង្គំថ្វាត់ ៗ
ដោយគេជះ នមស្ការ យ៉ាងខ្វេនេះ
ខ្ញុំសូមរិះ រកពាក្យកាព្យ ដោយវៃឆ្លាត់
ឲ្យចាប់ចួន ជួនបានន័យ គ្មានវិបត្តិ
សូមកំចាត់ បំបាត់មោហ៍ នាំចិត្តល្អក់ ៗ

## អារម្ភកថា

កតីនេះ ខ្ញុំសូមថ្លែង រឿងនារទៈ
កស្សបៈ ដ៏មានជាតិ ក្នុងជាតក

នៃគម្ពីរ ព្រះសុត្តន្ត-បិដក

ដោយការផ្ចង់ បកប្រែ ជាពាក្យកាព្យ ។

ជាពាក្យបួន ប្រាំបួនម៉ាត់ ចាត់មួយវគ្គ

បួនឃ្លាជាក់ ដាក់ទ័ណ្ឌមួយ ស្អាត់ដកប

តែពាក្យខ្លះ ដែលអានផ្ចង់ ព្រួតិចតាប(១)

ឃ្លានោះឯង ទីងប្រែភាព ជាពាក្យដប់(២) ។

ការណ៍ដែលនាំ បន្ទំខ្ញុំ លើករឿងនេះ

ដោយត្រិះរិះ ឃើញពិតថា ជារឿងគប់

គ្មានពាន់ផ្សាយ ក្នុងដែនខ្មែរ ជាច្រើនចប់

ជាកំណាប់ កប់លិចនៅ ក្នុងបាលី ។

ហើយជារឿង មានសារៈ ជាក់សំខាន់

ដូចព្រះចន្ទ ព្រះអាទិត្យ ចាំងរង្សី

---

១ ពាក្យដែលអានផ្ចង់ព្រួតិច គឺជាពាក្យធ្លាប់និយាយរត់មាត់មកហើយ ដូច សរណា, ប្រតិបត្តិការ, ករុណា, មនុស្ស, មហាក្សត្រ ជាដើម ។ ២ កាព្យភាសាខ្មែរ បើតែងជាបទពាក្យ ៧ ក្នុងមួយឃ្លា ទំងមានឃ្លាខ្លះជាពាក្យ ៨, បើជាបទពាក្យ ៨ នឹងមានឃ្លាខ្លះ ជាពាក្យ ៩, បើជាបទពាក្យ ៩ ទំងមានឃ្លាខ្លះជាពាក្យ ១០ ដោយអាស្រ័យពាក្យអានផ្ចង់នោះ ដូចគ្នានឹងកាព្យបាលីដែរ គួយ៉ាង :

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

ឲ្យដឹង ដឹកមិនបាន ប្រានអស់ខ្ញី
បញ្ចាំងដី ឲ្យពួកសត្វ ប្រតិបត្តិការ ។
បើលោកអ្នក មានចិត្តស្មគ្រ បានអានហើយ
នឹងបានស្បើយ បាត់សង្ស័យ កុំងឆមិអាចិ
ដែលយល់ឆ្ងង ឬមិនយល់ ដោយពិស្តារ
តាមហេតុការណ៍ គោះគិតច្រើន ជាកុំខាន ។
ដោយអាស្រ័យ ន័យយ៉ាងនេះ ទើបខ្ញុំប្រែ
បកស្រាយកែ តែងជាកាព្យ ដោយក្លាហាន
ទុកជាកិច្ច ការសោដៃ នៃអន្តប្រាណ
ដូចនិទាន មានតទៅ ជាសង្កាត់ ។

វិតកបិា
១

សេចក្តីថា កងវិទេហនគរ
ដ៏បវរ មានស្តេចមួយ ប្រសើរក្តាត់
ទ្រង់ព្រះនាម អង្គតិ ជាមហាក្សត្រ
សោយកដ្ឋរដ្ឋ មានអំណាច ខ្លាំងអស្ចារ្យ ។
មានរេហ៍ពល សុទ្ធពូកែ ច្រើនអនេក
អាចចូលច្រែក ដែកតយុទ្ធ ទឹងខ្លាំងមារ
ដោយក្លាហាន គ្មានខ្លាច ហ៊ានតុះតារ

ស្ដេចដខែ ក៏យអន្ធការ ចុះបាញ់ដៃ ។
ក្នុងថ្ងៃមួយ ស្ដេចទ្រង់ហៅ ពជសេរ័ក
ទាំងបីនាក់ ឲ្យចូលគាល់ ប្រញាប់រ៉
គឺសុនាម, លោកអលាត នឹងវិជ័យ[1]
ហើយក្សត្រថ្ងៃ មានបន្ទូល ត្រាស់ប្រឹក្សា ៖

នៃអស់លោក ក្នុងថ្ងៃនេះ ខ្ញុំនឹកចង់
សប្បាយអង្គ ត្រង់រឿងមួយ ប្រពៃថ្លា
ចេះបួរអ្នក ស្មុគ្រជួយគិត តាមប្រាជ្ញា
ធ្វើយ៉ាងណា ឲ្យខ្ញុំបាន ក្សាន្តរីកកាយ ។

លោកអលាត ក្រាបទៀបបាទ បង្គំថ្វាត់
ទូលមហាក្សត្រ តាមយោបល់ យល់ក្នុងកាយ
ថាបពិត្រ ព្រះនរិន្ទ្រ រិទ្ធិពណ្ណកយ
ទូលបង្គំ សូមក្រាបថ្វាយ ពយយោបល់ ៖
ការចម្បាំង តាំងតយុទ្ធ នឹងស្ដេចណា
ដែលមិនខ្លាច ព្រះចេស្ដា នៃចមពល

---

១ បណ្ដាមន្ត្រីជាន់ខ្ពស់ទាំង ៣ នេះ, លោកសុនាម នឹងលោកវិជ័យ ក្នុងបាលី មិនឃើញប្រាប់ឋានន្តរស័ក្តិទេ; ចំណែកលោកអលាត មានប្រាប់ថា ជាសេនាបតី គឺជានាយករដ្ឋមន្ត្រី ក្នុងសម័យឥឡូវនេះ ។

កាយស្តេចនោះ ឲ្យចុះញុំម ព្រមប្រគល់
ថ្វាយដីដល់ ព្រះកូមិន្ទ ឲ្យត្រួតត្រា ៗ
ត្បើយាំងនេះ ទើបព្រះអង្គ ទ្រង់សប្បាយ
ដោយបានផ្សាយ កាត់អំណាច រាជអាជ្ញា
បើទ្រង់សព្វ តាមព្រះទ័យ ស្របចិន្តា
ទូលបង្គំ កុំសេនា ច្បាំងថ្វាយទ្រង់ ៗ
បន្ទាប់មក លោកសុនាម ក្រាបបង្គំ
ព្រះបរម មហាក្សត្រ ខត្តិយវង្ស
ទូលថ្វាយន័យ ឲ្យទ្រង់ជ្រាប មិនបង្អង់
ថាសូមទ្រង់ ជ្រាបក្រោមល្អង ធូលីបាទ ៗ
ទូលបង្គំ យល់ថាការ ច្បាំងរាំងដល់
នាំអំពល់ ឲ្យវរល់ ខូចបង់ខាត
ព្រោះព្រះអង្គ មានស្តេចច្រើន ស្តាប់ឱវាទ
ជ្រកក្រោមបាទ មានមកហើយ ដូចជ្រាបស្រាប់ ៗ
បើព្រះអង្គ ចង់កែកាយ ក្នុងព្រះទ័យ
សូមទ្រង់លៃ នៃត្រិះរក ខាងល្បែងសព្វ
ប្រគំភ្លេង លេងច្រៀងរាំ ឲ្យគឹងគាប់
ទើបចិត្តបាប ក្នុងគម្រោក នៃកាមា ៗ

តមកៈទៀត លោកវិជ័យ លើកកំបង់
បង្គំអង្គ ព្រះឧរិទ្ធ ពិទូសិរ្យ
ក្រាបទូលន័យ លៃតាមយល់ យ៉ាងនេះថា
សូមមេត្តា ទ្រង់ករុណា ជ្រាបសេចក្តី ។
ការស្តាប់ប្រៀង មៀងមើលរ៉ា ល្បែងនេះណា
ព្រះរាជា ទ្រង់សណ្តាប់ ពល់ពត្រី
ចាំបាច់ទូល ឲ្យទ្រង់ជ្រាប បានការអ្វើ
ព្រះចក្រី គួរមានក្តី យល់យ៉ាងនេះ ៖
សូមព្រះអង្គ ទ្រង់ស្តេចយាង សាកសួរធម៌
ដោយស្មោះសរ ទឹងអ្នកប្រាជ្ញ ដែលអាចចេះ
ដោះស្រាយរួច គ្មានទើសទាល់ សល់ចំណោះ
ធ្វើយ៉ាងនេះ ទើបពេញជា សប្បាយពិត ។
គ្រានោះឯង ព្រះរាជា នរសេដ្ឋ
ទ្រង់សង្កេត ន័យទាំង៣ ដោយពិនិត្យ
ឃើញដូចពាក្យ លោកវិជ័យ ស្តីនោះពិត
ទើបទ្រង់រិទ្ធ ប្រសិទ្ធពរ ឲ្យវិជ័យ ។
រួចទ្រង់ត្រាស់ ព្រះបន្ទូល សួរទៅថា
ចុះលោកណា ធ្លាប់ស្គាល់ជាក់ អ្នកប្រាជ្ញថ្លៃ

មានប្រាជ្ញា អាចដោះសា ដោយប្រពៃ
នៅអាស្រ័យ រស់យប់ថ្ងៃ ក្នុងទីណា ?

លោកអលាត ជានាយក រដ្ឋមន្ត្រី
ក្រាបទូលថ្វី ថាសូមទ្រង់ ព្រះមេត្តា
មានអចេលក៍(១) ឈ្មោះគុណៈ(២) ស្នាក់នៅនា
ព្រៃមិគទាយ៍ មហាវ័ន ណាព្រះអង្គ ! ។
លោកគ្រូនេះ មានចំណេះ ប្រាជ្ញាជ្រៅ
បើស្ដេចទៅ សួរប្រស្នា យ៉ាងផ្ចិតផ្ចង់
លោកអាចថ្វាយ ពាក្យសេចក្ដី គ្មានបង្អង់
មុខជាទ្រង់ បានរីករាយ ជាពុំខាន ។

ព្រះរាជា ទ្រង់សណ្ដាប់ សព្ទនាយក
ទើបទ្រង់ងក់ ព្រះសិរ្សៈ ទទួលថ្កាន
រួចទ្រង់ត្រាស់ ព្រះបញ្ជា ឲ្យរៀបយាន
សម្រាប់ពល គង់ពាហន ទឹងមន្ត្រី ។
ស្ដេចទ្រង់យាន ដោយមានខនាង ពលកញ្ញា
តាំងសេនា អ្នកកងការ ហែចក្រី

---

១ អ្នកបួសអាក្រាត ដាច់គ្រឿងតំរៀយ បួសក្រៅពុទ្ធសាសនា ។ ២ ហៅបាន ២ យ៉ាងថា "គុណៈ" ក៏បាន, ថា "គុណ" ក៏បាន ។

ស្តេចដល់ហើយ ទ្រង់គោរព តាមវេណី
រួចនរបតី ត្រាស់ទង្គារ សួរទៅថា ៖

លោកគ្រូម្ចាស់ សុខស្រួលអង្គ ទេឬអ្វី
ឬមានក្តី មិនសប្បាយ ដោយហេតុណា
ទាំងព្រះនេត្រ អាចសង្កេត មើលឃើញជាក់
ឬក៏ជា ងងឹតដិត អស់ទៅហើយ ?

លោកគ្រូគុណ ថ្វាយព្រះពរ បវរក្សត្រ
ជាវិបត្តិ ក្នុងរូបប្រាណ ពុំមានឡើយ
សឹងសុខសាន្ត គ្មានទុក្ខព្រួយ ជាសះស្បើយ
ភ្នែកទាំងពីរ ភ្លឺនៅឡើយ គ្មានងងឹត ។

– ខ្ញុំករុណា ដែលយាត្រា មកទីនេះ
ប្រាថ្នាចេះ នូវចំណេះ ដ៏ពិចិត្រ
ដោយសាកសួរ នូវសំនួរ តាមក្រមក្រឹត្យ
សូមម្ចាស់គិត ពិនិត្យដោះ សោះសង្កា ។

ខ្ញុំសង្ស័យ សឹងមានន័យ ដូចតទៅ ៖
តើមែនឬ ត្រូវបុត្រធ្វើ កិច្ចយ៉ាងណា
តបគុណលោក ដែលមានមក លើអាត្មា
ឲ្យសុខា ជ័យមង្គល មានដល់ប្រាណ ?

មួយវិញទៀត ជាតិជាមនុស្ស ក្នុងលោកិយ
កាន់ធម៌អ្វី ទើបមានក្តី សុខសម្រាន្ត
ក្នុងលោកនេះ នឹងលោកនាយ ពុំអាក់ខាន
សូមលោកគ្រូ គួរនិទាន កាត់ក្តីឲ្យ ។

— ថ្វាយព្រះពរ ! ផលនៃកម្ម អាក្រក់ល្អ
នៃសត្វក- សាងសន្សំ ខំតំកល់
ដូចឲ្យទាន រក្សាសីល ផ្តិលកន្ទល់
ដែលនឹងផ្តល់ ឲ្យសុខទុក្ខ នោះក៏គ្មាន ។

ទាំងបរលោក លោកដទៃ ពីលោកយើង
ឋានសួគ៌ច្រើន ឋាននរក នឹងនិព្វាន
ទេព្តាព្រហ្ម មារយក្សយម ក៏ពុំមាន
សេចក្តីនេះ សូមរិះធ្យាន កុំវិតក្ក(១) ។

បើបាបបុណ្យ ទាំងទោសគុណ មិនឲ្យផល
ទៅវិលវល់ តបគុណអ្វី ម្តាយឪពុក
កិច្ចចែចាំ ដែលលោកធ្វើ ទាំងគ្រប់មុខ
ការនេះទុក ជាការៈ អ្នកជាមេ ។

សត្វបានសុខ ឬបានទុក្ខ ក៏បានឯង

---
១ អាន វិតុក តាមសំនៀងថៃ ។

គ្មានកម្មចែង ចាត់ឲ្យសុខ ឲ្យទុក្ខទេ
ឯមានសីល គឺជនពាល ធំជាងគេ[២]
បានបញ្ញត្ត ទុកគ្រាន់តែ[២] ប្រយោជន៍ខ្លួន ។
ព្រោះហេតុនេះ មនុស្សយើង មុនស្លាប់ទៅ
មិនបាច់ត្រូវ គិតទៅមុខ ដែលឈឹងសូន្យ[៣]
គិតធ្វើអ្វី នាំឲ្យភ័យ មានដល់ខ្លួន[៣]
បើនឹងគិត គិតឲ្យមួន ពីរកេទ្រព្យ ។

ក្នុងពេលនោះ លោកអលាត រដ្ឋមន្ត្រី
មានសេចក្តី ជឿគ្រូគុណ ដែលរៀបកប់
ទើបលើកហត្ថ ពោលស្អាតថា ខ្ញុំមានភ័ព្វ
សូមគំនាប់ លោកគ្រូម្ចាស់ ដោយជ្រះថ្លា ។
ពាក្យលោកម្ចាស់ ដែលពោលនេះ ពេញជាត្រូវ
ត្រង់តាមផ្លូវ គំនិតខ្ញុំ ឥតសង្កា
ខ្លួនខ្ញុំឯង ក៏ស្តុតាងស្រាប់ ធ្លាប់កើតជា

---

២-៣ សម្ពស្សពាក្យចួនមាន ៣ គឺ មុខសម្ពស្ស ដូចខ្យល់ អី នឹង អៃ, ខ្យល់ អា នឹង អៀ. ខ្យល់វិសញ្ញនី :) នឹងខ្យល់ ស, ខ្យល់ រ នឹង ផត រ យកចួនគ្នា ១; មជ្ឈិមសម្ពស្ស ដូចខ្យល់ អេ នឹង អែ, ខ្យល់ អូ នឹង អូ. ខ្យល់ អំ នឹង អុំ យកចួនគ្នា ១; ឧកដ្ឋសម្ពស្ស ដូចខ្យល់ អ នឹង អ, ខ្យល់ អា នឹង អា. ខ្យល់ អះ នឹង អះ យកចួនគ្នា ១ ។ កវីនិពន្ធកាព្យ តែងចៀសពាក្យចួនជា មុខសម្ពស្ស ។

បិង្គលា[១] បិតនៅតា- ភណសី ។

បិង្គលៈ ជាតិជាអ្នក សម្លាប់គោ

ជាមនុស្សមោហ៍ ចាំងងងឹត ជិតរស្មី

មិនដែលធ្វើ នូវអំពើ កុសលអ្វី

លុះស្លាប់ខ្ចី ម្តេចមិនទៅ នៅនរក ។

ត្រឡប់កើត យកកំណើត ជាខ្ញុំនេះ

បុណ្យធំម៉្លេះ ធ្វើមន្ត្រី ទីនាយក

ព្រោះរឿងនេះ ទើបខ្ញុំយល់ ថានរក

ឋានលាមក សម្រាប់សត្វ ពុំមានទេ ។

ចាំងឋានសួគ៌ ក៏មិនគួរ ជឿថាមាន

ចាំងនិព្វាន ក៏មិនគួរ ជឿតាមគេ

ផលនៃកម្ម ដឹកនាំជាតិ ឲ្យជាតិរេ

គ្មានសោះទេ ស្រេចនៅតែ ធម្មតាចាត់ ។

ខណៈនោះ មានបុរស កំសត់ម្នាក់

ឈ្មោះវីជកៈ អង្គុយស្តាប់ ដោយស្ងៀមស្ងាត់

កាលបានឮ ពាក្យសេនូនា ជាសង្កាត់

---

១ ឈ្មោះ "បិង្គលៈ" ទេ តែដែលជា "បិង្គលា" ដើម្បីឲ្យចួននំពាក្យ "ជា" នៅឃ្លាខាងដើម ។

កើតវិបត្តិ កាត់ពុំបាន យំហ៊ឺ ៗ ។

ស្ដេចទតឃើញ ទ្រង់ទឹកឆ្ងល់ ខ្វល់ព្រះទ័យ

ទើបត្រាស់ថ្លៃ ឲ្យមន្ត្រី ទៅបំភ្លឺ

នាំយកមក ទ្រង់សួររក ហេតុយំឮ

នោះតើគឺ មានកើតទុក្ខ ពុំសុខអ្វី ?

វីជកៈ អ្នកទុគ៌ត ខ្សត់កំព្រា

លើកហត្ថា បន្ទន់កាយ ថ្វាយសេចក្ដី

ថាខ្ញុំឯង ចំបែងចិត្ត ព្រោះជៀតអី

មានសេចក្ដី រឭកឃើញ ជាតិពីមុន ។

កាលខ្ញុំកើត ជាសេដ្ឋី ឈ្មោះកាវៈ

មានគោគៈ ទ្រព្យសម្បត្តិ ជាដើមទុន

ច្រើនអនេក ខ្ញុំលែក ចែកធ្វើបុណ្យ

យកទ្រព្យទុន ដាក់ជាទាន គ្មានអាល័យ ។

តែដល់ខ្ញុំ ស្លាប់ពីនោះ លុះមកកើត

យកកំណើត កូនត្រកូល ទ័លខ្វាំងក្រៃ

ជាជាតិថោក ធ្វើខ្ញុំគេ តែសព្វថ្ងៃ

ក្រហិនហៃ ភ័យទុក្ខព្រួយ ឥតពេលផុត ។

តោះយ៉ាងនេះ ខ្ញុំគង់រះ ស្មាទានសីល

ឥតមានខ្ជិល ខំរក្សា ឧបោសថ[១]
កល់ថ្ងៃខែ ខំប្រឹងថែ ឲ្យបរិសុទ្ធ
ខំលំអុត ដុតកិលេស គ្មានសើរើ ។
ឥឡូវត្រូវ លោកគ្រូគុណ ទឹងអលាត
ដែលមានពាក់ ថាសីលពាន គ្មានអំពើ
នាំឲ្យខ្ញុំ ស្ដាយក្នុងចិត្ត គិតសើរើ
ឃើញមានធ្វើ ពីជាតិមុន ឥតផលផាក់ ។
ពាំងសីលសោត ដែលខ្ញុំកាន់ តែកល់ថ្ងៃ
ក៏មានន័យ ប្រហែលគ្នា គ្មានស្មើរស្មាក់
ត្រូវដូចពាក្យ របស់លោក ពាំងពីរនាក់
ទើបខ្ញុំភ្ញាក់ ស្ដាយកុសល ទៅជាយំ ។
— ឧរីដកៈ! អ្នកកុំយំ ខំកាត់ទៅ
បើតាមត្រូវ យើងធ្វើអ្វី ពោះតូចធំ
តែងមានខុស តែងមានត្រូវ មានមិនសម
ច្នេះយើងកុំ នាំគ្នាជឿ បុណ្យទឹងបាប ។
អង្គតិ ព្រះមហាពដ លុះទ្រង់ត្រាស់
បញ្ជាក់ច្បាស់ ឲ្យវីដកៈ ដឹងសភាព

---
១ អាន ឧបោសុថ តាមសំនៀងថៃ ។

រួចទ្រង់បែរ ព្រះភក្ត្រ ដាក់បន្ទូល

ព្រះកាយពប ថ្វាយបង្គំ លោកគ្រូគុណ ។

លាចេញទៅ កាន់លំនៅ វាំងប្រាសាទ

ប្រសើរស្អាត វិមានចន្ទូក៍(១) កើតដោយបុណ្យ

ហើយតម្រូវ នូវអាមាត្យ ឈ្មោះដូចមុន

ឲ្យទទួល ទ្រៃកតុន ការផែនដី ៖

នៃអស់លោក ទាំង ៣ នាក់ៈ ឥឡូវនេះ

ខ្ញុំបានរិះ គិតសម្រាក លាកចេញខ្មី

ឈប់ទទួល មើលខុសត្រូវ នូវទឹកដី

នេះដើម្បី ប្រយោជន៍ឲ្យ បានក្តីសុខ ។

ចេះសូមលោក យោគយល់ខ្ញុំ កុំប្រកែក

សូមរំលែក ចែកការគ្នា កាន់ដោយមុខ

រក្សាពស្ត្រ ទាសកម្មករ កុំឲ្យទុក្ខ

រក្សាស្រុក ជាតិប្រទេស ឲ្យមាំទាំ ។

ប្រគល់ស្រេច ស្តេចបញ្ជា អស់ក្រុមភ្លេង

ឲ្យមកលេង តូរ្យតន្ត្រី ស្រីច្រៀងរាំ

លុះទ្រង់ត្រេក មានតម្រេក ក្នុងកាមមាំ

ទ្រង់ក៏នាំ នារីស្រស់ មកសេពសន្ធ៍ ។

---

១ ឈ្មោះប្រាសាទ ។

ច្រើនសប្បាយ មិនដឹងណាយ នឹងសម្ដស្ស
ស្រីទាំងអស់ មានសម្រស់ ល្អពេកពន់
នាំឲ្យច្រើន លង់ព្រះទ័យ វែងគិតគណ
ពីព្រះជន្ម ដែលមិនធន់ ដករេក ។

ស្មេះរឿងនេះ បែរទៅពោល ពីធីតា
នាមវុតា រូបសោភា ល្អមានជោគ
ជាបុត្រី នៃអង្គិត ក្សត្រមានភោគ
ស្រីក្នុងលោក យកមកផ្ទឹម ត្រឹមពុំបាន ។

នាងវុតា មានប្រាជ្ញា ថ្លាជ្រាលជ្រៅ
យល់ខុសត្រូវ ផ្លូវធម៌អាថ៌ ទាំងប៉ុន្មាន
នាងក្មេងពិត តែគំនិត ដ៏ក្លាហាន
ចេះឲ្យទាន ហ៊ានកាន់សីល ឧបោសថ ។

នៅថ្ងៃមួយ ដែលជាថ្ងៃ ទីដប់បួន
នាងរៀបខ្លួន ស្អិតស្អាងអង្គ ខ្ពង់ល្អផុត
រួចនាំស្រី ជាបរិពារ ទៅលំអុក
គាល់រាជមកុដ ជាបិតា នៃព្រះនាង ។

ព្រះរាជា គ្រាន់តែឃើញ រាជបុត្រី
មានក្មេងស្រី ជាបរិវារ ហែសងខាង

មើលទៅហាក់ ទេពអប្សរ ល្អរូបកង
ទើបត្រាស់ក្នុង សួរទៅកៅ ទៅធីតា៖
ឱកូនស្រី កែវពិសី មាសឪពុក!
នាងបានសុខ គ្មានកើទុក្ខ ឬយ៉ាងណា
នាងទៅលេង ឯស្រះស្រង់ ទឹកវង់ថ្លា
កល់ទាក់ ពុំដែលមាន ហេតុអ្វី?
រូបគុគ្គា ដូចរូបភ្នា ឬរូបគោ
រូបសិង្ហគោ សេះក្របី រូបដំរី
នៅតែមាន គេធ្វើឲ្យ ហេតុអ្វី?
ឱវកូនស្រី ប្រាប់បិតា ឲ្យដឹងកាំ ៗ
កម្រងផ្កា បាច់មាលា រូបគ្រឹះស្ថាន
មាសកល្យាណ មានគ្រាន់លេង ឬ ធីតា!
ចុះមកនេះ តើកូនស្រី មានប្រាថ្នា
របស់អ្វី ពីហ្វាងប៉ា ជាមកស្ងួន?
នាងរុចា លើកហត្ថា បង្គំផ្ទង់
ចំពោះអង្គ ព្រះបិតា គុណធំធ្ងួន
ក្រាបទូលតប សម្របតាម រឿងក្នុងខ្លួន
ថាយសេចក្ដី ថៃសំនួន ដូច្នេះថា៖

ឧបិតា មហាគុណ ដ៏ធ្ងន់ក្រៃ ។
កូនសព្វថ្ងៃ បានទទួល ក្ដីសុខា
កូនទៅលេង ឯស្រះស្រង់ ទឹករងថ្លា
រាល់ទិវា ជាប្រក្រតី ពុំដែលខាន ៕
រូបតុក្កតា ផ្កាកម្រង ភួងមាលា
ដោយគេជះ ព្រះរាជា ទ្រង់ប្រទាន
អ្នកបំរើ នៅតែធ្វើ ឲ្យពុំខាន
ខ្ញុំម្ចាស់បាន បាត់អផ្សុក វិតក្កហ្មង ៕
ដែលខ្ញុំម្ចាស់ មកគាល់នេះ ដោយប្រាថ្នា
នឹងសុំប្រាក់ ពីហ្លួងប៉ា មួយពាន់ហោង
ដើម្បីចែក ឲ្យជាទាន ដល់អ្នកផង
ដែលទ័លក្រ ដ៏កន្ទង ណាព្រះអង្គ! ៕
ហើយថ្ងៃស្អែក នុ៎ះជាថ្ងៃ ទីដប់ប្រាំ
តាមចំណាំ ត្រូវខ្ញុំម្ចាស់ ខះខំផ្ចង់
ទទួលសីល រក្សាចិត្ត ឲ្យផូរផង់
ឲ្យខ្លួនត្រង់ តម្រង់ទៅ ក្នុងផ្លូវធម៌ ៕
ព្រះរាជា ទ្រង់សណ្ដាប់ សព្វសវន័យ៍
នៃបុត្រី ស្រីសម្លាញ់ ពេញទទេរ

ទ្រង់មិនសព្វ ព្រះហឫទ័យ ដោយស្មោះសរ
ទើបភូធរ មានបន្ទូល តបបុត្រី
ឱបុត្រា ពីតាកូន! នាងកុំកុំ
កុំទៅទំ ធ្វើបុណ្យទាន ប្រយោជន៍អ្វី
ឈប់បំផ្លាញ ប្រាក់ឪពុក ទៅកូនស្រី!
ឈប់ឃ្លាតខ្លី ស្លាទានសីល ទៅណាកូន! ។
លោកគ្រូគុណ, លោកអលាត, វីជក:
បានយល់ជាក់ ជាផលកម្ម គឺសោះសូន្យ
ដោយគេអាង មានភស្តុតាង យ៉ាងសមសួន
ដូច្នេះកូន ជឿគេទៅ ពៅពុំផា! ។
លោកអលាត បានដឹងជាតិ អំពីមុន
ជាជាតិកុន ដុនដាបអាប់ យ៉ាប់វេទនា
សម្លាប់គោ ចិញ្ចឹមប្រាណ បានសុខា
លុះមរណា មកកើតជា អលាតឯង ។
វីជក: ក៏ដឹងជាតិ ក្នុងភពមុន
ជានាយទុន ដ៏មានបុណ្យ ធនធានវែង
ជាអ្នកលះ ឈ្នះកំណាញ់ ទ្រព្យផងឯង
អាចថែកថែង ឲ្យជាទាន គ្មានស្តាយទេ ។

លុះលែងជាតិ រាគមក យកភពថ្មី
ប្រែជាតិ ជាទាសៈ អ្នកខ្ញុំគេ
ជនពីរនេះ សឹងមានកម្ម ដែលជាមេ
កូនឃើញទេ ពិតជាកម្ម គ្មានឲ្យផល ។

កុមារី ស្រីរុចា ប្រាជ្ញាវៃ
បានឮន័យ ព្រះគម្រាស់ ខ្លះយោបល់
ទើបព្រះនាង ត្រាស់តបភ្លាង ដោយក្ដីយល់
ឲ្យចមពល យល់ឃើញត្រូវ ផ្លូវសាសនា ៖

បពិត្រព្រះ រាជបិតា មានគុណធំ !
ពីដើមខ្ញុំ គ្រាន់តែឮ គេស្ដីថា
ឥឡូវនេះ បានឃើញច្បាស់ នឹងនេត្រា
សមដូចជា សុភាសិត ពិតម៉ត់ចត់ ៖

ជនណាគប់ គប់ជនពាល ដែលល្ងង់ខ្លៅ
នឹងក្លាយទៅ ជាពាលា ជាក់ប្រាកដ
អ្នកណាគប់ ជនវង្វេង វង្វេងខុសបថ
នឹងលេក ស្មារតីឈង វង្វឹងវង្វិន ។

ព្រះបិតា មានវាសនា ជាស្ដេចធំ
មិនគួរសម សម៉ូជឿ ពាក្យគ្រូគុណា

លោកគ្រូនេះ មានចំណេះ ប្រាជ្ញាជុន
ដោយស្វែងបុណ្យ ទើបតាំងខ្លួន ជាអ្នកប្រាជ្ញ ។
កាលគ្រូនេះ ពោលថាកម្ម គ្មានឲ្យផល
ទ្រង់គួរឆ្ងល់ ផ្តល់សួរវិញ ដោយអង់អាច
ថាពួកមនុស្ស ខុសផ្សេងគ្នា ដោយល្ងង់ប្រាជ្ញ
តើអំណាច របស់អ្វី ធ្វើឲ្យផ្សេង ? ។
ដូចកូនស្តេច ប្រសូតពី ឧទរមួយ
ខ្លះឥតព្រួយ មានប្រាជ្ញា ថ្វាយល់ឈ្វេង
ខ្លះល្ងង់ល្ងឹត ប្រាជ្ញាអន់ ទន់ក្រៃលែង
ខ្លះខែងវ៉ែង បានសោយរាជ្យ អំណាចវែង ។
ខ្លះគថ្លង់ អន្ធខ្វិនខ្វង់ ពីកំណើត
ខ្លះភ្នែកស្ងើត ភ្នែកងងឹត ដិតសូវឲ្យឈឺង
ខ្លះកើតមក ឥតពិការ កាយសក្តឹង
ការផ្សេងហ្នឹង គួរចង់ដឹង តើព្រោះអ្វី ?
សត្វផ្សេងគ្នា ពិតគឺជា ដោយសារកម្ម
កម្មតែងចាំ នាំបំបែរ ប្រែប្រក្រតី
កម្មជាពូជ ដូចដៅពង្ស មិត្រក្សាប្រិយ
កម្មកាត់ក្រើ ធ្វើសត្វឲ្យ អាក្រក់ល្អ ។

កម្មនាំសត្វ ឲ្យប្រាជ្ញល្ងង់ អង្គតមគាក់
ឲ្យខ្វិនខ្វាក់ ក្អែកងងឹត ឬថ្លង់គ
ពីកំណើត ស្រេចតែម្តង ក៏មានមក
ដួនកាលល លបឲ្យផល ដល់ខ្លួនចាស់ ។

ខ្ញុំកូនស្រី មានក្តីឆ្ងល់ នឹងគ្រូគុណ
ដែលថាបុណ្យ ទាំងថាបាប គ្មានផលច្បាស់
ចុះហេតុអ្វី ថ្វីលោកបួស ខំប្រឹងណាស់
ការណ៍នេះច្បាស់ ពិតជាជាន់ ជើងខ្លួនឯង ។
ព្រោះការបួស ប្រតិបត្តិ កាត់កិលេស
ឲ្យវិសេស បរិសុទ្ធ ផុតគ្រឿងស្មែង
កិច្ចទាំងនេះ ចាត់ពប់ថា កម្មនោះឯង
បើផលស្តែង ឥតមានទេ ម្តេចក៏បួស ។
មួយទៀតថា ទានសីលា ឥតឲ្យផល
ការដែលយល់ បែបយ៉ាងនេះ គឺយល់ជ្រួស
ដ្បិតទានសីល ជាគុណមួយ ជួយជុលជួស
ឲ្យពួកសត្វ ៈចរបួស នាលោកិយ ។
ដូចឲ្យទាន ទុកជាស្ពាន ចងភ្ជាប់មិត្រ
ឲ្យមានចិត្ត រាប់រកគ្នា ជាមេត្រី

បើខ្វះទាន គ្មានការឲ្យ គេបានអ្វី
ឲ្យមានក្ដី ស្និទ្ធស្នេហា ករុណា ។
ម្ល៉ោះសមបុត្រ ហ៊ានខតយុទ្ធ ទឹងម៉ែង
កស្ត្រូទៅ លែងគោរព ព្រះរាជា
ពួកនិស្សិត លែងកោតខ្លាច គ្រូនានា
ទាំងភរិយា លែងជឿស្ដាប់ គោរពប្ដី ។
ការឲ្យទាន មានកម្រៃ ទៅជាតិមុខ
ឲ្យរួចទុក្ខ ទុកវេទនា ទលក្រក្រី
បើមានគ្រោះ គ្រោះកំហុស គេប្រណី
មានកក្ដី មេត្រីជួយ ឲ្យទោសឃ្លាត ។
ចំណែកសីល ជាគុណមួយ ជួយលំអ
ឲ្យចិត្តស ល្អស្អាតស្អំ សមមនុស្សជាតិ
ពួកមនុស្សយើង បើគ្មានសីល ដូចគេស្រាត
ឬខ្ជូបជាតុ ជាតិកែល រល់ដួងថៃ ។
ទៅជាមនុស្ស ហ៊ានលួចលាក់ ចាក់សម្លាប់
ហ៊ានកយកាប់ ចាប់ប្រពន្ធ ជនដទៃ
ក្លាយជាមនុស្ស មានទោសទណ្ឌ ធ្ងន់ធំក្រៃ
ជនដទៃ ខ្ពើមវិស័យ ដូចគម្រង់ ។

ការគាន់សីល ផ្តិលមន្ទិល ក្នុងសន្តាន
អាចពាញប្រាន ទុក្ខទោសពៃរ៍ ភ័យខ្សីនខ្សន់
ឲ្យឃ្លាតចេញ ដេញឲ្យឆ្ងាយ ចាករូបអង្គ
ឲ្យគម្រង់ ក្នុងក្តីសុខ នៅលោកិយ ។

ក្នុងបរលោក សីលកំយោគ ជួយប្រសិទ្ធ
ឲ្យជួនចិត្ត ជួនវិញ្ញាណ មានសួស្តី
ធ្វើដំណើរ ដើរទៅកាន់ ភពជាថ្មី
ដោយសិរី ជ័យមង្គល សុខក្រៃលែង ។

ម្តាយឪពុក គ្រូគុណទុក ជាគ្មានគុណ
កិច្ចការុណ្យ[១] មកលើកូន ដោយជាក់ស្តែង
ជាភារៈ លើម៉ែឪ ត្រូវប្រឹងប្រែង
ថែកូនឯង ឲ្យរស់ពន មានសុខសាន្ត ។

ចុះភារៈ អ្នកជាកូន តើយ៉ាងណា
ម្តេចមិនថា តាមទំនង ទងដើមដាន
ត្រូវធ្វើម្តេច ចំពោះលោក ជាកល្យាណ
ម្តេចក៏ហាន ថាមិនបាច់ តបគុណលោក ។

---

១ ការុណ្យ ជាពាក្យសំស្ក្រឹត បាលីថា ករុណា បានន័យថា សេចក្តីករុណា, ការអាណិត, អាសូរ ។

លោកធ្វើមុន[១] គេសងគុណ[២] នេះការៈ
នៃនរៈ អ្នកមានធម៌ ល្អមានៈជាត
ដូចម៉ែឪ ត្រូវមុខកូន សងគុណលោក
តាមប្រយោគ ដែលលោកធ្វើ មកលើយើង ។
កាលដែលកូន នៅខ្ចី វ័យនៅក្មេង
ម៉ែឪតែង មានការៈ ថ្នាក់ថ្នមស្ងួន
ដល់ឪម៉ែ ប្រែចាស់ជរា ទោរទន់ខ្លួន
ការៈកូន ត្រូវថែថ្នម ចិញ្ចឹមវិញ ។
ប្រពៃណី នៃមនុស្សយើង គ្រប់ជាន់ថ្នាក់
តែងជាប់ធ្លាក់ ទាក់ទងគ្នា ជាប្រដេញ
ដូចសិស្សគ្រូ គួនឹងគ្នា ត្រូវបំពេញ
ការៈវិញ តាមនាទី ទៅរកគ្នា ។
ការៈគ្រូ ត្រូវប្រឹតប្រៀន បង្រៀនសិស្ស
ឲ្យប្រតិស្ឋ តំកល់ខ្លួន ស្ងួនវិជ្ជា
ការៈសិស្ស ត្រូវជឿស្តាប់ ផ្គាប់គារវ
ត្រូវវន្ទា ធ្វើដូចគ្នា នឹងម៉ែឪ ។

---

១ បុព្វការីបុគ្គល ។ ២ កតញ្ញូកតវេទីបុគ្គល ។

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

## ការអានពាក្យវប្បធម៌

លោក ឃួច-គីធៀង

សាស្ត្រាចារ្យនៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ រៀបរៀង

---

ពាក្យវប្បធម៌ គឺជាពាក្យដែលប្រកបដោយសារៈប្រយោជន៍ ហើយសំខាន់យ៉ាងក្រៃលែងផង ក្នុងបច្ចុប្បន្នកាលនេះ សម្រាប់យុវជនខ្មែរ ព្រោះជាពាក្យ ដែលគណៈកម្មការខាងបកប្រែតាមផ្លូវការ សុទ្ធតែបានអនុមតិជាឯកច្ឆន្ទថា យកជាការបាន ។ ពាក្យវប្បធម៌ទាំងនោះ ច្រើនតែប្រែចេញមកពីអារ្យភាសា គឺភាសាបាលីនិងសំស្រ្កឹតដែលជាភាសាបរទេស ដូចជាភាសាបារាំង និងអង់គ្លេស (ល) ក្លាយចេញមកពីភាសាឡាតាំង និងក្រិកដែលជាភាសាបរទេសដូច្នោះដែរ ។ ប៉ុន្តែបើគ្រាន់តែគណៈកម្មការវប្បធម៌បានបកប្រែទុកឲ្យយើងប្រើប្រាស់ ហើយយើងមិនចេះប្រើប្រាស់ឲ្យបានត្រឹមត្រូវ ក៏ឈ្មោះថា យើងដែលជាអ្នកទទួលប្រើប្រាស់ពុំទាន់បានបំពេញការកិច្ចរបស់ខ្លួននៅឡើយដែរ ប្រៀបបាននឹងបុគ្គលដែលគេឲ្យគ្រឿងសំលៀកបំពាក់ហើយ មិនចេះយកទៅស្លៀកពាក់គុបតែងកងកាយ ។

ពិតមែនណាស់ ក្រុមបញ្ញវន្តក្តី អបញ្ញវន្តក្តី នាបច្ចុប្បន្នកាលនេះ ច្រើនតែគិតសត្ថ ក្នុងការអានភាសាជាតិឲ្យត្រឹមត្រូវ ព្រោះគេយល់ថា ភាសាជាតិយើង បើខុសក៏មិនជាការអ្វី ។ បើអានភាសាបារាំងខុសតែបន្តិច បន្តួចទៅវិញនោះ គេនឹងរញ្ជួញខ្ពុន ហើយខ្មាសដូចពង្រលអីចឹង ។ សូមមិត្រទាំងឡាយកុំគិតខេមរស្មោតសិតថា " សំដីសជាតិ មារយាទ-សត្វជិ " ឡើយ ។

ការអានភាសាខ្មែរ ដោយពិសេសគឺពាក្យប្រៀធម៌មិនខុសគ្នានឹងការអានភាសាបរទេសប៉ុន្មានដែរទេ ។ ពាក្យដែលប្រែចេញមកពីភាសាបាលី ត្រូវតែអនុវត្តស្ទួរសៀងឲ្យទៅតាមក្បួនភាសាបាលី វៀរលែងតែមានពាក្យខ្លះ ដែលលាយទៅជាពាក្យខ្មែរយើងសុទ្ធសាធទៅហើយ ។ រីឯពាក្យដែលត្រូវអានទៅតាមវេយ្យាករណ៍ភាសាបាលីនោះ ខ្ញុំនឹងពន្យល់ដោយសង្ខេបដូចតទៅនេះ៖

អក្សរខ្មែរទាំង ៣២ តួ គេចែកចេញទៅជា ២ ក្រុមគឺ៖

ក្រុមទី ១

១- អក្សរ ៥ តួ គឺៈ កខគឃង ហៅថា ក្រុម ក (ក វគ្គៈ)

២- – ចឆជឈញ – – ច (ច វគ្គៈ)

៣- – ដឋឌឍណ – – ដ (ដ វគ្គៈ)

៤- អក្សរ៥តួគឺ: តថទធន ហៅថា ក្រុម ត (ត វគ្គៈ)

៥- " បផពភម – – ប (ប វគ្គៈ)

ក្រុមទី ២

អក្សរ ៧ តួ គឺ: យរលវសហ និង ឡ ហៅថា ក្រុមសេស (សេសវគ្គ) ;

ក្នុងបណ្ដាអក្សរទាំង ២ ក្រុមនេះអក្សរទី ១ និងទី ២នៃវគ្គទាំង ៥គឺ: កខ,ចឆ,ដឋ តថ, និង បផ និងអក្សរទី ៥ នៃសេសវគ្គគឺ: ស· អក្សរទាំង ១១ តួនេះហៅថា "អឃោសៈ" (soft letters) ប្រែថា អក្សរមានសម្លេងទន់ឬស្រាលឬក៏មិនគឹកកងក៏បាន ។ អក្សរទី ៣, ទី ៤ និងទី៥ នៃវគ្គទាំង ៥ គឺ គឃង, ជឈញ, ឌឍណ· ទធន, ពភម និង អក្សរ ៦ តួគឺ: យរលវហ និង ឡ ទាំង ២១ តួនេះ ហៅថា "ឃោសៈ" (hard letters) ប្រែថា អក្សរមានសម្លេងធ្ងន់ឬរឹងឬក៏គឹកកងក៏បាន ។ រីឯ អក្សរ ៥ តួគឺ: ង,ញ,ណ,ន និងម នៃវគ្គទាំង៥ និងអក្សរ ៤ តួគឺ: យរល និងវ នៃសេសវគ្គ– ទាំង ៩ តួនេះហៅថា "អព្យាកតក្ខរៈ" ប្រែថា អក្សរមានសម្លេងជាអព្យាក្រឹត ។ ហេតុដូចម្ដេចបានជាថាអក្សរទាំងនេះ មានសម្លេងជាអព្យាក្រឹត? ។ បានជាថាមានសម្លេងជាអព្យាក្រឹត ពីព្រោះ

អក្សរទាំងនេះ អាចអនុវត្តស្វរសៀងរបស់ខ្លួន ឲ្យនៅធ្ងន់ជាឃោសៈដូចប្រក្រតីដើមក៏បាន ឲ្យទន់ប្តូរស្រាលទៅជាអឃោសៈទៅវិញក៏បាន ស្រេចតែទីឯការបិតនៅនៃអក្សរ ។ តាមក្បួនធម្មតាអក្សរទាំង ៩ តួនេះរាប់ចូលក្នុងពួកឃោសៈ(សម្លេងធ្ងន់)ទេ តែក៏អាចប្តូរទៅជាអឃោសៈវិញបាន កាលបើវាទៅបិតនៅបន្ទាប់ទីឯអក្សរជាអឃោសៈណាមួយ, បានសេចក្តីថា អក្សរជាអឃោសៈទាំង ១១ តួនោះ អាចកាច់អក្សរជាអព្យាកតតួៈទាំង ៩ តួនេះ ឲ្យបាក់សម្លេងទៅតាមខ្លួនបានគឺ:

| | | | |
|---|---|---|---|
| អក្សរ | ង | ទៅជាព្តស្វរ | ង៉ |
| - | ញ | - | ញ៉ |
| - | ណ | - | ន៉(១) |
| - | ន | - | ន៉ |
| - | ម | - | ម៉ |
| - | យ | - | យ៉ |
| - | រ | - | រ៉ |
| - | ល | - | ល៉ |
| - | វ | - | វ៉ |

(១) នៅជា ណ ដដែល ។

ឧទាហរណ៍ខាងក្រោមនេះ នឹងបានញ៉ាំងមិត្តអ្នកអានទាំងឡាយ ឲ្យយល់ច្បាស់នូវការអានៈ

## ទុស្សនា (ល)

ពាក្យថា ទុស្សនា មាន ៣ អក្សរគឺៈ អក្សរ ទុ ជាឃោសៈ, អក្សរ ស (ស្ស) ជាអឃោសៈនឹងអក្សរ នា ជាអព្យាកតក្ខរៈ ។ អក្សរ នា ដែលជាអព្យាកតក្ខរៈបិតនៅបន្ទាប់នឹងអក្សរ ស ដែលជាឃោសៈ ។ ហេតុដូច្នេះ អក្សរ នា ត្រូវតែបញ្ចេញសូរសៀងទៅជា ន៉ា ទៅវិញ ។ ពាក្យថា មករា មាន ៣ អក្សរគឺៈ អក្សរ ម ជាឃោសៈ, អក្សរ ក ជាអឃោសៈនឹងអក្សរ រា ជាអព្យាកតក្ខរៈ ។ អក្សរ រា ត្រូវតែបញ្ចេញសូរសៀងឲ្យទៅជា រ៉ា ទៅវិញ ដោយហេតុថា ខ្លួនបានទៅនៅអាស្រ័យផែបនឹងអក្សរ ក ដែលជាអឃោសៈ ។ ពាក្យថា បលនា មាន ៣ អក្សរគឺៈ អក្សរ ប អក្សរ ល នឹងអក្សរ នា ។ អក្សរ ប សង្កត់សូរ ល ឲ្យទៅជា ល៉, អក្សរ ល៉ សង្កត់សូរ នា ឲ្យទៅជា ន៉ា, ពាក្យនេះទៅជាអានថាៈ (បៈល៉ៈន៉ា) ។ ពាក្យថា អតិបរមា មាន ៤ អក្សរ, អក្សរ រ ទៅជា រ៉ ព្រោះនៅជិត ប, កាលបើ រ ទៅជា រ៉ ហើយ អក្សរ មា ក៏ត្រូវទៅជា ម៉ា ដែរ ។ រីឯពាក្យថា ការិយាល័យ វិញ ដោយអំណាចអក្សរ កា, រិ ទៅជា រ៉ិ, យា ទៅជា យ៉ា, ល័យ ទៅជា ល៉័យ ។

## ឧទាហរណ៍បន្ថែម

| | |
|---|---|
| ភាសា | សមាធិ |
| ទេសនា | គុណ |
| ឧបមា | ទស្សនាវដ្តី |
| កញ្ញា | អប្បបរមា |
| សាលា | បណ្ណាល័យ |

ពាក្យថា " អនុស្សាវរីយ៍ " ។ល។ ត្រូវតែអានឲ្យឮថា . . រី (កុំថា រ៉ី) ព្រោះជាអញ្ញត្រសព្ទ (exception) ។

ស្រៈទាំង ៨ តួគឺៈ អ, អា, ឥ, ឦ, ឧ, ឩ, ឯ, ឱ, ក៏ជាអឃោសៈ ដែលអាចទាញសម្លេងអក្សរជាអព្យាកតក្ខរៈ ឲ្យផ្តកទៅតាមខ្លួនបានដែរ ។

ឧទាហរណ៍:

អនាគត អានថា អៈ- ណ៉ា- គត់- ។ល។

កាលបើអព្យាកតក្ខរៈនោះឯង ទៅបិតនៅបន្ទាប់នឹងអក្សរជាឃោសៈ សូរសៀងរបស់វាត្រូវតែដើរតាមសូរអក្សរជាឃោសៈ ។ ឧទាហរណ៍ខាងក្រោមនេះ នឹងធ្វើអ្នកអានឲ្យបាត់សេចក្តីសង្ស័យ ៖

# សទ្ធា (ស)

ពាក្យថា សទ្ធា មាន ៣ អក្សរគឺៈ អក្សរ ស, អក្សរ ទ (ទ្ធ) និង អក្សរ ធា ។ អក្សរ ធា ដែលនៅបន្ទាប់នឹង ទ ដែលជាឃោសៈ ត្រូវមានសិទ្ធិរក្សាសម្លេងរបស់ខ្លួនឲ្យនៅជា ធា ដូចប្រក្រតីដើមវិញបាន ។ ពាក្យថា វិទ្ធា មាន ៣ អក្សរ, អក្សរ ធា នៅជាធា ដដែល ។ ពាក្យថា គមធាគមន៍ មាន ៤ អក្សរ, អក្សរ ធា (អព្យាកតក្ខរៈ) ដែលបិតនៅបន្ទាប់អក្សរ ម ដែលជាឃោសៈនោះ ឥតត្រូវគេបន្ថែមឲ្យផ្លាស់សូរសៀងទេ គឺនៅជា ធា ដដែល ។ ពាក្យថា គណធា មាន ៣ អក្សរ, អក្សរ គ ធ្វើសូរ ណា ឲ្យក្លាយទៅជាសូរ ង រីឯ ធា នៅជា ធា ដដែល ។

សេចក្ដីពន្យល់អំពីការអានពាក្យប្រែធម៌ គឺពាក្យខ្មែរដែលជាប់ទាក់ទងដោយភាសាបាលី ដូចបានអធិប្បាយដោយសង្ខេបមកខាងលើនេះ ប្រាកដជានឹងផ្ដល់នូវពន្លឺដល់មិត្រយើងអ្នកស្នេហាអក្សរសាស្ត្រជាតិ បានខ្លះពុំខានឡើយ ។ អ្នកសរសេរដឹងច្បាស់ថា សេចក្ដីពន្យល់នេះពុំទាន់សព្វគ្រប់នៅឡើយទេ ប៉ុន្តែ សូមមេត្តាជ្រាបថា "មានគ្រាន់បើជាងគ្មាន" ។

---

## ពាក្យខ្មែរប្រែចេញពីបរទេស
## ដោយគណៈកម្មការវប្បធម៌

( តមក )

| | | |
|---|---|---|
| Civilité | *n.f.* | សេចក្ដីគួរសម |
| Méningite cérébro-Spinale | | រលាកខួរក្បាល, ឆ្អឹងខ្នង |
| Poliomyélite | *n.f.* | គ្រុនស្វាប់អវយវៈ |
| Trypanosomiase | *n.f.* | រោគងងុយ |
| Piroplasmose Aiguë | | ពីរ៉ូប្លាស្មុស |
| Alastrim | | អាឡាស្ដ្រាំ(អុតធំនៅប្រទេសអាហ្វ្រិក) |
| Coqueluche | *n.m.* | ក្អកមាន់ |
| Grippe-influenza | | គ្រុនផ្ដាសាយធ្ងន់ |
| Pneumonie | *n.f.* | គ្រុនរលាកសួត |
| Broncho pneumonie | *n.f.* | គ្រុនរលាកទងនឹងចង់សួត |
| Erésypèle | *n.f.* | ពិសស្បែក |
| Congestion | *n.f.* | រោគស្ទាក់ឈាម |
| Accord à l'amiable | | កិច្ចព្រមព្រៀងដោយស្រុះស្រួល |
| Afférent | *adj.* | បច្ចេកកាត |
| Argenterie | *n.f.* | រជតភណ្ឌ |
| Aggravation | *n.f.* | គារុឡកម្ម. (ការធ្វើឲ្យធ្ងន់) |
| Bijoux | *n.m.* | អលង្ការ |
| Bijouterie | *n.f.* | អលង្ការភណ្ឌ, អលង្ការដ្ឋាន |
| Bijoutier | *n.m.* | ជាងទង, សុវណ្ណការ |

*(នៅមានទៀត)*

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

ព្រះមហា ចាំង . ទាត់ រៀបរៀង

(តមក)

អតិវទ៑ ធាតុ. ពោលក្រៃលែង, ពោលសរសើរ ។

អតិវត្តន នបុំ. កិរិយាប្រព្រឹត្តទៅក្រៃលែង, កិរិយារួចចាកទោស ។

អតិវត្តិន៑ គុ. ដែលប្រព្រឹត្តទៅក្រៃលែង, ដែលឆ្លងរួច ។

អតិវត្ត្យ គុ. ដែលគប្បីវៀរបង់ ។

អតិវប៌, អតិវប៌ណ នបុំ. កិរិយាភ្លៀងក្រៃលែង ។

អតិវល្លភ គុ. ដែលជាទីស្រឡាញ់ក្រៃលែង, ដែលជំនិត, ដែលថ្លៃថ្លា ។– ត្វ, នបុំ.

ភាវនៃ . . . . ជាទីស្រឡាញ់ក្រៃលែង ។

អតិវហ៑ ធាតុ. នាំទៅក្រៃលែង, បង្ហួស, ដឹកនាំ ។

អតិវា ធាតុ. បក់ក្រៃលែង (ខ្យល់) ។

អតិវាត្សល្យ នបុំ. ភាវនៃ . . . ជាទីស្រឡាញ់ក្រៃលែង ។

អតិវាទ បុំ. ពាក្យពោលក្រៃលែង, ពាក្យប្រទេច ។ សេចក្តីថ្លែងការណ៍,

ពាក្យដាច់ខាត ។

អតិវាទិន៑ គុ. ដែលពោលក្រៃលែង, ដែលប្រទេច ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ៤៧

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

( តមក )

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងរេះរកឧបាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូ - អ៊ុន

តាំងពីឡេវពីឃើញសេចក្ដីសំបុត្រខុងបេងប្លាប់ទី ៣ ហើយនាំនាងស៊ុនហ៊ូយិន រត់ទៅជួបនឹងខុងបេងបរកទូកមកទទួល ជីវយីលើកទ័ពតាមហើយចូវហ៊ូល្បងទាហាន ឡេវស៊ុកមកតារស្រុកកេងជីវ ជីវយីគិតកលឧបាយទៅវាយស្រុកសែឈួន ខុងបេងគិតត្រូវតកលជីវយីបាត់ទ័ពលើកទៅ ។

---

ឡេវពី ដឹងសេចក្ដីក្នុងសំបុត្រនោះហើយ ក៏ត្រឡប់ទៅប្រាប់នាងស៊ុនហ៊ូយិនតាមសេចក្ដីសំបុត្រនោះថា ពីដើមស៊ុនគួននឹងជីវយីគិតកលឧបាយថានឹងលើកប្អូនឯងឲ្យធ្វើជាភរិយាបង ប៉ុន្តែនឹងបញ្ឆោតបងឲ្យមកឯស្រុកឡាំស៊ី ហើយចាប់ខ្លួនបងដាក់គុក បើបង្វិលស្រុកកេងជីវឲ្យវិញកាលណា នឹងប្រហារជីវិតបងចេញកាលណោះ មិនមែនឲ្យប្អូនដោយស្មោះត្រង់ទេ គឺយករូបប្អូនធ្វើជានុយទៅបញ្ឆោតឲ្យបងមក, មួយទៀតបង

ដឹងច្បាស់ថា ខ្លួនប្អូនជាស្រីក៏មែន តែមានគម្រេះប្រាជ្ញាចេះរិះគិតលើស ជាងប្រុសទៅទៀត បានជាបងប្រថុយខ្លួនមកកេប្អូនមិនមានខ្លាចសេចក្ដីស្លាប់ នេះព្រោះមាតានឹងកៀកកុកឡើងមានសេចក្ដីមេត្តា បានជាបងរួចពាកសេចក្ដីស្លាប់ បានកប់ប្រុសពូនឹងប្អូនរហូតមក ឥឡូវស៊ុនគួននឹងជីវយ៉េចេះតែគិតកលទុបាយផ្សេងៗ ដោយចិត្តបង់វេកព្យាបាទប្រាថ្នានឹងធ្វើអន្តរាយជីវិតបងៗ យល់ថា នៅកងស្រុកឡើងស៊ុតទៅ មុខជាមិនរួចពីសេចក្ដីស្លាប់ ទើបប្រញាប់គិតត្រឡប់ទៅស្រុកកេងជីវវិញ ហើយក៏ទូងប្រាប់ប្អូនថា ស្រុកកេងជីវកើតសឹកនឹងស្រុកទៅធ្វើការសង្គ្រាមជាប្រ-ញាប់ ប្អូនក៏មានចិត្តជាសត្យពិតត្រង់នឹងបងជាចចិត្តជិតដោយតាមមកផង ដោយស្នេហាអាល័យ គុណប្អូនជំធំក្រាស់ក្រៃនឹងរកពុំផុតគ្មាន បងក៏នៅមិនទាន់បានតបស្នងគុណសោះ, គ្រានេះ ស៊ុនគួនក៏គ្មានចិត្តសប្បុរសទុកយើងជាបងប្អូន លើកទ័ពតាមពាក់ពួនតាមមកទៀតច្រើនណាស់ ចាំងជីវយ៉េខាងនេះក៏ឡូតាហាននមកចាំស្ទាក់ពីមុខ បងនឹងធ្វើទុក្ខជាច់ជីវិតយើងហើយ ឯទាហានចាំងសងខាងនេះក៏នៅកងអំណាចប្អូន បើប្អូនមិនជួយតែខ្វៃហើយ បងក៏ត្រូវតែស្លាប់កងថ្ងៃនេះជាប្រាកដ ដែលជីវិតបងនឹងស្លាប់បងក៏មិនសោកស្ដាយប៉ុន្មាន នឹកស្ដាយតែប្អូនកល្យាណ

បងមិនទាន់បានតបស្នងសងគុណប្អូន ដែលទៀងត្រង់សុចរិតចំពោះបង នោះពន់ប្រមាណណាស់ ។

នាងស៊ុនហ៊ួយិនឮដូច្នោះ សោមនស្សត្រូវចិត្តចំពោះស៊ុនគួនខ្លាំងណាស់ ទើបចេញពាក្យថា ដែលស៊ុនគួនធ្វើខ្លាំងម៉្លេះ គឺលះបង់អាល័យនៃសាច់ឈាមដែលជាបងប្អូននឹងគ្នាអស់ហើយ ម៉្លេះហើយនឹងត្រឡប់ទៅមើលមុខស៊ុនគួនវិញធ្វើម្ដេចបាន ការខ្លាំងប៉ុន្មានក្នុងគ្រានេះ ខ្ញុំក៏សុំរិះគិតកែខៃឲ្យរួចភ័យអន្តរាយតាមប្រាជ្ញាខ្ញុំចុះ នាងស៊ុនហ៊ួយិនក៏ឲ្យមនុស្សបំរើប្ដូរសក់ឡើងស្រឡះមុខមាត់ ហើយក៏ឡើងបររថស្រូតទៅ ឃើញឈីសេង, គេងហង លើកកងទាហានទៅស្ទាក់ពីមុខ នាងស៊ុនហ៊ួ-យិនក៏ស្រែកថា ខ្ញុំទាំង ២ នាក់មកធ្វើការយ៉ាងនេះ ប្រុងនឹងប្រហារជីវិតអញឬ? ឈីសេង, គេងហងឮដូច្នោះ ក៏ស្លុតស្លាំងកាំងកាំងស្មារតី លោតចុះពីលើសេះបោះអាវុធផុតពីដៃ ហើយចូលទៅគំនាប់នាងស៊ុនហ៊ួយិនពីមុខរួចហើយថា យើងខ្ញុំឥតបានរិះគិតដោយគំនិតឯងក្លែងមកធ្វើអន្តរាយអ្នកកិះទេ ជីវយប្រើយើងខ្ញុំឲ្យនាំទាហានលើកមកចាប់ទៀតទេ ។

(នៅមានត)

# រឿងព្រេងចិន

លោក ហ៊ុយ.ប៊ុនគា ប្រែរៀបរៀង

(តមក)

ជាងឈើ ក៏ចូលទៅក្រាបបង្គំគាល់ព្រះមហាក្សត្រ ហើយបានយកសេះឈើមួយមកថ្វាយព្រះអង្គ ។

ព្រះរាជាទ្រង់មិនសប្បាយព្រះរាជហឫទ័យសោះ ដោយទ្រង់ទតទៅឃើញសេះឈើនោះហើយ ទ្រង់មានព្រះរាជឱង្ការថា :

" ម្តេចក៏លោកយកល្បែងក្មេងមកដូច្នេះ ! តើម្តេចនឹងប្រៀបធៀបទៅនឹងត្រីដែកនៃជាងដែកបាន ! " ។

ជាងឈើក៏ក្រាបបង្គំទូលព្រះរាជាថា: " សេះឈើនេះ ប្រសើរជាងត្រីដែក; សេះឈើនេះ មានកូនសោម្ភៃប្រាំមួយនៅលើកងកាយវា ។ កូនសោទីមួយចាក់មួលទៅធ្វើឲ្យសេះឈើហោះ, កូនសោទីពីរសម្រាប់ញ៉ាំងសេះឲ្យមានល្បឿន, បើគេចាក់កូនសោទាំងអស់. សេះនោះកាន់តែហោះលឿន ៗ ទៅ. រហូតដល់សោទីម្ភៃប្រាំ. សេះនោះក៏ហោះកាន់តែលឿនមែនទែនដូចជាបក្សា ។ សេះនេះ. គេអាចជិះវាហោះធ្វើដំណើរជុំវិញលោកបាន ។

គ្រានោះ ព្រះអង្គម្ចាស់ជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ដែលទ្រង់គង់ប្រថាប់នៅជិតព្រះវរបិតាទ្រង់សព្វព្រះរាជហឫទ័យ នឹងសេះឈើនោះណាស់, ទ្រង់មានព្រះរាជបំណងចង់ធ្វើព្រះរាជដំណើរទៅលើអាកាស, បានសូមព្រះរាជានុញ្ញាតព្រះវរបិតា ឲ្យទ្រង់ពិសោធទូវសេះឈើនេះ ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជឧត្ដរទៅកាន់ព្រះរាជបុត្រថា: "អ្នកណាថា សេះឈើនេះ អាចហោះទៅលើអាកាសបាន ? ហើយបើហោះទៅ សេះនោះក៏ធ្លាក់មកដី, តើក៏យ៉ាងម្ដេចទៅ ? ។

ជាងឈើក៏ក្រាបបង្គំទូលថា: " សូមទ្រង់ព្រះមេត្តាប្រោស ! សេះឈើនោះមិនធ្លាក់ទេ " ។

ព្រះអង្គម្ចាស់ ទ្រង់មានព្រះបន្ទូលអង្វរព្រះវរបិតាជាច្រើនលើកច្រើនគ្រា ។ ព្រះវរបិតា ក៏ទ្រង់ព្រះរាជានុញ្ញាតឲ្យព្រះរាជបុត្រសាកល្បងមើលសេះនោះតាមព្រះបំណង, ហើយទ្រង់មានព្រះរាជឧត្ដរផ្ដាំថា, កូនឯងត្រូវមួលតែកូនសោមួយទេ, ហើយហោះហើរបន្តិចម្ដងៗ កុំបង្ខំពេក ។

ព្រះអង្គម្ចាស់ទ្រង់បានសន្យានឹងព្រះវរបិតាថា: ទូលព្រះបង្គំនឹងប្រតិបត្តិតាមព្រះរាជបញ្ជាមិនហ៊ានធ្វេសប្រហែសឡើយ, រួចទ្រង់គង់លើសេះឈើនោះយកកូនសោទីមួយមកចាក់ ស្រាប់តែសេះនោះហោះទៅលើអាកាស ទ្រង់បានទតមកក្រោមឃើញមនុស្សក្រុះករ, ព្រៃ, រុក្ខជាតិ, ទន្លេ,

ភ្នំតូច-ធំស្ថិតនៅដេរដាសពាសពេញប្រឹថពី... ។ ទតឃើញដូច្នោះហើយ ព្រះអង្គម្ចាស់មានព្រះហឫទ័យសោមនស្សពន់ពេក, ទ្រង់មួលកួនសោមួយទៀត, រួចមួលកួនសោទីបីរហូតដល់កួនសោទីម្ភៃប្រាំមួយ ។ សេះនោះក៏ហោះកាន់តែលឿនឡើង ។ បន្ទាប់មក, ទ្រង់បានទតឃើញមនុស្សដែលយល់អម្បាញ់មិញនេះកាន់តែឆ្ងាយទៅៗ តមកទៀត ទ្រង់ទតលែងឃើញរុក្ខជាតិ ទឹងទីក្រុងផ្សេងៗ ទ្រង់គង់តែលើសេះហោះនោះពាល់តែឃ្លានព្រះស្ងោយ ស្រាប់តែទតមកខាងក្រោមម្តងទៀតឃើញទីក្រុងមួយ, បានមួលកួនសោបញ្ច្រាសមកវិញ ។ សេះនោះក៏បន្ថយល្បឿនបន្តិចម្តងៗ ហើយចុះមកដល់ដី ។ ព្រះអង្គម្ចាស់ទ្រង់ចូលទៅក្នុងភោជនីយដ្ឋានមួយដើម្បីនឹងទ្រង់សោយព្រះក្រយា ទ្រង់ក៏មានព្រះហឫទ័យសោមនស្សជាយ៉ាងខ្លាំង ដោយទ្រង់ធ្វើព្រះដំណើរក្នុងពេលមួយរំពេចសោះ ស្រាប់តែមកដល់ទីនេះ ។

ព្រឹកឡើង ព្រះអង្គម្ចាស់ទ្រង់យាងទស្សនាទីក្រុង បានយាងទៅដល់កន្លែងមួយដែលមានមនុស្សម៉ឺរដេរដាស ក៏ទ្រង់ពិគល់ថា នៅទីនោះប្រហែលជាមានរបស់អ្វីប្លែកហើយ បានជាពួកមហាជននាំគ្នាចោមរោមច្រើនម្ល៉េះ ។

(នៅមានត)

# ភូមិសាស្ត្រសេដ្ឋកិច្ចនៃសហភាពអាហ្វ្រិកខាងត្បូង

លោក រ៉ូបារ្ទ មែបែរស៍ អតីតសាស្ត្រាចារ្យ

នៃមហាវិទ្យាល័យច្បាប់ប្រទេសកម្ពុជា បាទនិពន្ធក្នុងឆ្នាំ ១៩៥៩-៦០

លោក ភៀម-ចឹម ប្រែសម្រួល

(តចប់)

សម្បត្តិរ៉ែ : សហភាពអាហ្វ្រិកខាងត្បូង ជាប្រទេសសម្បូរពេជ្រជាងគេបង្អស់ក្នុងសកលលោកគឺ ២/៣ នៃផលិតផលពេជ្រក្នុងសកលលោក បានចេញមកពីប្រទេសនេះ ។ អណ្តូងរ៉ែដែលចាស់ជាងគេស្ថិតនៅក្នុងរដ្ឋអូរ៉ង់ ជិតគិមបែរឡេ ។ ពេជ្រដែលគេយកបានស្ថិតនៅក្នុងបំពង់នៃភ្នំភ្លើងដែលរលត់ ។ ដើម្បីនឹងបានមាស គេត្រូវជីកជ្រៅជាគេជីកយកត្បូងថ្មដែរ ។

អណ្តូងរ៉ែពេជ្រថ្មីទៀត ទើបនឹងរកឃើញ នៅក្នុងរដ្ឋត្រង់ស្វាល់ជិតទីក្រុងប្រេតូរីយ៉ា ។

មានសហជីពពួកផលិតករ ដើម្បីដំឡើងថ្លៃទំនិញ (trust) មួយជាអ្នកត្រួតត្រាលើផលិតផលពេជ្រ ហើយជាក្រុមហ៊ុនមានសិទ្ធិលក់ពេជ្រផ្តាច់មុខក្នុងសកលលោក ។

ចំពោះផលិតផលមាសវិញ ក៏មានសារៈសំខាន់ណាស់ដែរ គឺសហភាពអាហ្វ្រិកខាងត្បូងនេះហើយ ដែលជាប្រទេសមានមាសច្រើន

ជាងគេក្នុងសកលលោក ។ ក្នុងមួយឆ្នាំ ៗ ប្រទេសនេះយកមាសបាន ចំនួន ៤៥០ តោន ចំនួននេះស្មើនឹង ៥០ ភាគរយ (៥០%) នៃផលិតផលសកលលោក ។

អណ្តូងរ៉ែមាសដែលគេរកឃើញមុនគេ ស្ថិតនៅក្នុងខេត្តត្រង់ស្វាល់ ជិតទីក្រុងហ្សូហាន់ណេស្បួរ ។ អណ្តូងរ៉ែមាស មានជំរៅជ្រៅណាស់ ជួនកាលដល់ទៅ ៣.០០០ ម៉ែត្រក៏មាន ។ ដូច្នេះឃើញថា គេស្ការយក អាចដីសម្បើមណាស់, ព្រោះក្នុង១តោនដី មានមាសតែ ៥ ដល់២០ក្រាម ប៉ុណ្ណោះ ។ បន្ទាប់មក, គេយកមាសដែលគេយកចេញពីដី ទៅរំលាយ ក្នុងរោងចក្រ ។ មានកម្មករចំនួន ៣៥០.០០០ នាក់ បានធ្វើការនៅ ក្នុងអណ្តូងរ៉ែទាំងឡាយ ។

នៅក្នុងសម័យមហាសង្គ្រាមសកលលោកលើកទីពីរ គេបានរកឃើញដុំលោហធាតុ (gisements) មាសជាច្រើនកន្លែងទៀត នៅក្នុងរដ្ឋអូរ៉ង់ តែចំណែកឯអណ្តូងរ៉ែ នៅក្នុងរដ្ឋត្រង់ស្វាល់ទៅជាចង់អស់មាសទៅវិញ ។ ជាមួយនឹងមាសនេះ គេមានយកបានលោហធាតុមួយយ៉ាងទៀត ហៅថា អ៊ុយរ៉ានីញ៉ូម ដែលសហភាពអាហ្វ្រិកជាប្រទេសមួយសម្បូរលោហធាតុនេះជាងគេក្នុងសកលលោក ។ សហភាពអាហ្វ្រិកខាងត្បូង បានដឹកនាំអ៊ុយរ៉ានីញ៉ូមនេះ ទៅលក់ឯប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិក ។

ក្រៅពីនេះ សហភាពអាហ្វ្រិកខាងត្បូងជាប្រទេសលេខ ១ ក្នុងសកលលោកខាងផលិតផលប្លាទីន ។ ជាទីបញ្ចប់នៅក្នុងសហភាពអាហ្វ្រិកខាងត្បូង, គេសង្កេតឃើញមានលោហធាតុផ្សេង ៗ ទៀតដូចជាត្បូងថ្ម (៣៦ ០០០.០០០ តោន) រ៉ែដែក, ម៉ង់ហ្គាណែស, ក្រូម (១)

អំពីឧស្សាហកម្មសំខាន់ ៗ៖

មកទល់នឹងសង្គ្រាមលោកលើកទីពីរ, ប្រទេសនេះមានតែឧស្សាហកម្មធ្វើគ្រឿងបរិភោគ, ប៉ុន្តែ តាំងពីសង្គ្រាមសកលលោកលើកទីពីរតទៅ, ពោលឧស្សាហកម្មផ្សេង ៗ ទៀតបានកើតឡើងជាច្រើន ៗ ពោលឧស្សាហកម្មស្ល៍ដែកមួយយ៉ាងធំ បានសង់នៅជិតប្រេតូរីយ៉ា, ផ្តល់ដែកថែបបានក្នុងមួយឆ្នាំចំនួន ១.០០០.០០០ តោន ។ ដោយសារដែកថែបនេះ, គេក៏បានបង្កើតគ្រឿងសម្ភារៈសម្រាប់អយស្ម័យយាន, គ្រឿងយន្តសម្រាប់ធ្វើរបរកសិកម្ម, កប៉ាល់ នឹងរថយន្ត ។

ពោលចក្រយន្តកណ្ដាញ (Industrie textile) ក៏រីកចំរើនដែរ ។ ពោលចក្រនេះ មានធ្វើរោមចៀមនឹងកប្បាស ។

ឧស្សាហកម្មគីមីក៏កើតមានដែរ ហើយបានធ្វើជី ស៊ីម៉ង់ត៍, ធ្វើថ្នាំ សម្រាប់ជ្រលក់ពណ៌ (Colorant) ។ល។

---

(១) ជាលោហធាតុម្យ៉ាងមានពណ៌ស រឹង ព្រោះមិនចាប់ សំរាប់លាបលើដែកផ្សេង ៗ ដែលយើងហៅថា ដែកក្រូម៉េ ។

មនោព្យាបាយដឹកនាំនិងពាណិជ្ជកម្ម៖

សហភាពអាហ្វ្រិកខាងត្បូងមានផ្លូវដែកល្អ ហើយវែងប្រវែង ២២.០០០ គីឡូម៉ែត្រ ។ ផ្លូវដែកច្រើនស្ថិតនៅប៉ែកខាងកើតនៃប្រទេស ។ ផ្លូវថ្នល់ក៏ល្អគ្រាន់បើដែរ ហើយសហភាពអាហ្វ្រិកខាងត្បូងមានកំពង់ផែយ៉ាងល្អ ។ ឯកំពង់ផែដែលធំជាងគេ មានពីរគឺៈ ឌឺបាប់ និងកេបថោន ។

ជំនួញក្រៅប្រទេសមានសារៈសំខាន់យ៉ាងសម្បើម គឺផ្តល់ប្រាក់ចំណេញយ៉ាងច្រើនដល់ប្រទេស ។

ផលិតផលសំខាន់ៗ ដែលគេនាំចេញទៅលក់នោះគឺៈ មាស, អ៊ុយរ៉ាញ៉ូម, ពេជ្រ និងរោមចៀម ។

ក្រៅពីនេះ គេអាចរាប់បន្ថែមនូវផលិតផលឯទៀតៗ ដូចជា ស្រូវសាលី, គ្រាប់ពោតសាត់, ស្រាទំពាំងបាយជូ ។

សហភាពអាហ្វ្រិកខាងត្បូងត្រូវការទិញផលិតផលផ្សេងៗ ចូលមកវិញមានដូចតទៅនេះៈ ផលិតផលកម្មន្តសាល, និងគ្រឿងសម្ភារៈខាងបរិក្ខារ ។

កាលពីឆ្នាំ ១៩៣៩ មួយចំណែកធំនៃពាណិជ្ជកម្ម បានធ្វើជាមួយនឹងប្រទេសអង់គ្លេស ។ ប៉ុន្តែចាប់តាំងពីពេលនោះមក, សហភាពអាហ្វ្រិកបានធ្វើជំនួញជាច្រើនជាមួយសហរដ្ឋអាមេរិកវិញ ហើយមានបំណាក់ទុន

ដកខ្លួនចេញពីសហគមអង់គ្លេស ប៉ុន្តែនៅស្ទាក់ស្ទើរចិត្តបន្តិច ដោយសារប្រទេសខ្លួន នៅត្រូវការអ្នកបច្ចេកទេសជាតិអង់គ្លេស និងដើមទុនអង់គ្លេសជាការចាំបាច់ ។

## សេចក្តីសន្និដ្ឋាន:

បញ្ហាដ៏សំខាន់ជាងគេ ដែលកើតឡើងនៅក្នុងសហភាពអាហ្វ្រិកខាងត្បូងសព្វថ្ងៃ គឺបញ្ហាមនុស្ស គឺបញ្ហាស្តីពីការប្រាស្រ័យទាក់ទងគ្នារវាងពួកស្បែកសនិងពួកស្បែកខ្មៅ ។ បើសិនជាបញ្ហានេះនៅតែកើតទៅទៀតនោះ, មិនយូរប៉ុន្មាន, ពួកជនជាតិស្បែកខ្មៅដែលជាម្ចាស់ស្រុកពិតប្រាកដ ។ ជាបញ្ចេញកំហឹងរបស់ខ្លួនឲ្យឃើញជាក់ស្តែងពុំខាន ។

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ទំនៀមទម្លាប់ នៃខេមរជាតិ
ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
ព្រោះខេមរជាតិ ជាជាតិសោភី
ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។

ប.ព

## រឿងព្រេងប្រារព្ធសុភាសិត ៤ បទៈ

១- ឃ្មាតទំអត់ ៣- គេឲ្យច្រើនកុំយក

២- ខ្សត់ទំរក ៤- ទ្វាបឲ្យជួលជិត

កាលពីអតីតកាល មានរឿងមួយដំណាលថា: មានបុរសម្នាក់ អាយុ ២០ ឆ្នាំ ម្តាយឪពុករៀបចំឲ្យមានប្រពន្ធ ។ លុះរៀបអាពាហ៍ពិពាហ៍រួចហើយ បុរសប្តីប្រពន្ធទំរកស៊ីតាមធម្មតា ។ ឪពុកម្តាយខាងប្រុស-ស្រី បានចែកទ្រព្យសម្បត្តិ ឲ្យបន្តិចបន្តួចស្តួចស្តើង ដោយខ្លួនជាមនុស្សទីទ័លក្រដែរ ។

បុរសប្តីប្រពន្ធបានចាយវាយកេរ្តិ៍មត៌កពីឪពុកម្តាយអស់ ក៏ធ្លាក់ខ្លួនទៅជាមនុស្សទីទ័លក្រ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក ។ បុរសនោះ មានសេចក្តីព្រួយជាខ្លាំង ដោយការធ្លាក់ខ្លួនទៅជាមនុស្សក្រខ្សត់ លំបាកវេទនាពន់ពេក ដេកកុំលក់ ។

ថ្ងៃមួយ បុរសនោះអង្គុយគិតតែម្នាក់ឯងថា "ខ្លួនអញក្រនេះមកពីអ្វី ? រកគិតពុំឃើញ" ។ មួយសន្ទុះក្រោយមក ក៏នឹកឃើញថា "ខអញក្រនេះមកពីគ្មានចំណេះវិជ្ជា អញឮស្មុកាសិតមួយគេនិយាយថា "អ្នកណាមានចំណេះវិជ្ជា អ្នកនោះអាចប្រមូលបាននូវមិត្រច្រើន បើមានមិត្រច្រើនហើយ មុខជានឹងចំរើនដោយភោគសម្បត្តិ, ហេតុដែលនាំឲ្យអញក្រនេះ មកពីអញគ្មានចំណេះវិជ្ជាអ្វីនៅកងខ្លួនបន្តិចបន្តួចសោះ ដូច្នេះ ត្រូវអញទៅស្វែងរកចំណេះវិជ្ជាទើបប្រសើរ បើមិនបានជាអ្នកមានឈ្មោះល្បីនឹងគេ ក៏ឲ្យតែល្មមគ្រប់គ្រាន់នឹងចិញ្ចឹមក្រុមញាតិរបស់អញបានហើយ" ។ លុះគិតឃើញដូច្នេះហើយ, បុរសនោះក៏ថ្លែងរឿងនេះ ប្រាប់ប្រពន្ធតាមដំណើរ ។ ប្រពន្ធបានឮប្ដីប្រាប់សព្វគ្រប់ហើយ មានចិត្តត្រេកអរជាខ្លាំង ក៏បើកអំណាចឲ្យស្វាមីទៅរករៀនចំណេះវិជ្ជាតាមសេចក្ដីត្រូវការ ។

បុរសនោះ បាននិយាយលួងលោមប្រពន្ធហើយផ្ដាំថា "បងទៅរៀនពុំយូរទេ កាលណាបងរៀនចប់ហើយ បងនឹងត្រឡប់មករកប្អូនវិញ ចូរប្អូនបីបាច់រក្សាកូនឲ្យបានសេចក្ដីសុខ បងទៅយ៉ាងយូរ ៩ ឆ្នាំ តែបើហួសពី ៩ ឆ្នាំទៅ ពុំឃើញបងត្រឡប់មកវិញទេ ចូរប្អូនសម្លឹងមើលបុរសណាមួយ ល្មមប្អូនផ្ញើខ្លួនបាន ប្អូនទទួលយកគេធ្វើប្ដីចុះ" ។ បុរសកំសត់ លុះនិយាយផ្ដែផ្ដាំប្រពន្ធរួចហើយ ក៏រៀបចំខ្លួនចុះដើរទៅជាយូរ

ខែ-ថ្ងៃ បានជួបនឹងអាចារ្យម្នាក់ ក៏ចូលទៅដំកបសួរដោយគោរព ។ លោកគ្រូអាចារ្យក៏ទទួលពាក់ទាក់សួរថា "អើចៅ! ចៅឯងនៅស្រុកណា? ខែត្រណា? ឈ្មោះអ្វី? មកនេះប្រាថ្នារកអ្វី?" ។ បុរសនោះដំកបថា "ខ្ញុំបាទមកនេះ ប្រាថ្នាចង់បានតែចំណេះវិជ្ជា, បានជាខំស្វះស្វែងចោលប្រពន្ធកូនមក ដោយឮល្បីកិត្តិនាមរបស់លោកគ្រូថាចេះវិជ្ជា ទើបបានខ្ញុំបាទមកសុំរៀនចំណេះនេះ សូមលោកគ្រូមេត្តាបង្ហាត់បង្រៀនខ្ញុំបាទឲ្យបានចេះដឹងវិជ្ជានេះផងចុះ" ។ លោកគ្រូក៏ទទួលបង្ហាត់បុរសនោះ ។ ឯលោកគ្រូនោះ ចេះចប់ត្រៃវេទ បានបង្ហាញសិស្សមកពីគ្រប់ទិសទាំងប្រាំបី កំណត់ហៅថា អាចារ្យទិសាបាមោក្ខ ។ អាចារ្យទិសាមោក្ខបាននិយាយទៅកាន់បុរសនោះថា "អ្នកត្រូវរៀន៤ ឆ្នាំ ទើបបានចប់ចំណេះវិជ្ជា" ។ បុរសនោះ ហេតុតែចង់បានចំណេះវិជ្ជា ក៏ខំគោរពប្រតិបត្តិគ្រូ ពុំឲ្យលោកអាក់អន់ចិត្តអ្វីបន្តិចសោះ ។

តាំងពីចៅកំសត់នោះ ចូលមកនៅជាមួយលោកគ្រូអាចារ្យនោះថ្ងៃណា លោកគ្រូពុំបានបង្ហាត់បង្ហាញវិជ្ជាអ្វីសោះ ។ បុរសនោះ ចេះតែខំខ្ទឹង ចាំថ្ងៃដែលគ្រូបង្ហាត់ ចាំមួយខែជាមួយខែ រហូតដល់៤ ឆ្នាំ ក៏គិតថា "ឥឡូវគ្រប់កំណត់ ៤ ឆ្នាំហើយ គ្មានចេះអ្វីមួយមាត់សោះ គេអញនៅធ្វើអ្វី ត្រូវតែទៅរកស៊ីចិញ្ចឹមប្រពន្ធកូនវិញល្អជាង" ។ លុះគិតដូច្នេះហើយ បុរសនោះក៏ចូលទៅសុំលាគ្រូត្រឡប់ទៅស្រុកវិញ ។ លោក

គ្រូសួរថា «ឯងត្រឡប់ទៅស្រុកវិញឬ?» ។ បុរសនោះថា «បាទ! ខ្ញុំនឹងត្រឡប់ទៅស្រុកវិញថ្ងៃស្អែកនេះហើយ គ្រូក៏ផ្តាំថា «បើឯងត្រឡប់ទៅស្រុកស្អែកនេះ ចូរឯងខំទន្ទេញឲ្យជាប់នូវគាថា ៤ បទនេះ កុំភ្លេចឲ្យសោះ គឺ

១- ឃ្មោងចំអក់ ៣- គេឲ្យជ្រើជកុំយក

២- ខ្លត់ចំរការ, ៤- ខ្លាចឲ្យចូលជិត

តមក លោកគ្រូអាចារ្យនិយាយបន្ថែមទៀតថា «ចូរចាំកុំភ្លេចឲ្យសោះ វិជ្ជានេះហើយ នឹងបានសម្រេចប្រយោជន៍ជាប្រាកដ» ។ បុរសនោះគិតក្នុងចិត្តថា «ខ្ញុំភ្លាអើយ! ងាយពេក», ក៏ខំការនាខ្សឹបៗ ។ គ្រូបញ្ជាក់ទៀតថា «ចាំហើយឬនៅ?» ។ បុរសថា «ចាំហើយ» ។ គ្រូថា «ស្អែកឯងទៅស្រុកកំណើតឯងវិញចុះ ឲ្យបានសុខសប្បាយ» ។ បុរសមានសេចក្តីទោមនស្សយ៉ាងខ្លាំងតែមិនបញ្ចេញស្តីសោះ ដោយគិតថា «ខ្លួនអញអើយ! មករៀន ៤ ឆ្នាំ គ្រូប្រាប់តែពាក្យ ៤ ម៉ាត់ ហើយថែមទាំងផ្តាំហើយផ្តាំទៀតផង» ។

ព្រឹកឡើង បុរសនោះ ក៏ចូលទៅលាលោកគ្រូត្រឡប់ទៅស្រុកកំណើតវិញ ។ លោកគ្រូឲ្យពរ ហើយផ្តាំទៀតថា «កុំភ្លេច» ។ រួចហើយ ទៅកំសត់ក៏ខំត្រាច់ទៅតែម្នាក់ឯង កាត់ស្រុកតត្រុកព្រៃយ៉ាងលំបាកវេទនា អស់រយៈប្រមាណជា ២០ ថ្ងៃ ពុំបានជួបប្រទះ

ស្រុកភូមិណាសោះ ម៉្លោះហើយបុរសនោះចេះតែដើរទៅមុខទៀត ដោយអត់អាហារ ១ ថ្ងៃ ទើបជួបប្រាសាទមួយ ដ៏ល្អវិចិត្រដោយក្បូរក្បាច់របនាក់គិតថា " ផ្ទះអ្នកណាក៏ល្អម្ល៉េះ ! " ។ បុរស មានចិត្តស្ញប់ស្ញែងជាខ្លាំង ខំតយគន់មើលម្ចាស់ផ្ទះ គ្មានឃើញម្នាក់សោះ ក៏នឹកក្នុងចិត្តថា "ប្រហែលជាសាលាយក្សទេដឹង?" ។ គិតហើយ បុរសក៏សក់ប្រុងគេចចេញឲ្យឆ្ងាយ តែនឹកឃើញបណ្ដាំគ្រូថា " ខ្លាចឲ្យចូលជិត " ។ ហើយបុរសនោះ លបចូលសន្សឹមៗទៅក្នុងប្រាសាទ បានឃើញរបស់ប្លែកៗ នៅក្នុងបន្ទប់មួយ មានសុទ្ធតែគ្រឿងល្អៗ លើតុមានម្ហូបចំណីមានក្លិនឈ្ងុយឈ្ងប់ស្ទើរតែទប់ទល់ នឹងសេចក្ដីស្រេកឃ្លានពុំបាន, គិតបរិភោគ ក៏នឹកឃើញបណ្ដាំគ្រូថា " ឃ្លានឲ្យខំអត់ " បើដូច្នេះ គួរអញបង្អង់ចាំមើលសិន ពីព្រោះពេលនេះ ជិតដល់ពេលម្ចាស់គេមកអាស្រ័យបាយផងទៅហើយ បើធ្វើលោភទៅ ម្ចាស់គេមកទាន់ គេធ្វើដូចម្ដេច? បើដូច្នេះ គួរចាំមើល ក្រែងមានមនុស្សដើរមក អញនឹងសាកសួរឲ្យដឹងច្បាស់ " បើគេជាម្ចាស់ អញសូមបាយបរិភោគ " ។ កំពុងតែគិតដូច្នេះ ស្រាប់តែឮសូរសន្ធឹកដូចខ្យល់ព្យុះសង្ឃរា ស្ទើររលើងសាលា បុរសនោះភ័យណាស់ ពុំដឹងជារត់ទៅពួនកន្លែងណា ក៏រត់ទ្រូឆ្ពាពេញបន្ទប់ សំឡឹងមើលទៅលើស្ពានឃើញនៅទំនេរ ក៏ប្រញឹបប្រញាប់ឡើងទៅពួននៅទីនោះ ហើយលបមើលតាមប្រហោងតូចមួយ ។ មិនយូរ

ប៉ុន្មាន ស្រាប់តែឃើញយក្សមួយមាឌធំសម្បើម ដើរចូលមកក្នុងសាលានោះ ហើយគ្រវាត់ខ្សែមួយចង្វាយនឹងដំបងមួយទៅលើស្កាក ។ បុរសកំសត់ ឃើញដូច្នោះក៏ភ័យញ័ររន្ធត់ស្ទើរបាត់ស្មារតីគិតថា "នេះហើយដែលអ្នកផងហៅថាយក្ស, ខ្សែនឹងដំបងនេះ ប្រហែលជាខ្សែចងដំបងវាយឯងហើយមើលទៅ" ។ បុរសក៏ចាប់ខ្សែចងដំបងវាយ មកគយគន់មើលក៏ដឹងថា នេះជាខ្សែចងដំបងវាយពិតមែន ។ កាលយក្សកំពុងស៊ីបាយ, បុរសនោះគិតថា អញគិតប្រថុយប្រើខ្សែចងដំបងវាយនេះល្បងមើល បើស្លាប់ក៏ស្លាប់ទៅចុះ តែយូរបន្តិចទៀតយក្សស៊ីបាយអស់ អញបានអីស៊ី, គិតស្រេចក៏បោះខ្សែនឹងដំបងទៅប្រាប់ថា "ខ្សែចង ! ដំបងវាយ!" ។ ភ្លាមនោះ, ខ្សែនឹងដំបងក៏ប្រតិបត្តិតាម ចងក្រសោបវាយសំពងយក្សជាប់ក្រញោន ។ យក្សដាច់បាយ ស្រែកទ្រហោយំស្ទើរដាច់ខ្យល់ស្លាប់ អង្វរគេឲ្យលែងខ្លួនថា "នឹងជូនកន្សែងថែមទៀត" ។ បុរសនោះស្រែកប្រាប់ទៅដំបងឲ្យឈប់វាយ ប្រាប់ខ្សែឲ្យបន្ធូរបន្តិច ហើយចុះពីលើស្កាកទៅគម្រាមយក្សថា "តាំងពីថ្ងៃនេះតទៅ ចូរឯងកុំមកសង្កត់សង្កិនមនុស្សលោកទៀត បើកាលណា អញឃើញមកទៀត អញនឹងប្រហារជីវិតចោលឥតត្រាប្រណី" ។ យក្សក៏ទទួលសច្ចា ហើយជូនកន្សែងបក់បាយមួយឲ្យបុរសកំសត់ ។ ក៏ដោះយក្សលែងទៅ ។

(នៅមានទៀត)

# ផ្នែកកំណត់និងប្រវត្តិការណ៍

## មហាសន្និបាតនៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ

លោក ង៉ាយ-ប៊ុក រៀបរៀង

---

កាលពីថ្ងៃទី ៣១ មករ ១៩៦២ ពេលម៉ោង ៨ ល្ងាច សមាគមមិត្តពុទ្ធិកវិទ្យាល័យ បានធ្វើមហាសន្និបាត លើកទី ១៨ នៅវត្តលង្កា ក្រុងភ្នំពេញ ។

បាននិមន្ត- បានអញ្ជើញមករួមប្រជុំ :

ផ្នែកខាងបព្វជិត គឺ:

ព្រះតេជព្រះគុណ ព្រះធម្មលិខិត ម៉ុង-សែស ចៅអធិការវត្តមហាមន្ត្រី ព្រះតេជព្រះគុណ ព្រះឃោសធម្ម ចៅអធិការវត្តលង្កា, ព្រះមុនីកោសល សួរ-ហាយ, ព្រះញាណកោសល ញាណ-ឈឹង, ព្រះមហា ទ៉ាង-ខាត់, ព្រមទាំងព្រះថេរានុត្ថេរទាំងឡាយ រួមជាង ៧០ អង្គ ។

ផ្នែកខាងគ្រហស្ថ គឺ

លោកអ្នកតំណាងរដ្ឋសភា , ក្រុមប្រឹក្សាព្រះរាជអាណាចក្រ, បុគ្គលិកគ្រប់ក្រសួង ; ពួកសមាជិក-សមាជិកាក្រុមអភិបាល , ពួកពុទ្ធមាមក-ជនទាំងបុរសទាំងស្ត្រី រួមទាំងអស់ប្រហែល ៦០ នាក់ ។

ពេលម៉ោង ៨ ៧ លោក ង៉ាយ-ប៊ុក ប្រធានសមាគម បានបើក

សម័យប្រជុំមហាសន្និបាត ហើយបានថ្លែងសុន្ទរកថាមួយ រៀបរាប់អំពីលទ្ធផលនៃសមាគមក្នុងឆ្នាំ ១៩៦១ ដែលមានសេចក្តីដូចតទៅនេះ៖

សូមថ្វាយបង្គំព្រះថេរានុត្ថេរគ្រប់ព្រះអង្គ,

សូមគោរពមហាសន្និបាត,

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះព្រះថេរានុត្ថេរ អស់លោកជាសមាជិក សមាជិកា នឹងពុទ្ធបរិស័ទដែលបាននិមន្ត អញ្ជើញមកកាន់ទីនេះ ដើម្បីប្រមូលប្រជុំធ្វើមហាសន្និបាត ជាគំរប់ឆ្នាំទី ១៤ នៃសមាគមមិត្តពុទ្ធិកវិទ្យាល័យ របស់យើងរាល់គ្នា ។

ការប្រជុំធ្វើមហាសន្និបាតក្នុងពេលនេះ ជាមហាសន្និបាតសម្រាប់ឆ្នាំ ១៩៦២ ដែលជាប់តជាបវេណីរៀងរាល់ឆ្នាំមក ដូចជាអស់លោក-អ្នកធ្លាប់បានដឹងរួចមកហើយ ។

ហេតុអ្វីក៏បានជាចាំធ្វើមហាសន្និបាត កំណត់ក្នុង ១ ឆ្នាំម្តងដូច្នេះបានជាធ្វើ ព្រោះមានសារៈសំខាន់ជាការចាំបាច់ ក្នុងផ្នែកនៃសមាគម៖

ក- ដើម្បីដឹងនូវអាយុកាលនៃសមាគម,

ខ- សកម្មភាពនៃសមាគមដែលបានប្រព្រឹត្តទៅក្នុងឆ្នាំ ១៩៦១ តើបានលទ្ធផលយ៉ាងណាខ្លះ,

គ- ស្ថានការណ៍ស្តីអំពីហិរញ្ញវត្ថុ ប្រាក់ចំណូល-ចំណាយនិងសំណល់,

ឃ- បោះឆ្នោតជ្រើសតាំងក្រុមអភិបាលថ្មីសម្រាប់ឆ្នាំ ១៩៦២.

ង- ការជួបជុំ សមាជិក- សមាជិកានៃសមាគម ដើម្បីពិភាក្សាឫរ យោបល់គ្នាទៅវិញទៅមក រកមធ្យោបាយបែបណា ធ្វើឲ្យសមាគម មានដំណើរទៅកាន់សេចក្ដីចំរើនទាន់សម័យ នឹងឲ្យមានសាមគ្គីរឹងរឹតតែ ជិតស្និទ្ធឡើង ។

អាស្រ័យដោយហេតុនេះហើយ បានជាថ្ងៃដែលយើងបានមកជួប ជុំរួមជុំនុំធ្វើមហាសន្និបាតនេះ នឹងត្រូវកម្រិតទុកជាថ្ងៃមួយដ៏ប្រសើរប្រកប ដោយនក្ខត្តឫក្សជោគជ័យ នៃប្រវត្តិសមាគមមិត្តពុទ្ធិកវិទ្យាល័យ ដែល បានតាំងនៅជាប់ឋិតថេរចីរកាលតាំងពីឆ្នាំ ១៩៤៨ រហូតមកទល់នឹងឆ្នាំ ១៩៦២ នេះ គឺមានអាយុ ១៤ ឆ្នាំហើយ ដោយសារតែពុទ្ធមាមកជន មានព្រះសង្ឃនឹងឧបាសក- ឧបាសិកាជាដើម ជួយឧបត្ថម្ភគាំទ្រដោយ កំឡាំងសទ្ធា នឹងកំឡាំងកាយ ទើបសមាគមនេះរស់គង់មានជីវិត រហូត មកទល់នឹងបច្ចុប្បន្នកាលនេះ ។

ខ្ញុំសូមដកបងាក្នុងឆ្នាំ ១៩៦១ ដែលកន្លងទៅនេះសមាគមមានសភាព កាន់តែតឹងស្ដាំងស្ដួមខាងថវិកាជាអតិបរមា ស្ទើរតែអស់សង្ឃឹមថា មិនអាច នឹងតាំងនៅឋិតថេរចីរកាលតទៅមុខបានឡើយ ព្រោះប្រាក់ចំណូលមាន ចូលតិចជាងប្រាក់ចំណាយ ដែលត្រូវចាយរាយរាល់ខែ ហើយគ្មាន ប្រាក់ចំណូលអ្វីសម្រាប់ផ្ដល់ឲ្យក្រៅពីប្រាក់ភាគទាន ដែលសមាជិក

សមាជិកាបានបង់ប្រចាំខែ ប្រចាំឆ្នាំនោះទេ ម្ល៉ោះហើយការរស់នៅរបស់សមាគមនេះ ពឹងផ្អែកតែទៅលើកំឡាំង សមាជិក-សមាជិកាតែម្យ៉ាង ប៉ុណ្ណោះ ។ បើពេលណាមានចំនួនសមាជិក-សមាជិកាច្រើន ថវិកាក៏បានចំរើនធំធាត់បន្តិចឡើង បើចំនួនសមាជិកតិចក៏អន់ថយដុនដាបទៅតាមចំនួនតិចដែរ តែជាភ័ព្វសំណាងល្អរបស់សមាគម នៅពេលបំណាច់ឆ្នាំ ១៩៦១ ទទួលព្រះមហា អាំ-សួន ជាសមណនិស្សិតដែលសមាគមបញ្ជូនឲ្យទៅបន្តវិជ្ជាសិក្សាជាន់ខ្ពស់ នៅប្រទេសឥណ្ឌាអស់រយៈ ៧ ឆ្នាំនោះ ក៏បាននិមន្តត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។

ដោយឃើញថា សមាគមមានសភាពដុនដាបដូច្នោះ លោកក៏បានសុំព្រះអង្គលោក ចូលបំរើសមាគមតាមសមត្ថភាពរបស់លោក ដែលគួរបំរើបាន ដើម្បីតបស្នងសងគុណសមាគម ។

គណៈកម្មាធិការនាយកនៃសមាគម ក៏បានពិភាក្សាព្រមព្រៀងគ្នាបើកឲ្យមានបង្រៀនភាសាអង់គ្លេសមួយនៅសាលាវត្តលង្កា ដោយចាត់លោកឲ្យធ្វើជាសាស្ត្រាចារ្យក្រោមសេចក្តីអនុញ្ញាតពីក្រសួងធម្មការ ដើម្បីយកកម្រៃសម្រាប់ជាប្រយោជន៍ដល់ថវិកានៃសមាគម ។ ព្រះថេរៈអង្គនេះក៏ព្រមទទួលដោយសោមនស្សរីករាយ ហើយក៏បានចាប់បង្រៀនភាសាអង់គ្លេស តាំងពីដើមខែ តុលា ១៩៦១ រហូតមកទល់នឹងសព្វថ្ងៃនេះ ។

លទ្ធផលនៃការបង្រៀនក្នុងរយៈ ៣ ខែនេះ ក៏បានកម្រៃចូលមកក្នុងថវិកាជាង ៤ ម៉ឺនរៀល ។

មានការជាពិសេសទៅទៀត ដែលគួរឲ្យសរសើរដល់សេចក្ដីប្រឹងប្រែងរបស់អស់លោកក្រុមអភិបាលខ្លះ ដូចជាលោកស្រី ត្រូច-ស្អាត លោកស្រី ហ៊ាយ·ប៊ុកា លោក ងៃ-វង្ស លោក យ៉ិង·គឹមលន លោក ប៊ឹង·ហ៊ិត ជាដើម បានទៅប្រាស្រ័យទាក់ទងជាមួយនឹងអស់លោកអស់អ្នកសប្បុរសប្រុសស្រី បានចូលជាសមាជិក សមាជិកាសាមញ្ញខ្លះ ជាពិសេសខ្លះ ខ្ញុំសូមកយនាមក្នុងទីនេះ ចំពោះតែសមាជិកសមាជិកាពិសេស ដែលបានបង់ប្រាក់ប្រចាំឆ្នាំតាំងពី ៥០០ រៀលឡើងទៅ ហើយនឹងសូមអភ័យទោស ដោយមិនបានកយឈ្មោះសមាជិក សមាជិកាសាមញ្ញ ដែលបានបង់ប្រាក់ប្រចាំឆ្នាំតិចជាងពី ៥០០ រៀលចុះមក ព្រោះសមាជិកប្រភេទនេះមានចំនួនច្រើន ហើយពេលនេះក៏ខ្វះពេល ចាំថ្ងៃក្រោយនឹងកយឈ្មោះផ្សាយជូនតាមវិទ្យុជាតិរៀងរាល់ថ្ងៃសីល ។

នាមសមាជិកនិងសមាជិកាពិសេសក្នុងឆ្នាំ ១៩៦១ មានដូចតទៅនេះ ៖

១- លោកគហបតី សុគា-ហុគា បានបង់ក្នុង១ឆ្នាំ ២.០០០ រៀល

២- លោកគហបតី តាង·ចា – – ១.២០០រៀល

៣- លោកស្រី ម៉ែរ-ម៉ាលី – – ១.២០០រៀល

៤- លោក ឃុង ងេ ភគញ្ញាសោភា - – ១.០០០រៀល

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | សឺន-សាន | បានបង់ក្នុង ១ ឆ្នាំ | ៦០០រៀល |
| ៦-លោក | តាង-គីយ៉ុង | – – | ៦០០រៀល |
| ៧-លោកស្រី | រ័ត្ន-ធុច | – – | ៦០០រៀល |
| ៨-លោកស្រី | សុន-វិនសៃ | – – | ៦០០រៀល |
| ៩-អ្នកស្រី | រស់-ឡម | – – | ៦០០រៀល |
| ១០-អ្នកស្រី | ហ៊ុន-ងី.ប៊ិន | – – | ៦០០រៀល |
| ១១-អ្នកស្រី | ភ៊ី-ឈីវហ៊ាង | – – | ៦០០រៀល |
| ១២-អ្នកស្រី | គោន | – – | ៦០០រៀល |
| ១៣-លោក | តាង.ដេង | – – | ៥០០រៀល |
| ១៤-លោក | ងា.ប៊ុនឡុង | – – | ៥០០រៀល |
| ១៥-លោក | សេង-ស៊ឹម | – – | ៥០០រៀល |
| ១៦- | រោងពុម្ពគោតសិរី | – – | ៥០០រៀល |

សូមជំរាបមហាសន្និបាតថា: ក្នុងពេលថ្មីៗនេះ លោកគហបតី ស៊ុក·ហ៊ុក ខាងលើនេះ បានធ្វើអំណោយដល់សមាគមនូវបង្គៀនម៉ែត្រ អគ្គិសនី ៤ និងផ្ទឹតបញ្ជូរអគ្គិសនី ២ តម្លៃជាប្រាក់ ៦.០០០រៀល ដើម្បីទុកជាសម្បត្តិផ្ទាល់របស់សមាគម ។

សមាគមសូមថ្លែងអំណរគុណជាអនេកប្បការចំពោះ អស់លោកសមាជិកសមាជិកាថ្មី ដែលបានបរិច្ចាគគោតទ្រព្យដល់សមាគមនេះ សូម

ឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលដែលជាទីគាប់ចិត្តជានិរន្តរ៍ ។

អំពីកិច្ចការសមាគម ដែលបានប្រព្រឹត្តទៅក្នុងឆ្នាំ ១៩៦១ នេះ៖

សមាគមមិត្តពុទ្ធិកវិទ្យាល័យ ពោះបីមានការខ្វះខាតដូចម្ដេចក៏ដោយ ក៏ពុំដែលលះបង់នូវភាគតួកិច្ចរបស់ខ្លួន ដែលត្រូវតែបំពេញដោយមិនដែលខាននោះឡើយ ។

១– បានចំណាយប្រាក់ ៦០០ រៀលទិញកម្រងផ្កា និងប្រគេនព្រះសង្ឃបង្សុកូល ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធសពលោក អ៊ុ-កង់ និងលោក លី-ស៊ុនគូ ជាឧបការីសមាជិកដែលទទួលមរណភាពក្នុងឆ្នាំ ១៩៦១ នេះ ។

២– បានចំណាយប្រាក់ ១.០០០រៀលទិញឱសថរៀកពេទ ប្រគេនព្រះតេជព្រះគុណព្រះឃោសធម្មវត្តលង្កា នៅពេលដែលលោកនិមន្តទៅព្យាបាលរោគនៅមន្ទីរពេទ្យ ព្រះកេតុមាលា ។

៣– បានចំណាយប្រាក់ ៤.០០០ រៀល ប្រគេនព្រះមហា អាំ-សួន សមណនិស្សិតជាតខ្មែរយានជំនិះ ដែលនិមន្តត្រឡប់ពីប្រទេសឥណ្ឌាមកប្រទេសកម្ពុជា ។

៤– បានសម្រេចគ្រោងការចំណាយប្រាក់ក្នុង១ ខែ២.៤០០រៀលសម្រាប់ជាអាហារូបករណ៍ ផ្ញើទៅប្រគេនសមណនិស្សិត ៣អង្គទៀតគឺ ១ ភិក្ខុ ម៉ៅ-វ៉េង, ២ ភិក្ខុ ឧង-ណាង, ៣ សាមណេរ កែវ-ចាំម៉ា

ដែលកំពុងសិក្សាបន្តវិជ្ជានៅប្រទេសឥណ្ឌាសព្វថ្ងៃនេះ ចាប់តាំងពីខែមករា ១៩៦២ នេះទៅ ។

សូមដកបថា: សមណនិស្សិតដែលកំពុងសិក្សាបន្តវិជ្ជាសព្វថ្ងៃនៅប្រទេសឥណ្ឌាក្រោមការឧបត្ថម្ភនៃសមាគម មានចំនួន៩អង្គហើយ ។

៤– នៅឱកាសបុណ្យសន្និសីទទី ៦ នៃពុទ្ធិកសមាគមពិភពលោក ពីថ្ងៃទី ១៤ ខែ វិច្ឆិកា ១៩៦១ សមាគមបានបោះពុម្ពសៀវភៅ ធម្មសង្គិតិ ចំនួន ១០១០ ក្បាល សម្រាប់ចែកជូនដល់ពុទ្ធបរិស័ទទូទៅ ដោយឧបាសិកា មែរ·ម៉ាលី មានសទ្ធាជ្រះថ្លាចំណាយប្រាក់ផ្ទាល់ខ្លួនចំនួន ៣០០០ រៀល ក្រោមការអំពាវនាវរបស់សមាគម ។ ក្រៅអំពីនេះទៅទៀត សមាគមបានចាត់ក្រុមអភិបាលរូបខ្លះ ឲ្យទៅរួបរួមជាមួយនឹងពុទ្ធិកសមាគមកម្ពុជរដ្ឋ សម្រាប់ជួយធ្វើការក្នុងកិច្ចការផ្សេងៗ មានបំរើភ្ញៀវព្រះសង្ឃបរទេសជាដើម រហូតទៅដល់ទីងថ្ងៃចប់ពិធីបុណ្យ ចំណែកក្រុមអភិបាលខ្លះទៀត ដូចជារូបខ្ញុំបាទនឹងអ្នកស្រី សាខង·សាម៉ង ក៏ត្រូវសមាគមចាត់ឲ្យទៅធ្វើជាប្រតិភូ សម្រាប់ប្រទេសកម្ពុជា រួបរួមប្រជុំជាមួយនឹងគណៈប្រតិភូបរទេសនានាក្នុងឱកាសបុណ្យនោះដែរ ។

៦– ថ្ងៃទី ១-៤-៦១ ពិធីបុណ្យដាក់បាត្រព្រះសង្ឃ ៤០០ អង្គ នៃពួកពុទ្ធបរិស័ទនៅខាងត្បូងផ្សារទួលតាពូង ដែលមានលោកអនុសេនីយឯក គុល·ឈុង កងខេមរភូមិន្ទ លោក សឹង·ស៊ុម នាយកា.

វិយាល័យនិពន្ធទី ៣ លោក ឌៃ-វង្ស នាយកម្រុតព្រះនគរបាលជាតិ លោក យ៉ឹង-គីមលន ពាណិជ្ជករ ជាអ្នកផ្តើមបុណ្យ បានចំនួន ប្រាក់១០.០០០រៀល សម្រាប់ផ្តល់ជំនួយដល់សមាគម ។

៧-- ថ្ងៃទី ១០ ខែ មិថុនា ១៩៦១ សមាគមបានរួបរួមជាមួយពួក ពុទ្ធបរិស័ទវត្តលង្កា ធ្វើពិធីបុណ្យដាក់បាត្រឧទ្ទិសកុសល ថ្វាយចំពោះ សម្តេចព្រះប្រមុខរដ្ឋជាព្រះបិតាឯករាជ្យជាតិនៃប្រទេសកម្ពុជា ព្រមទាំង សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ដែល ទ្រង់យាង-និមន្តទៅព្យាបាលព្រះរោគ នឹងចក្ខុរោគនៅប្រទេសបារាំង ។

៨- ថ្ងៃទី ២៩ មេសា ១៩៦១ សមាគមបានរួបរួម នឹងសមាគម គិលានសង្គ្រោះសម្តេចព្រះមហាក្សត្រិយានី ពុទ្ធិកសមាគមមជ្ឈមណ្ឌល កម្ពុជរដ្ឋ ធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ៍ នៅមុខស្ថានីយ៍ រាជអយស្ម័យយានកម្ពុជា បានបច្ច័យជាង ៧.០០០ រៀល គណៈកម្មា- ធិការក៏បានសម្រេចចែកកុសលទាននេះ មកសមាគមយើង បានប្រាក់ ២.៤០៨រ០០ ។

៩-ថ្ងៃទី ៧ តុលា ១៩៦១ សមាគមបានធ្វើការប្រាស្រ័យទាក់ទង នឹងមូលនិធិអាស៊ី មូលនិធិអាស៊ី បានផ្ញើអំណោយមកសមាគមនូវម៉ាស៊ីន សម្រាប់ទាញក្រដាសទ្បានច្រើន យីហោ-រ៉ូក្វូ តម្លៃ១៣ ៥០០រៀល ។

សមាគមបានធ្វើការប្រោសប្រណីយកទង់ ទីវមូលនិធិអាស៊ីមួយទៀត មូល-និធិអាស៊ី បានជួយជាអាហារូបករណ៍ ចំពោះសមណនិស្សិត ដែលនិមន្ត ទៅសិក្សាឯប្រទេសឥណ្ឌា គឺសមណនិស្សិត ក៏-យ៉ាវ១ មាស-ចង១ អ៊ុង-សំបេត១ ប្រសើដ្ឋ១ ឈឹម-ដង១ បាន ២០០ រូពី ១ ខែ ១ អង្គ ។

១០- សមាគមបានធ្វើការគមនាគមន៍ ទីវឯកទូតមងកអគ្គរដ្ឋទូត ប្រទេសឥណ្ឌាប្រចាំប្រទេសកម្ពុជា រដ្ឋាភិបាលកណ្តាលប្រទេសឥណ្ឌា បានជួយជាអាហារូបករណ៍ចំពោះសមណនិស្សិត ៣ អង្គ គឺ ភិក្ខុ ប៉ែង-សាអៀង ភិក្ខុ អ៊ុក-អ៊ង ភិក្ខុ សួង-សារៀម បានបច្ច័យ ២០០ រូពី ១ អង្គ ។

១១- ថ្ងៃទី ២ តុលា ១៩៦១ សមាគមបានធ្វើពិធីបើកសាលា បង្រៀនភាសាអង់គ្លេស ដើម្បីយកកម្រៃដាក់ថវិកាសមាគម ដោយ លោក មហា អាំ-សួង មានបំណងតបស្នងសងគុណឧបការៈសមាគម ដែលបានជួយឧបត្ថម្ភលោក ក្នុងការសិក្សាឯប្រទេសឥណ្ឌា បានបច្ច័យ ជាង ១០.០០០៛០០ ក្នុង ១ ខែ ។

១២- អំពីសមាជិកនៃសមាគមគ្រប់ប្រភេទក្នុងឆ្នាំ ១៩៦១ ខ្ញុំព្រះ ករុណា ខ្ញុំ សូមតាណនាដូចតទៅនេះ៖

១- សមាជិកកិត្តិយស ៩ នាក់

២- ជនកសមាជិក ២៣ នាក់

៣- ឧបការីសមាជិក ៤២ នាក់

៤- ទាយកសមាជិក ៧៧ នាក់

៥- កម្មិកសមាជិក ៦៨៥ នាក់

៦- បាសាទិកសមាជិក ៨២២ នាក់

បូករួម . . . . . ១.៦៥៨ នាក់

ឆ្នាំ ១៩៦០ មានចំនួន១.៥៥៣ នាក់ ឃើញកើនជាងឆ្នាំចាស់ចំនួន ១០៥ នាក់ ។

១៣- សូមប្រគេននិងជូនដំណឹងដ៏ជាទីរីករាយមួយដល់មហាសន្និបាតថា ព្រះរាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលមានអគ្គសម្តេចព្រះបិតាឯករាជ្យជាតិដ៏ជាទីគោរព បានទទួលស្គាល់នូវសមាគមយើងជាផ្លូវការហើយ ព្រមទាំងបានធ្វើសេចក្តីគ្រោងការសម្រាប់ចំណាយប្រាក់ចំនួនប្រាំបីម៉ឺនរៀល ផ្តល់ដល់សមាគមតាំងពីឆ្នាំ ១៩៦២ តទៅ ។

ដូច្នេះសមាគមយើង នឹងមានសភាពមាំមួនតាំងពីពេលនេះតទៅ ។

មុននឹងបញ្ចប់នូវសុន្ទរកថានេះ ខ្ញុំព្រះករុណា.ខ្ញុំបាទ សូមឆ្លៀតឱកាសពេលនេះ ថ្លែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅ ចំពោះសមាជិក សមាជិកាក្រុមអភិបាល ដែលបានជួយបំពេញករណីយកិច្ចតាមមុខការរៀង

ខ្លួន ដោយសុទ្ធចិត្ត ហើយសូមដាស់តឿនក្រើនរំលឹកនូវសមាជិកក្រុមអភិបាលថា សមាគមមានលក្ខន្តិកៈជាប្រធាន សូមលោកអ្នកញុំាង បញ្ហានានា មានហិរញ្ញវត្ថុជាដើម ឲ្យប្រព្រឹត្តទៅដោយត្រឹមត្រូវ តាមលក្ខន្តិកៈកុំបីឃ្លៀងឃ្លាត ។

ម្យ៉ាងវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមសរសើរចំពោះមុខមហាសន្និបាត នូវការព្យាយាមនៃលោក-អ្នក ដែលមាននាមខាងក្រោម ក្នុងការពារប្រាក់សមាជិករៀងរាល់ខែគឺ៖

លោក ឌី-វ៉ង ដំណាងក្រសួងធម្មការ

- ម៉ៅ-ម៉ី ដំណាងក្រសួងមហាផ្ទៃ
- ជៃ-វង្ស ដំណាងក្រសួងគិញ
- យ៉ង-គឹមលង ដំណាងបរិស័ទទួលតាពូន

លោក មាស-ងាង នឹងលោក ប៉ុល-ប៉ូច ដំណាងក្រសួងឃោសនាការជាតិ

- សរម សុខុម ដំណាងកសហករណ៍
- ឈុត មាលីស ដំណាងព្រះបរមរាជវាំង

ជាអវសាន ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រមូលនូវបុញ្ញកុសលដែលកើតឡើងអំពីបុញ្ញកម្ម នៃសមាគមនេះ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះមហាកាញ្ចនគោដ្ឋ សុំព្រះអង្គបានប្រកបនូវព្រះបរមសុខ

គ្រប់ប្រការក្នុងសុគតិភព  នឹងសូមថ្វាយចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គមានមហិទ្ធិរិទ្ធិ  នឹងព្រះមហាតេជានុភាពឈ្នះអស់ទាំងសត្រូវគ្រប់ទិសទី មានព្រះបរមសុខុមាលភាព  ក្នុងព្រះសិរីរាជសម្បត្តិ  មានព្រះជន្មាយុយឺនយូរអស់រយៈព្រះវស្សា  ដើម្បីជាទីពឹងពុំនាក់ជាម្លប់ដ៏ត្រជាក់  នៃប្រជាពលរដ្ឋក្នុងព្រះរាជអាណាចក្រ   ព្រមទាំងប្រគេននឹងចែកជូននូវភាគផលកុសលកសិនេះ ដល់ព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកជាប្រធាន នឹងអស់លោកអ្នកជាសមាជិក សមាជិកាគ្រប់រូប សូមឲ្យបានប្រកបដោយពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិរន្តរ៍ទៅហោង ។

លំដាប់តមក លោក ម៉ៅ-ម៉ុំ អគ្គហេរញ្ញិក បានថ្លែងនូវស្ថានការណ៍ហិរញ្ញវត្ថុសមាគម អំពីប្រាក់ចំណូល-ចំណាយ នឹងប្រាក់សល់ក្នុងហិប ដូចខាងក្រោម ៖

ប្រាក់ចំណូល - ចំណាយ របស់សមាគម ដែលបានប្រព្រឹត្តទៅក្នុងឆ្នាំ ១៩៦១

ប្រាក់ចំណូល . . . . . ១៤២.១២៧ រៀល

ប្រាក់ចំណាយ . . . . . ៣០.៩១៦ រៀល

ប្រាក់នៅសល់ក្នុងហិប . . . . ៧១.២១១ រៀល

ពេលម៉ោង ៩.៣០ នាទី មហាសន្និបាតបានចាត់តាំងការិយាល័យមួយ សម្រាប់បោះឆ្នោតជ្រើសតាំងសមាជិកក្រុមអភិបាលថ្មី ក្រោយដែលក្រុមអភិបាលឆ្នាំចាស់សូមលាលែងពីមុខតំណែង ។

ពេលម៉ោង ៩.៥០ នាទី លោក ប៊ិន-ឃាត បានឡើងលើវេទិកា បានសុំមហាសន្និបាតកែប្រែលក្ខន្តិកៈត្រង់ចំនួនសមាជិកក្រុមអភិបាល ១៦ នាក់ ឲ្យកែជា ២០ នាក់ ហើយសុំមហាសន្និបាតអនុមតិជាឯកច្ឆន្ទនូវនាមឈ្មោះដែលបានសរសេរលើក្ដារខៀនចំនួន ២០ នាក់ថា ជាក្រុមអភិបាលសម្រាប់ឆ្នាំ ១៩៦២ ។

ឯសមាជិកក្រុមអភិបាលថ្មី ដែលមហាសន្និបាតបានជ្រើសតាំងហើយអនុម័តិជាឯកច្ឆន្ទ បានសម្រេចនូវលទ្ធផលដូចតទៅ :

១- លោក កាយ-ប៊ុត្រា អធិបតី

២- លោក ដេង-ជ្រីវ អធិបតីរង

៣- - អ៊ឹង-ឌួង -

៤- - ប៊ិន-ឃាត លេខាធិការ

៥- លោកស្រី សាខុង-សាម៉ុង អនុលេខាធិការ

៦ លោក ដៃ-វង្ស -

៧- - ម៉ៅ-ម៉ី អគ្គហេរញ្ញិក

៨- លោក សូរ.ស៊ីផន ហេរញ្ញិក

៩- - យ៉ីន.គឹមលន -

១០- - ញ៉ង.សៀង បណ្ណារក្ស

១១- - ម៉ែន.ឌន -

១២- លោកស្រី វ៉ាយ.ប៊ុត្ត សួនការ

១៣- - ត្រួច.ស្អាត -

១៤- - ម៉ែរ.ម៉ាលី -

១៥- - សម.ណៃ -

១៦- លោក ជា.ឌន -

១៧- - លុយ-ឌុំម -

១៨- - អាស.ជាន -

១៩- - មាស.ជេង -

២០- - ឌី.វ៉ង -

ពេលម៉ោង ៦ ល្ងាច មហាសន្និបាត ក៏បានប្រកាសហៅនាម សមាជិក.សមាជិកា ក្រុមអភិបាលសមាគមថ្មីសម្រាប់ឆ្នាំ ១៩៦២ ហើយ ព្រះសង្ឃក៏បានប្រទានសព្ទសាធុការពរ ទំនងជ័យមង្គលសិរីសួស្តីគ្រប់យ៉ាង ដល់ក្រុមអភិបាលថ្មី ជាកិច្ចបញ្ចប់សម័យមហាសន្និបាត ។

មហាសន្និបាតក៏បានបញ្ចប់សព្វគ្រប់នៅម៉ោង ៦ និង ១០ នាទី ។

---

# គិលានដ្ឋាន បំរើសុខភាព

សម្តេចព្រះមហាសុមេធាធិបតី ជ.ណ. ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ បានចាត់ការស្ថាបនាគិលានដ្ឋានបេតុង-អារម៉េ ១ ខ្នង ក្នុងឃុំកោះកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ចាប់ផ្តើមស្ថាបនាពីក្នុងខាងចុងឆ្នាំ ១៩៦០ ដល់ខាងចុងឆ្នាំ ១៩៦១ ទើបហើយស្រេច បានឲ្យឈ្មោះថា គិលានដ្ឋាន "បំរើសុខភាព" ។ គិលា-នដ្ឋាននេះ មានបណ្តោយ ១៨ ម៉ែត្រ ទទឹង ៨ ម៉ែត្រ ចែកជា ៤ ល្វែង មានយ៉ចេញមកខាងមុខ ៤ ម៉ែត្រ ៤ ជ្រុង គ្រឿងឈើស្រឡៅ ប្រក់ក្បឿងក្បាច់ ក្រាលឥដ្ឋពណ៌ស.លឿងចាស់ មានយ៉ចេញមកខាងក្រោយ ៤ ម៉ែត្រ ៤ ជ្រុងដែរ មានផ្ទះបាយបណ្តោយ ១១ ម៉ែត្រ ទទឹង ៤ ម៉ែត្រ ចែកជា ៣ ល្វែង, ផ្ទះបាយនេះធ្វើភ្ជាប់ពីយ៉ខាងក្រោយមក មានដំបូលកបស្មើ ក្រាលឥដ្ឋដីពីលើ- ទាំងផ្ទះធំទាំងផ្ទះបាយមានម៉ាស៊ីនទឹកសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ ម៉ាស៊ីនទឹកទាំងនោះ បូមយកពីអាងទឹកខាងក្រោយផ្ទះបាយ ដែលទទួលយកទឹកភ្លៀងពីផ្ទះធំទាំងផ្ទះបាយ ឬបូមយកពីអណ្តូងនៅជិតនោះក៏បាន ។ គិលានដ្ឋាននេះ សង់លើទីដីមានបណ្តោយ ១០០ ម៉ែត្រ ទទឹង ៩២ ម៉ែត្រ ជាដីរបស់ឈ្មោះ ស្នួស.យ៉ា ភរិយាឈ្មោះនាង ប្រាក់.សាប៊ិ បានប្រគេនសម្តេចព្រះសង្ឃនាយក ដោយឥតយកថ្លៃបន្តិចបន្តួចឡើយ ។ សម្តេចព្រះសង្ឃនាយក បានចាត់ការស្ថាប-

នាកំពែងបេតុងអារម៉េព័ទ្ធជុំវិញមានបណ្ដោយ ១០០ ម៉ែត្រ ទទឹង ៥២ ម៉ែត្រ តាមទំហំដី ។ តម្លៃគិលានដ្ឋាន ព្រមទាំងកំពែងជុំវិញផង ៤១៨.២០៨ រៀល, តម្លៃគ្រឿងសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងគិលានដ្ឋាន តទៅចំនួនជាង ២ ម៉ឺនរៀល, តម្លៃឱសថជាង ១០ ម៉ឺនរៀល ។ គិលានដ្ឋាននេះ ឋិតនៅត្រង់ជ្រុងថ្នល់ជាតិ និងថ្នល់ចូលទៅវត្តសុរភី និងវត្តពោធិព្រឹក្ស ចម្ងាយពីវត្តទាំង ២ នេះ ៤ គីឡូម៉ែត្រកន្លះដូចគ្នា ចម្ងាយពីក្រុងភ្នំពេញ បើគិតតាមផ្លូវកំពត ៣៨ គីឡូម៉ែត្រ បើគិតតាមថ្នល់មិត្តភាពនិងថ្នល់ទៅកំពង់ត្រាំ ៤៤ គីឡូម៉ែត្រ ។

នៅថ្ងៃព្រហស្បតិ៍ ១១ កើតខែមាឃ ឆ្នាំឆ្លូវត្រីស័ក ព.ស. ២៥០៤ ត្រូវនឹងថ្ងៃទី ១៨ កុម្ភៈ ១៩៦៥ សម្ដេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ បានស្ដេចយាងទៅជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធគិលានដ្ឋាន "ចំរើនសុខភាព" នេះ ស្ដេចយាងទៅដល់ទីនោះនៅវេលាម៉ោង ៩ រហូតដល់ម៉ោង ១៣ កន្លះ ទើបស្ដេចនិវត្តមកកាន់ព្រះរាជធានីភ្នំពេញវិញ ដោយព្រះទីនាំងឧទ្ធម្ភាគចក្រ ។

សម្ដេចព្រះមហាសុមេធាធិបតី បានមានថេរដីកាតំណាលប្រាប់យើងថា គិលានដ្ឋាននេះ ជាសាធារណៈប្រយោជន៍ដល់ប្រជាពលរដ្ឋ ៨ ឃុំ ដល់ភិក្ខុសាមណេរ ១៨ វត្ត ចាប់តាំងពីសម្ពោធរួចហើយរៀងមកសព្វថ្ងៃនេះ ក្នុង ១ ថ្ងៃៗ លើកលែងតែថ្ងៃអាទិត្យ មានប្រជាពលរដ្ឋចូលមក



រូបគិលានដ្ឋាន ចំរើនសុខភាព ថតពីខាងលិច ចំពីមុខ



រូបគិលានដ្ឋាន ចំរើនសុខភាព ថតពីខាងត្បូង ឃើញទាំងផ្ទះបាយផង

ប្រាស្រ័យនឹងគិលានដ្ឋាននេះ ច្រើនហួសពីការស្មានទុកពីមុនមក គឺក្នុង ១ ថ្ងៃ ៗ យ៉ាងតិចជាង ១០០ នាក់ យ៉ាងច្រើនជាង ៣០០ នាក់ ពេទ្យម្នាក់នឹងអ្នកជួយធ្វើការម្នាក់ផង ស្ទើរតែនឹងទប់មិនឈ្នះទៅហើយ ដោយមកពីគិលានដ្ឋាននេះ មានឱសថបរិបូណ៌ណាស់ ព្រោះនៅថ្ងៃសម្ពោធឆ្លងរៀងរហូតមកដល់សព្វថ្ងៃនេះ មានអស់លោក-អ្នកមានសទ្ធានៅក្រុងភ្នំពេញ បានជាវឱសថល្អ ៗ យកមកចូលបាប់កុសល ចំពោះសម្ដេចព្រះមហាសុមេធាធិបតី សម្ដេចក៏បេះតែយកឱសថទាំងនោះ ទៅបន្ថែមមិនឲ្យខ្វះខាត ។

នៅពេលសម្ពោធឆ្លងគិលានដ្ឋាននេះ សម្ដេចព្រះប្រមុខរដ្ឋទ្រង់ព្រះមេត្តាប្រោសប្រគេនបច្ច័យចំនួន ១០ ម៉ឺនរៀលចំពោះសម្ដេចព្រះមហាសុ-មេធាធិបតី ដើម្បីឲ្យស្ថាបនាថាវរវត្ថុមួយដែលជាសាធារណៈប្រយោជន៍តទៅទៀត សម្ដេចព្រះសង្ឃនាយក បានផ្ដើមនឹងស្ថាបនាប្រសូតិគ្រឹះ គឺផ្ទះធ្នប ១ ខ្នងឲ្យមានផ្ទះបាយនឹងម៉ាស៊ីនទឹកជាដើម ដូចគិលានដ្ឋាននេះដែរ នឹងសង់ក្នុងកំពែងគិលានដ្ឋាននោះ បំរុងនឹងឲ្យហើយស្រេចក្នុងកាលខាងចុងឆ្នាំ ១៩៦២ នេះ ថ្វាយសម្ដេចព្រះបិតាឯករាជ្យជាតិ ។ បើអាចផែលកបាន សម្ដេចព្រះសង្ឃនាយកនឹងបាត់ការស្ថាបនាសាលា ១ ខ្នង សម្រាប់អ្នកជម្ងឺសំណាក់ នឹងអាស្រម ៤ ឬ ៥ ខ្នង នៅក្នុងស្រះធំខាងលិចកំពែងគិលានដ្ឋាន សម្រាប់ភិក្ខុសាមណេរសំណាក់អាស្រ័យឲ្យពេទ្យបាក់ថ្នាំឲ្យ ចំពោះភិក្ខុសាមណេរដែលមានអាពាធក្ដៅ ។